ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ស្វែងយល់អរិយធម៌ខ្មែរ

## ភាគ ១

បេង ហេង

ឆ្នាំ ច អដ្ឋស័ក ពុទ្ធសករាជ ២៥៥០ គ្រឹស្តសករាជ

២០០៦

## អារម្ភកថា

សកម្មភាពពលកម្មផ្នែកខួរក្បាល និង រូបរាងកាយរបស់មនុស្សខ្មែរ គឺជាវប្បធម៌របស់ជាតិខ្មែរ។ បញ្ហាវប្បធម៌ទូទៅជាបញ្ហាសំខាន់មួយ ដែលឆ្លុះបញ្ចាំងនូវចំណេះដឹងទូទៅ ( La Connaissance Générale ) សម្រាប់កូនខ្មែរ ដែលត្រូវតែសិក្សាស្វែងយល់ ពីព្រោះវាជាតម្លៃមិនអាចកាត់ថ្លៃបានរបស់ព្រលឹងជាតិខ្មែរ និងប្រជាជនកម្ពុជាយើង។

ប្រទេសកម្ពុជា ជាប្រទេសមួយ ដែលសម្បូណ៌ទៅដោយប្រាង្គប្រាសាទសីលាផុសចេញពីព្រៃព្រឹក្សាស្ទើរពាសពេញប្រទេស។ ទំហំទ្រព្យសម្បត្តិដ៏ធំធេងនេះ បានធ្វើឱ្យកម្ពុជាល្បីសុះសាយ ជាហេតុទាក់ទាញអ្នកប្រាជ្ញ និង អ្នកទេសចរណ៍ចង់មកទស្សនាប្រទេសនេះ។ សម្បត្តិដ៏ថ្លៃថ្លានេះ ពិតជាកើតចេញពីស្នាដៃដ៏ពិសិដ្ឋរបស់ដូនតាយើង ដែលបានកសាងទុកជាកេរ្តិ៍មរតក ដល់កូនចៅជំនាន់ក្រោយ មិនមែនកើតឡើងដោយអភិនិហាររបស់អាទិទេពឡើយ។

រូបអង្គរវត្ត ត្រូវបានផ្តិតជាប់នឹងទង់ជាតិរបស់ខ្មែរ ជានិមិត្តរូបនៃភាពរុងរឿងនាសម័យមហានគរតំណាងឱ្យការរីកចម្រើនខាងវិស័យស្ថាបត្យកម្មខ្មែរបុរាណ ជាកញ្ចក់ឆ្លុះបញ្ចាំងនូវជីវភាពរស់នៅរបស់បុព្វបុរសខ្មែរ ព្រមទាំងការវិវត្តផ្សេងៗ នៃប្រវត្តិសាស្ត្រ។ ផ្តើមចេញពីការស្គាល់មនុស្សខ្មែរ ប្រភពលក្ខណៈជាតិខ្មែរ ធ្វើឱ្យជនជាតិនេះមានទឹកចិត្តស្នេហាជាតិ ស្នេហាទឹកដី និងប្រពៃណី ទំនៀមទំលាប់ដ៏ល្អរបស់ខ្លួន ដែលជាជនជាតិធ្លាប់មានអារ្យធម៌ខ្ពង់ខ្ពស់ កេរ្តិ៍ឈ្មោះល្បីល្បាញនាសម័យកាលមហានគរ គ.ស " ៨០២ - ១៤៣២ "។

ឆ្លងតាមបទពិសោធន៍កន្លងមក ក្នុងការស្រាវជ្រាវ និងបង្រៀនលើមុខវិជ្ជាវប្បធម៌ អរិយធម៌ខ្មែរ ខ្ញុំយល់ថាការសិក្សាមុខវិជ្ជានេះ គឺជាការចាំបាច់ណាស់ ចំពោះសិស្ស និស្សិត ដែលម្នាក់ៗ ត្រូវស្គាល់ខ្លួនឯងឱ្យបានច្បាស់ ស្គាល់អ្វីៗដែលជារបស់ជាតិខ្មែរ នោះទើបអាចរក្សាបាននូវអត្តសញ្ញាណជាតិខ្លួន ការពារឱ្យបានរឹងមាំ និងឈានទៅកសាងប្រទេសជាតិឱ្យបានរីកចម្រើនយ៉ាងឆាប់រហ័ស។ បើខ្មែរម្នាក់ៗ ពុំស្គាល់ខ្លួនឯង ពុំស្គាល់វប្បធម៌ អរិយធម៌របស់ខ្លួនច្បាស់លាស់ទេនោះ អាចឈានទៅរកការរលំរលាយជាតិ។ យើងនៅតែមានសង្ឃឹមថា " ខ្មែរមិនសាបសូន្យ " ដូចជាភ្លេងជាតិលើកឡើងថា " ជាតិខ្មែរដូចថ្ម រឹងប៉ឹងជំហរ......"។

អាស្រ័យហេតុនេះ ខ្មែរគ្រប់រូបត្រូវភ្ញាក់រលឹកវិលមកគិតរឿងជាតិ ហើយមិនត្រូវបណ្តែតបណ្តោយភ្លេចខ្លួនឱ្យព្រលឹងជាតិរលាយបាត់បង់ឡើយ។

ខ្ញុំបាទសង្ឃឹមញញឹមទុកជាមុន ក្នុងបំណងរង់ចាំជានិច្ចនូវគំនិតរិះគន់ជួយ ស្ថាបនាពីសំណាក់ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដោយក្តីសង្ឃឹមប្រកបដោយទឹកចិត្តសោមនស្សរីករាយជាទីបំផុត។

សូមអរព្រះគុណ និងអរគុណ!

ភ្នំពេញ. ធ្វើនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

សាស្ត្រាចារ្យអក្សរសាស្ត្រ ផ្នែកអរិយធម៌ខ្មែរ

**បេង ហេង**

# សេចក្ដីផ្ដើម

គ្រប់ជាតិសាសន៍នៅលើលោកយើងនេះ សុទ្ធតែមានវប្បធម៌ អរិយធម៌ជាមូលដ្ឋាន សម្រាប់ទ្រទ្រង់ប្រទេសជាតិរបស់គេរៀងៗខ្លួន។ ដោយសារពលកម្មខាងខួរក្បាល និងខាងរូបកាយរបស់មនុស្សធ្វើឱ្យមានការវិវត្តព្រមទាំងរីកចម្រើនឥតឈប់ឈរ ។ ប្រទេសណាមានការរីកចំរើនខ្លាំង គេតែងនិយាយថាវប្បធម៌ អរិយធម៌របស់ប្រទេសនោះខ្ពង់ខ្ពស់ ឬគេហៅ " អារ្យប្រទេស "។

ជនជាតិខ្មែរគឺជាជនជាតិមួយរស់នៅលើទឹកដីរបស់ខ្លួន បានកសាងខឿនវប្បធម៌ អរិយធម៌តាំងពីសម័យ នៃការកកើតទឹកដីមកម្លេះ ។ ប្រវត្តិសាស្ត្របានបញ្ជាក់ថា ជនជាតិខ្មែរបានកសាងវប្បធម៌ អរិយធម៌របស់ខ្លួនខ្ពស់ត្រដែត ហើយល្បីល្បាញពាសពេញសកលលោកនាសម័យមហានគរ ពេលនោះខ្មែរបានក្លាយទៅជាមហាអំណាចមួយយ៉ាងធំ នៅភូមិភាគអាស៊ីអាគ្នេយ៍។

អាស្រ័យហេតុនេះ ខ្មែរគ្រប់រូបគួរគប្បីខំស្វែងយល់វប្បធម៌ អរិយធម៌ជាតិរបស់ខ្លួនឱ្យបានច្បាស់ មុននឹងឈានទៅស្គាល់វប្បធម៌ អរិយធម៌ជាតិសាសន៍ដទៃទៀត។ ស្គាល់វប្បធម៌ អរិយធម៌ជាតិខ្លួន គឺស្គាល់ប្រភពលក្ខណៈរបស់ជាតិ ព្រមទាំងស្គាល់តម្លៃពិសេសនៃវប្បធម៌ អរិយធម៌តាំងពីសម័យបូរាណ ដើម្បីឆ្លុះបញ្ចាំងនូវធាតុសកម្ម និងអសកម្មរបស់មែងធាងវប្បធម៌ អរិយធម៌ ដែលមានកន្លងមក។ ក្រោយពីការយល់ដឹងពីតម្លៃវប្បធម៌ អរិយធម៌ និងធាតុផ្សេងៗដែលមានឥទ្ធិពលទៅលើវប្បធម៌ អរិយធម៌នោះហើយ នាំឱ្យយើងមានមោទនភាពឈានទៅស្គាល់ជាតិរបស់ខ្លួន ស្គាល់ទឹកដី ស្គាល់ការវិវត្ត របស់សង្គមជាតិ ហើយកោតសរសើរស្នាដៃដូនតាយើង ដែលបានបន្សល់ទុកនូវកេរ្តិ៍ដំណែលសម្បត្តិវប្បធម៌ អរិយធម៌ ទំនៀម ទំលាប់ ប្រពៃណីដ៏ល្អប្រពៃ សម្រាប់កូនខ្មែរជំនាន់ក្រោយ។

ទន្ទឹមនឹងការស្គាល់តម្លៃជាតិ មោទនភាពជាតិរួចមក យើងមិនត្រូវបន្ទាបវប្បធម៌ អរិយធម៌ជាតិសាសន៍ដទៃទៀតដែរ ពីព្រោះលក្ខណៈស្ថិតស្ថេររបស់ជាតិនីមួយៗតែងតែមាន ហើយទំនាក់ទំនងអរិយធម៌ជាតិ និងអរិយធម៌បរទេស វាជាផលរួមឈានទៅរកការរីកចម្រើន។

ចូរខ្មែរគ្រប់រូប ខិតខំរក្សាការពារខឿនវប្បធម៌ អរិយធម៌ជាតិឱ្យបានគង់វង្ស និងរីកចំរើន។

" វប្បធម៌រលត់ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន "

# គោលបំណង

## ១. ចំណេះដឹង

❖ បណ្ដុះមនោសញ្ចេតនា ឱ្យចេះថែរក្សាការពារនូវអ្វីៗ ដែលជារបស់ជាតិ មរតកវប្បធម៌ជាតិ ពោលគឺ វប្បធម៌ អរិយធម៌ដ៏រុងរឿងរបស់បុព្វបុរសដែលបានបន្សល់ទុកឱ្យ។

❖ ស្គាល់ច្បាស់នូវប្រភពលក្ខណៈនៃវប្បធម៌ អរិយធម៌ខ្លួន គ្រប់ឥរិយាបថ ដេក ដើរ ឈរ អង្គុយ ទំនៀម ទំលាប់ប្រពៃណី ជំនឿសាសនា សិល្បៈ.....របស់ជាតិ។

## ២. ចំណេះធ្វើ

❖ ចេះច្នៃប្រឌិតនូវអ្វីៗ ដែលមិនមែនជារបស់ជាតិខ្លួនឱ្យទៅជារបស់ជាតិខ្លួន " *ជាតូបនីយកម្ម* " ស្របតាម ដួងប្រលឹងជាតិ។

❖ ផ្សារភ្ជាប់ចំណេះដឹងទូទៅស្តីពីវប្បធម៌ជាតិ អន្តរជាតិ រួមជាមួយនឹងមុខវិជ្ជាឯកទេសផ្ទាល់ខ្លួន ដើម្បីលើក កម្ពស់គុណភាពអប់រំ តាមផែនការរបស់ជាតិ។

❖ និយមប្រើប្រាស់នូវអ្វីៗ ដែលជារបស់ជាតិ និងផ្សព្វផ្សាយ ថែរក្សា ការពារ និងលើកតម្កើងនូវអ្វីៗ ដែល ជារបស់ជាតិ។

## ៣. ឥរិយាបថ

❖ ស្គាល់កាតព្វកិច្ច និងស្វ័យអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋល្អ មានមនសិការក្នុងរបរវិជ្ជាជីវៈ តាមសម្មាជីវោ។

❖ ស្គាល់ព្រំដែននៃសិទ្ធិ និងច្បាប់ ករណីយកិច្ច និងការទទួលខុសត្រូវ ដើម្បីចៀសវាងការរំលោភសិទ្ធិ។

❖ មានសាមគ្គីភាពល្អ ស្រឡាញ់យុត្តិធម៌ និងស្រឡាញ់មនុស្សជាតិទូទៅ។

❖ មានទំនាក់ទំនងល្អជាមួយជាតិ និងអន្តរជាតិ មិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ជំនឿសាសនា.......។

❖ ចេះថែរក្សាការពារបរិស្ថាន។

## ៤. ចំណេះចេះរស់នៅក្នុងសង្គម

❖ ចេះរស់នៅក្នុងសង្គមជាមួយគ្នា ស្រឡាញ់រាប់អានគ្នា គោរពសិទ្ធិគ្នា រក្សាបាននូវវប្បធម៌សន្តិភាព។

❖ ចេះរស់នៅប្រកបដោយចរិយាធម៌ គុណធម៌ ដើម្បីរស់នៅក្នុងសេចក្តីថ្លៃថ្នូរ។

# មាតិការឿង


ទំព័រ

១- ប្រទេសកម្ពុជា........................................ ៥
២- វប្បធម៌ អរិយធម៌ខ្មែរ........................................ ៨
៣- ដើមកំណើតនៃពាក្យវប្បធម៌ ........................................ ១០
៤- ន័យនៃពាក្យវប្បធម៌ និងមែកធាងរបស់វប្បធម៌........................................ ១៤
៥- ន័យនៃពាក្យសង្គមធម៌ និងមែកធាងរបស់សង្គមធម៌........................................ ១៥
៦- ទំនាក់ទំនងរវាងវប្បធម៌ និងសង្គមធម៌ ........................................ ១៧
៧- ន័យនៃពាក្យអរិយធម៌ និងមែកធាងអរិយធម៌........................................ ១៨
៨- ធាតុសំខាន់ៗ ដែលសំរេចឱ្យកើតមានវប្បធម៌ អរិយធម៌របស់ជាតិមួយ........................................ ២០
៩- ទំនាក់ទំនងអរិយធម៌ខ្មែរ និងអរិយធម៌បរទេស........................................ ២២
១០- ដើមកំណើតជនជាតិខ្មែរ........................................ ៣១
១១- លក្ខណៈពិសេសរបស់អរិយធម៌ខ្មែរ ........................................ ៣៤
១២- វប្បធម៌អូស្ត្រូអាស៊ី ( អាស៊ីខាងត្បូង ) ........................................ ៣៤
១៣- អំពីសាសនា និងប្រភពនៃសាសនានៅកម្ពុជា........................................ ៤០
១៤- ព្រហ្មញ្ញសាសនា........................................ ៤១
១១- លទ្ធិព្រាហ្មណ៍ក្នុងសង្គមខ្មែរ........................................ ៦១
១៥- ព្រះពុទ្ធសាសនា........................................ ៧១
១៦- ពុទ្ធប្រវត្តិ ........................................ ៧២
១៧- ទ្រឹស្តីសំខាន់ៗរបស់ព្រះពុទ្ធ........................................ ៧៥
១៨- អំពីពុទ្ធលទ្ធិ ........................................ ៧៨
១៩- ពុទ្ធ ភាវៈ សុខៈ ក្នុងសាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនា........................................ ៨៥
២០- ព្រះពុទ្ធសាសនា និងសង្គមខ្មែរ........................................ ៩០







# ផែនទីសម័យមហានគរ



# ផែនទីប្រទេសកម្ពុជានាពេលបច្ចុប្បន្ន




ផ្ទៃដី : ១៨១ ០៣៥ គីឡូម៉ែត្រការេ

ខេត្ត-ក្រុង : ២៤

អាកាសធាតុ : ក្ដៅ ហើយសើម

ប្រជាជន : ១៣ ០៩១ ០០០ លាននាក់ ( អង្កេតប្រជាជនចន្លោះជំរឿនឆ្នាំ ២០០៤ )

ចំពោះការបែងចែករដូវ ប្រទេសកម្ពុជាចែកចេញជាបីរដូវ គឺរដូវវស្សា (ពីខែមិថុនា ដល់ខែកញ្ញា) រដូវរងា ( ពីខែតុលាដល់ខែមករា) និងរដូវប្រាំង ( ពីខែកុម្ភៈ ដល់ខែឧសភា ) ។ តែរដូវរងានៅប្រទេសកម្ពុជាមិនត្រជាក់ខ្លាំងដូចជានៅប្រទេសឯទៀតៗឡើយ ។ ប៉ុន្តែអ្នកខ្លះគេចែករដូវនៅប្រទេសកម្ពុជាជាពីររដូវប៉ុណ្ណោះ គឺរដូវភ្លៀង និងរដូវក្ដៅពីព្រោះប្រជាជនកម្ពុជា អាចប្រកបរបររកស៊ីធ្វើស្រែចម្ការ និងដំណាំដាំដុះផ្សេងៗ បានស្ទើរគ្រប់រដូវ ។

ប្រទេសកម្ពុជា ជាប្រទេសមួយស្ថិតនៅភូមិភាគអាស៊ីអាគ្នេយ៍ មានព្រំប្រទល់ជាប់ប្រទេសវៀតណាម ឡាវ ថៃ និងឈូងសមុទ្រ ដែលមានឆ្នេរប្រវែង ៤៤០ គម ។ មានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រការេ គឺប្រមាណ ១/៣ នៃប្រទេសថៃ ។ មានសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំ ២៨.៥ អង្សា ។ ប្រទេសកម្ពុជាមានអំណោយផលធម្មជាតិជាច្រើនដូចជា ÷

❖ ទន្លេសាបគឺជាបាតសមុទ្រដ៏ជ្រៅ នាសម័យដើម ត្រូវចាក់បំពេញដោយដីល្បាប់នៃទន្លេមេគង្គ មានរាងជាបាតខ្ទះ ហើយក៏ជាជំរកត្រីទឹកសាបផងដែរ ។

❖ វាលទំនាបកណ្តាល ដែលលាតសន្ធឹងពីទិសពាយ័ព្យទៅអាគ្នេយ៍ សុទ្ធសឹងជាតំបន់ដែលមានដីជាតិជាអំណោយផល ដល់កសិករប្រកបមុខរបរកសិកម្ម ។

❖ ជួរភ្នំនៅខាងលិច ខាងជើង និងខ្ពង់រាបប៉ែកខាងកើត ជារនាំងការពារខ្យល់ព្យុះ និងគ្រោះមហន្តរាយ ដែលបណ្តាលមកពីបាតុភូតធម្មជាតិនានា ។

❖ កំដៅ និងសំណើមនៃអាកាសធាតុ បានអនុគ្រោះដល់ដំណាំដាំដុះ រុក្ខជាតិ និងជាជំរកសត្វព្រៃ ។

❖ ប្រទេសកម្ពុជា ជាប្រទេសមួយមានធនធានធម្មជាតិយ៉ាងច្រើន ដែលជាទុនមួយផ្នែកសម្រាប់ធ្វើការអភិវឌ្ឍសង្គម ជាតិ ដូចជារ៉ែ ព្រៃឈើ ឧស្ម័ន ( នៅតាមកោះដែនសមុទ្រមួយចំនួន ) ។



# សិក្សាវប្បធម៌ អរិយធម៌ខ្មែរ

យើងដឹងហើយថា ប្រភពរបស់វប្បធម៌របស់មនុស្សកើតចេញពីពលកម្ម ។ ពលកម្មមានពីរគឺ ពលកម្មខួរក្បាល និងពលកម្មផ្នែករូបរាងកាយ ។ ពលកម្មផ្នែកខួរក្បាល តម្រូវឱ្យរូបរាងកាយធ្វើសកម្មភាព ឬផលិតនូវអ្វីៗ សព្វបែបយ៉ាង ដើម្បីបម្រើ ឬបំពេញតម្រូវការខាងខួរក្បាល ។

កាលដើមឡើយមានសុទ្ធតែទឹកសមុទ្រ បន្ទាប់មកទើបមានជួរភ្នំទាំងឡាយ បានផុសចេញពីទឹកសមុទ្រនៅពេលនោះ ប្រមាណក្នុងកំឡុងស័ក្តទី១ ( *Ere Primaire* ) ភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូល បានជួបប្រទះនូវបាតុភូតធម្មជាតិមួយឈ្មោះថាពំនើងផ្ទត់ ( *Plissement Calédonien et Hercynien* ) ឬហៅថា ប្រតិកម្ម ( *Tétonique* ) ដែលបណ្តាលឱ្យផុស នូវជួរ ភ្នំទាំង ឡាយពីក្នុងទឹកសមុទ្រ និងខ្ពង់រាបនានាពាសពេញភូមិភាគ ក៏ដូចជានៅលើទឹកដីកម្ពុជាយើងដែរ ។

បន្ទាប់មកបាតុភូតធម្មជាតិនោះ ក៏ធ្វើឱ្យជួរភ្នំ និងខ្ពង់រាបនានាលិចទៅក្នុងទឹកសមុទ្រវិញ រហូតទៅដល់ចុងស័ក្តទី៣ ។ នៅដើមស័ក្តទី ៤ ក៏ចាប់ផ្តើមផុសនូវជួរភ្នំ និងខ្ពង់រាបម្តងទៀត ចាប់ពីភូមិភាគភ្នំហេមពាន្តឆ្ពោះមកភូមិភាគអាស៊ី អាគ្នេយ៍ទាំងមូល ។ ដោយឡែក ទឹកដីខ្មែរយើងមួយចំនួនក៏ត្រូវផុសឡើងដែរ ។ ក្នុងកំឡុងស័ក្តទី ៤ មានបាតុភូតធម្មជាតិមួយ ទៀត គឺទឹកជោរ ទឹកនាចច្រើនលើកច្រើនសារ ។ នៅចន្លោះឆ្នាំពី ៦០.០០០ ឆ្នាំមក ១៥.០០០ ឆ្នាំមុនគ.ស ទឹកសមុទ្របាននាច ថយពី ១៣០ - ១៥០ ម៉ែត្រ បើប្រៀបធៀបនឹងកំពស់ទឹកសមុទ្រសព្វថ្ងៃ ។ ដោយហេតុខាងលើនេះហើយ បានជាពេលនោះ ភូមិភាគឥណ្ឌូចិន និងប្រជុំកោះអាំងស៊ុយឡាំង ( *Insulinde* ) ស្ថិតនៅជាប់គ្នារហូតគ្មានខ័ណ្ឌទឹកសមុទ្រដូចសព្វថ្ងៃនេះទេ ។ កំឡុង ១៥. ០០០ ឆ្នាំមុនគ.ស គេឃើញទឹកសមុទ្របានជោរឡើងកំពស់ ១៥ ម៉ែត្រ ជាហេតុនាំឱ្យទឹកដីខ្មែរយើងផ្នែកខាងក្រោម និងតំបន់វាលទំនាប ត្រូវលិចទៅក្នុងទឹកសមុទ្រវិញ ។ លុះដល់សតវត្សទី ៣ មុន គ.ស ទឹកសមុទ្របាននាចបន្តិចម្តងៗទៅវិញ ពេលនោះទន្លេមេគង្គបានហូរនាំដីល្បាប់មកចាក់បំពេញបង្កើតជាទឹកដីសណ្តូ ( *Delta*) ឡើងឆ្ពោះទៅទិសខាងត្បូង ។ អាស្រ័យដូចបានរៀបរាប់ខាងលើ បានជាលក្ខណៈភូមិសាស្ត្រនៃប្រទេសកម្ពុជា មានភ្នំ និងខ្ពង់រាបព័ទ្ធជុំវិញ ប្រៀបបាននឹងខ្ទះមួយ ដែលមាត់លើខ្ពស់ ជាហេតុនាំឱ្យប្រទេសកម្ពុជា ជាប្រទេសមួយ ពុំសូវជួបប្រទះនឹងបាតុភូតធម្មជាតិ ដូចជាខ្យល់ព្យុះធំៗ ដូចប្រទេសដទៃទៀតឡើយ ។

យើងសង្កេតឃើញថា នៅពេលដែលជួរភ្នំ និងខ្ពង់រាបទាំងឡាយផុសចេញពីក្នុងទឹកសមុទ្រ ពេលនោះភាវៈមានជីវិត និងឥតជីវិត ( *Les êttres* Vivants ) ក៏កើតមានឡើងដែរ ។ ជាមួយគ្នានោះ សត្វស្វាម្យ៉ាងដែលមានកំណើតជាមនុស្សបានកកើតមាននៅលើភពផែនដី ។ ដើម្បីរស់រានមានជីវិត និងគេចឱ្យផុតពីការគំរាមកំហែងនៃពំនើងផ្ទត់ ពួកគេបាននាំគ្នារត់ទៅរស់នៅលើកំពូលភ្នំ ចោះភ្នំជាលំនៅ ។ នៅពេលឥទ្ធិពល នៃពំនើងផ្ទត់ថយចុះ គេចុះមករស់នៅតាម

ចង្កេះភ្នំ ធ្វើផ្ទះពីស្លឹកឈើ សំបកឈើរុំព័ទ្ធបិទបាំងនៅសល់រន្ធចេញចូលតែមួយ។ ការធ្វើផ្ទះបែបនេះ ដោយសារពលកម្មខួរក្បាល គេយល់ថា ដើម្បីការពារអាកាសធាតុត្រជាក់តំបន់ព្រៃភ្នំ និងការពារសត្វសាហាវផ្សេងៗ។

បន្ទាប់ពីឥទ្ធិពលនៃពំនើងផ្ទត់បានបាត់បង់ទៅ និងទឹកជោរទឹកនាចថយឥទ្ធិពលរបស់ខ្លួន ស្វាមនុស្សបានចុះមករស់នៅតាមវាលទំនាប ជាមួយគ្នានោះ ទន្លេមេគង្គ បានហូរនាំដីល្បាប់មកចាក់បំពេញ បង្កើតបានជាដី វាលទំនាបនៅសល់តែបឹងទន្លេសាបមួយទេ ដែលជា បាតុសមុទ្រដ៏ជ្រៅ និងចំណាស់ជាងគេ។

ជីវភាពរស់នៅរបស់ស្វាមនុស្ស បានរស់ នៅជាហ្វូង ជាពួក ជាក្រុម ដែលហៅថាក្រុមកុល សម្ព័ន្ធ ក្នុងនោះបានដឹកនាំ និងបានទទួលខុសត្រូវលើ បូរណភាពដែនដី ដោយមេក្រុមកុលសម្ព័ន្ធ។ មេក្រុម កុលសម្ព័នទាំងនេះ ជា អ្នករកយុត្តិធម៌ និងការពារ សុវត្ថិភាព ឱ្យកូនក្រុមកុលលសម្ព័ន្ធ។ លុះមេក្រុមកុល សម្ព័ន្ធស្លាប់ទៅ គេមានជំនឿថាព្រលឹងរបស់មេក្រុម កុល សម្ព័ន្ធឥតស្លាប់ទេ នៅតែជួយថែរក្សាពួកគេតទៅ ទៀត។ ពេលជួបអាសន្នអន់ក្រម្តងៗ គេតស៊ូប្រយុទ្ធដោយកម្លាំងក្នុងខ្លួនអស់សមត្ថភាពហើយ គេតែងតែ ពឹងផ្អែកលើកម្លាំងក្រៅខ្លួនរបស់គេទៀត គឺការបន់ ស្រន់ហៅរកព្រលឹងមេក្រុមកុលសម្ព័ន្ធឱ្យជួយពួក គេ ជំនឿនេះសម័យក្រោយមកគេហៅថា ជំនឿទៅលើអារក្ខអ្នកតា។

កាលដើមឡើយ ពួកគេស៊ីស្លឹកឈើ មើមឈើជាអាហារ ដោយមានការរីកចំរើន និងបទពិសោធន៍ផ្អែកពលកម្មខួរក្បាល និងរូបរាងកាយរបស់ពួកគេ ពួកគេរកឃើញគ្រាប់ធញ្ញជាតិសំរាប់ដាំដុះ ដើម្បីយកផលល្អានុផលធ្វើជាអាហារ ពោលគឺឈប់ហូបស្លឹកឈើទៀតហើយ។ ពួកគេកាលដើមឡើយស៊ីសាច់នៅជាអាហារ ដែលជាហេតុធ្វើឱ្យពលកម្មខួរក្បាល និងរូបរាងកាយចេះផលិតសំភារៈ ដើម្បីសំលាប់សត្វ ដោយយកឈើ ថ្ម ឆ្អឹងសត្វធ្វើជាអាវុធ និងសំភារៈប្រើប្រាស់។

ក្រោយមក ពួកគេរកឃើញវត្ថុធាតុរឹងគួតគ្នាចេញជាផ្កាភ្លើង មានន័យថាគេបានរកឃើញភ្លើង សំរាប់ចំអិនអាហារផ្សេងៗ ពេលនោះគេឈប់ហូបសាច់នៅទៀតហើយ គេឈានមកហូបសាច់ឆ្អិនវិញ និងចំអិនម្ហូបអាហារផ្សេងៗ។ តមកទៀត ដោយសារការរីកចំរើនផ្អែកពលកម្មខួរក្បាល និងរូបរាងកាយ ពួកគេចេះស្លលោហៈធាតុផលិតនូវសំភារៈប្រើប្រាស់គ្រប់បែបយ៉ាង ដើម្បីបំពេញតម្រូវការរបស់ពួកគេ។ កាលដើមឡើយ ខ្លួនពួកគេអាក្រាត គ្មានការអៀនខ្មាស់







ការវិវត្តពីស្វាមនុស្ស មកជាមនុស្ស

បន្ទាប់មកមិនយូរប៉ុន្មាន ពួកគេចាប់ផ្តើមមានការរៀនខ្វាស់យកស្លឹកឈើ ឬសំបកឈើបិទបាំងរូបរាងកាយ រហូតដល់ចេះដាំដើមគរ កប្បាសយកមកត្បាញ រវៃធ្វើជាសំលៀកបំពាក់ ។បំពាក់ ។

ដោយសារការអភិវឌ្ឍផ្នែកពលកម្មខួរក្បាល និងរូបរាងកាយរបស់ពួកគេ ធ្វើឱ្យពួកគេចេះធ្វើម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ ម៉ាស៊ីនស្វ័យប្រវត្តិ ចេះផលិតសំភារៈប្រើប្រាស់ទំនើប១ឈានឡើងឥតឈប់ឈរ រហូតចេះធ្វើគ្រឿងអេឡិចត្រូនិច ម៉ាស៊ីន កុំព្យូទ័រ និងម៉ាស៊ីនអាប៉ូឡូសព្វថ្ងៃនេះ ។

*តើវប្បធម៌មានកំណើតកើតមក ពីណា ?*

*តើវប្បធម៌ចាប់ផ្តើមមានចាប់ពីពេលណាមក ?*



យើងដឹងហើយថា ពលកម្ម គឺជាសកម្មភាពមានបំណងរបស់មនុស្ស ។ រីឯវប្បធម៌ក៏មានកំណើតកើតចេញពីពលកម្មដែរ ហើយមានកំណើតដំណាលគ្នានឹងកំណើតមនុស្ស មានន័យថា មនុស្សមានកំណើតពេលណាវប្បធម៌ ក៏ចាប់ផ្តើមមានពេលនោះ ពីព្រោះមនុស្សមានជីវិតកាលណា តែងតែធ្វើពលកម្មពេលនោះដែរ ពោលគឺ សកម្មភាពនោះឯង ។ នៅលើសាកលលោកយើងនេះ គេសង្កេតឃើញថា សកម្មភាពពលកម្មខួរក្បាល និងរូបរាងកាយរបស់មនុស្ស មានការវិវត្តមិនដូចគ្នាទាំងស្រុងនោះទេ ពីព្រោះការវិវត្តពីក្រុមកុលសម្ព័ន្ធ

ក្លាយមកជាប្រទេសនីមួយៗ គឺអាស្រ័យទៅដោយស្ថានភាពភូមិសាស្ត្រ សេដ្ឋកិច្ចនៃជនជាតិនីមួយៗរស់នៅ ដូចនេះហើយ មានក្រុមខ្លះ ប្រទេសខ្លះជឿនលឿន ក្រុមខ្លះ ប្រទេសខ្លះអន់ថយទៅតាមតម្លៃយល់ដឹង និងការវិវត្តនៃប្រវត្តិសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចនៃជនជាតិ នោះ។



ប្រជាជាតិ ដែលសប្បុរិរុងរឿង មានកម្រិតយល់ដឹងខ្ពស់ គេថាមានវប្បធម៌ខ្ពស់ ចំពោះប្រជាជាតិ ដែលមានការយល់ដឹងទាប គេថាមានវប្បធម៌ទាប ការវាយតម្លៃរបស់ជនជាតិមួយជាការលំបាកបំផុត ហាក់បីដូចជាពុំសូវត្រឹមត្រូវនោះទេ ពីព្រោះគេពិបាកនឹងថ្លឹងថ្លែងថា វប្បធម៌របស់ជននោះខ្ពស់ ឬទាប ពីព្រោះវប្បធម៌របស់ជនជាតិមួយ ប្រជាជាតិរបស់គេតែងតែអួតសរសើរ និងមានមោទភាពចំពោះជន ជាតិ គេរៀងៗខ្លួន។



*ឧទាហរណ៍ :* ភ្លេងចិន
យើងស្តាប់ហាក់ទៅ ហាក់មិនពិរោះ
ភ្លេងខ្មែរយើងស្តាប់ទៅពិរោះពេញ ចិត្ត។

សរុបមក យើងឃើញថាជនជាតិនីមួយៗមានវប្បធម៌ផ្សេងៗគ្នា ជនជាតិខ្មែរយើងក៏មានវប្បធម៌ខុសប្លែកពីគេដែរ ពោលគឺ មានវប្បធម៌ច្បាស់លាស់សម្រាប់ជនជាតិខ្មែរ។



*ឧទាហរណ៍ :* នារីខ្មែរមានវប្បធម៌ច្បាស់លាស់របស់ខ្លួន ហើយប្លែកពីគេដូចជា សុភាពរាបសាទន់ភ្លន់ មានការ អៀនខ្មាស់ច្រើន អ៊ឹមអៀនមើល មិនចំ.....។

ចាប់តាំងពីការកកើតទឹកដីមក ជនជាតិខ្មែរបានកសាងទឹកដី និងវប្បធម៌របស់ខ្លួន បានល្អប្រសើរខ្ពង់ខ្ពស់ ហើយ ល្បីល្បាញសុះសាយនៅលើ



ពិភពលោក។ *ឧទាហរណ៍ :* នៅសម័យអង្គរ ខ្មែរយើងបានកសាងវប្បធម៌មួយខ្ពស់យ៉ាងត្រដែត ដែលគេបានចាត់ទុកថាជាអរិយធម៌ខ្ពង់ខ្ពស់នា សម័យអង្គរ។ តាមប្រវត្តិសាស្ត្រអង្គរ សង្គមវិទូ ប្រវត្តិវិទូ គេសន្មត់ថាខ្មែរជាមហាអំណាច ដ៏ធំមួយនៅភូមិភាគអាស៊ីអាគ្នេយ៍ វប្បធម៌ អរិយធម៌ខ្មែរ នៅសម័យអង្គរ ដែលធ្លាប់តែល្បីល្បាញ នេះត្រូវបានសង្គ្រាមបំផ្លិចបំផ្លាញឥតឈប់ ឈរ ព្រមទាំងពួកអាណា និគម បានបំផ្លិចបំផ្លាញបន្តិចម្តងៗ ធ្វើឱ្យវប្បធម៌ខ្មែរចុះអន់ថយ ថែមទាំងចុះអនុភាពលែងមានជំនឿលើខ្លួនឯង ថា ខ្លួនឯងជា អ្នកពូកែ អស្ចារ្យនោះ រហូតហ៊ាន និយាយថាប្រាសាទអង្គរវត្តគឺព្រះវិស្ណុជាអ្នកកសាងទៅវិញ "អភិនិហាររបស់អាទិទេព "។



*ឧទាហរណ៍ :* ក្រោយសម័យអង្គរ ប្រជាជនអង្គុយហូបបាយចោងហោង បញ្ជាក់នូវការប្រុងប្រយ័ត្នសង្គ្រាមរបស់ ពួកអាណានិគម និងសត្រូវគ្រប់ប្រភេទ " បាក់ស្បាត "។ កាចសាហាវជាងនេះទៅទៀត គឺរបបអតីតកាល "អាវខ្មៅ " បានបំផ្លិចបំផ្លាញវប្បធម៌ឱ្យសាបសូន្យ បំផ្លាញសម្បត្តិ វប្បធម៌ជាតិឱ្យវិនាសអន្តរាយ

ពីព្រោះពួកគេ បានបដិសេធទាំងស្រុង និងបំផ្លាញសម្បត្តិវប្បធម៌ជាតិ ដែលមានពីសង្គមចាស់ មានន័យថាអ្វីៗ ដែលចាស់ រួមទាំងមនុស្ស



ផងដែរ។ ពួកគេពុំយល់ថា វប្បធម៌របបចាស់ ពិតជាមានវប្បធម៌ជឿនលឿនរបស់ មហាជន ប្រជាជនយើងនោះទេ ត្រូវ គិតថាអ្វីៗទាំងអស់ ដែលជាវប្បធម៌របស់ប្រជាជន ត្រូវតែពង្រឹង និងពង្រីកថែមទៀត ព្រមទាំង បង្កើតវប្បធម៌ថ្មី ដែល មានលក្ខណៈជាតិជឿនលឿន។ ការសិក្សាវប្បធម៌ អរិយធម៌ គឺជាការចាំបាច់ ក្នុងការកសាងវប្បធម៌ថ្មី ហើយត្រូវស្គាល់ ធាតុសកម្ម និងធាតុអសកម្មរបស់វប្បធម៌នាសង្គមចាស់សិន។ ទស្សនៈវិទូ និង ប្រវត្តិវិទូបានមានប្រសាសន៍ថា " បើគ្មាន អតីតកាល គឺគ្មានបច្ចុប្បន្នកាល ហើយក៏គ្មានអនាគតកាលដែរ"។ ឈរលើស្មារតី នេះ យើងអាចចែកវប្បធម៌សង្គម ចាស់ ជាពីរ គឺ វប្បធម៌ចាស់គំរិលអន់ថយ ដែលមានការរំលោភសិទ្ធិមនុស្ស និង វប្បធម៌ជឿនលឿន ដែលមានការគោរពសិទ្ធិ មនុស្ស។ ដូចនេះហើយ យើងអាចដឹងថា វប្បធម៌សង្គមចាស់ មានវប្បធម៌មហាជន តែពុំអាចរីកចំរើនបានទេ ពីព្រោះ តែមានការ រំលោភ សិទ្ធិ។

***មតិទី ១ :*** គេយល់ថា ការកសាងវប្បធម៌ថ្មី ត្រូវទាត់ចោលវប្បធម៌ចាស់ទាំងស្រុង កសាងវប្បធម៌ដោយ ឡែក ដែលពុំធ្លាប់មាន។

***មតិទី ២ :*** ត្រូវរក្សាវប្បធម៌ចាស់ទាំងស្រុង ពីព្រោះវប្បធម៌ជាតិនីមួយៗ មានលក្ខណៈសកល សម្រាប់ ជាតិមួយ។

មតិទាំងពីរខាងលើនេះ គឺជាមតិភាន់ច្រឡំ គឺមិនទុកទាំងស្រុង ឬទាត់ចោលទាំងស្រុងនោះទេ។ រីឯវប្បធម៌កម្ពុជាយើង គឺកសាងវប្បធម៌ថ្មី ដោយកំចាត់វប្បធម៌ពុករលួយពាលាអាវ៉ាសែ ហើយពង្រឹងរក្សាទុកនូវវប្បធម៌មហាជនដែលមានលក្ខណៈជឿនលឿន ដែលមានតាំងពីយូរយាណាស់មកហើយ។

**I. ន័យនៃពាក្យវប្បធម៌ និងមែកធាងរបស់វប្បធម៌**

**ក. វប្បធម៌ តាមន័យស័ព្ទជាតិ :**

វប្បធម៌ > វប្ប + ធម៌

វប្ប : ការសាបព្រួស ការបណ្ដុះផ្សាំ ការបណ្ដុះពូជ ការបណ្ដុះបណ្ដាល

ធម៌ : ធម្មភាព ធាតុ វិធី សភាវៈទ្រទ្រង់ ទ្រឹស្ដី

ចំពោះពាក្យវប្បធម៌មានមតិជាច្រើនបានឱ្យនិយមន័យប្លែកៗគ្នា។

**ខ. ទស្សនៈផ្សេងៗ**

- ខ្លះយល់ថា វប្បធម៌ គឺជាការបណ្ដុះផ្សាំ ការសាបព្រួស ការបណ្ដុះបណ្ដាលទាំងផ្នែកស្មារតី និងប្រាជ្ញា
- ខ្លះយល់ថា វប្បធម៌ គឺជាចំណេះដឹង ការសិក្សាអប់រំ ឬអ្វីៗ ដែលទាក់ទងទៅនឹងការសិក្សា
- ខ្លះយល់ថា វប្បធម៌ គឺជាអ្វីដែលធ្វើឱ្យរីកលូតលាស់លើគ្រប់វិស័យ

**គ. តាមវចនានុក្រមខ្មែរ របស់សម្ដេចសង្ឃ ជួន ណាត**

វប្បធម៌ សម្គាល់នូវការផ្សាំ បណ្ដុះចំណេះវិជ្ជា និងប្រាជ្ញាស្មារតីឱ្យរីកចំរើន ដោយវិទ្យាសាស្ត្រ សិល្បៈ......។

**ឃ. តាមន័យស័ព្ទភាសាបារាំង**

*វប្បធម៌ : La Culture Est Le Travail De La Terre* គឺជាការងារ ដែលទាក់ទងទៅនឹងវិធីដាំដុះផ្សេងៗ *La Culture Est Le Travail De L'esprit* គឺជាការងារ ដែលទាក់ទងនឹងចិត្តគំនិត ស្មារតី វិជ្ជាផ្សេងៗ។ ទោះបីជាមានន័យច្រើនយ៉ាងនេះក៏ដោយ ក៏ន័យដើមរបស់វប្បធម៌បានក្លាយជាការសម្គាល់ធម៌ទាំងឡាយណា ដែលទ្រទ្រង់ បណ្ដុះបណ្ដាល ទាំងផ្លូវកាយ និងផ្លូវចិត្តឱ្យរីកចំរើនលូតលាស់ចេញជាផ្លែផ្កា។

សរុបមក យើងឃើញថាពាក្យវប្បធម៌ ត្រូវបានគេឱ្យនិយមន័យផ្សេងៗ ដែលមានលក្ខណៈដូចគ្នាត្រង់តម្លៃនៃការលូតលាស់ផ្នែកបញ្ញាស្មារតី និងការអប់រំ។

*ឧទាហរណ៍ :*

បសុវប្បកម្ម : ការបណ្ដុះបណ្ដាលខាងផ្នែកចិញ្ចឹមសត្វ

នេសាទវប្បកម្ម : ការបណ្ដុះបណ្ដាល ខាងផ្នែកនេសាទត្រី

រុក្ខវប្បកម្ម : ការបណ្ដុះបណ្ដាលខាងផ្នែកដាំដុះរុក្ខជាតិ

ប្រពលវប្បកម្ម : ការបណ្ដុះបណ្ដាលធ្វើឱ្យ មានទិន្នផលខ្ពស់។

**សេចក្ដីសន្និដ្ឋាន**

វប្បធម៌ គឺជាសញ្ញាណដ៏ទូលំទូលាយមួយ ក្ដោបក្ដាប់គ្រប់សកម្មភាពច្នៃប្រឌិតផ្នែកពលកម្មខួរក្បាល និងរូបរាងកាយរបស់មនុស្ស។

**II. មែកធាងនៃវប្បធម៌**

- ចំណេះដឹង
- ការផ្សព្វផ្សាយ
- ការអនុវត្ត

ការអភិវឌ្ឍខ្លួនចេញពីភាពជាសត្វរបស់ស្វាមនុស្ស ក៏ដោយសារមានការរីកចំរើនផ្នែកចំណេះដឹង និងបទពិសោធន៍ (ពលកម្មខួរក្បាល និងរូបរាងកាយ) មានកំរិតឈានឡើងពីទាបមកខ្ពស់ ពីភាពមិនទាន់សុក្រឹតមកភាពសុក្រឹតឡើងៗ ឥតឈប់ឈរទៅតាមរបកគំហើញរបស់មនុស្ស នៃដំណាក់កាលប្រវត្តិសាស្ត្រ។

ទន្ទឹមនឹងមានចំណេះដឹង បទពិសោធន៍ គេតែងតែផ្សព្វផ្សាយចែកចាយដល់គ្នាពីកន្លែងមួយទៅកន្លែងមួយ តាមរយៈសិល្បៈ អក្សរសាស្ត្រ អក្សរសិល្ប៍ ពត៌មាន......ជាបន្តបន្ទាប់ពីសម័យមួយទៅសម័យមួយ។

កាលណាមានចំណេះដឹង និងមានការផ្សព្វផ្សាយហើយ ពិតជាពុំទាន់គ្រាប់គ្រាន់ទេ គេត្រូវបង្កើតចេញនូវលទ្ធផលជាស្នាដៃលើការអនុវត្តថែមទៀត តាមរយៈឥរិយាបថ ដេក ដើរ ឈរ អង្គុយ និយាយស្ដីលើផ្នែកទំនៀមទំលាប់ប្រពៃណីការ សិក្សាអប់រំ និងច្បាប់ផ្សេងៗ។

*វប្បធម៌*

- ១. ចំណេះដឹង
  - ជំនឿ Croyance
  - សីលធម៌ Morale
  - សាសនា Religion
  - វិទ្យាសាស្ត្រ Science
- ២. ការផ្សព្វផ្សាយ
  - សិល្បៈ Arts
  - អក្សរសាស្ត្រ Lettres
  - អក្សរសិល្ប៍ Littérature
  - ពត៌មាន Information
- ៣. ការអនុវត្ត
  - ទំនៀមទំលាប់ប្រពៃណី Moeurs et Coutumes
  - ការសិក្សា Enseignement
  - ការអប់រំ Education
  - ច្បាប់ Droit

មែកធាងទាំងបី នៃវប្បធម៌ខាងលើនេះ ដែលសំរេចធ្វើឱ្យមនុស្សមានសុភមង្គល និងវឌ្ឍនភាពសមស្របទៅតាមសម័យកាល នៃដំណាក់កាលប្រវត្តិសាស្ត្រណាមួយ ប៉ុន្តែយើងអាចកត់សំគាល់បានថា មែកធាងខ្លះនៃវប្បធម៌ ត្រូវរលុបរលាយទៅវិញ ឬត្រូវរីកចំរើនតាមការវិវត្តរបស់សង្គមមនុស្ស។ វប្បធម៌របស់ជាតិមួយមានតម្លៃណាស់ ពុំអាចកាត់ថ្លៃបាន សម្រាប់ជាតិនីមួយៗ។ ដូចនេះ កាលណានិយាយពីវប្បធម៌របស់ជាតិមួយ ត្រូវនិយាយពីការគាំទ្រ និងការពេញចិត្តរបស់មហាជន នៃជនជាតិនោះ។

### III. ន័យនៃពាក្យសង្គមធម៌

ពាក្យសង្គម "*La Societé* " សំដៅយកធម្មជាតិមនុស្សដែលរស់នៅរួមគ្នា មានទីលំនៅ មានរបររកស៊ី មានរបៀបបែបបទរស់នៅទាក់ទងគ្នា ក្នុងស្រុកដែលជារដ្ឋ។

ឯពាក្យសង្គមធម៌ *Le Social* សម្គាល់ធម៌ទាំងឡាយណា ដែលជាធាតុ វិធី ធម្មភាព រៀបចំសង្គមមនុស្សឱ្យមានសភាពទម្រង់ និងលក្ខណៈចំរើនលូតលាស់ បានសេចក្ដីថា រៀបចំសង្គមឱ្យរស់នៅបានស្រួល ប្រកបដោយគ្រឿងសំភារៈគ្រប់គ្រាន់ និងមានសភាពល្អប្រសើរថែមទៀត។

រួមមក យើងបានដឹងថាអរិយធម៌មានវប្បធម៌ និងសង្គមធម៌ ជាមធ្យោបាយ វិធីសំដៅសំរេចនូវសុខៈ ក្នុងដំណើរទៅកាន់គោលដៅមួយ។

***តើវប្បធម៌ និងសង្គមធម៌មានឥទ្ធិពលទាក់ទងគ្នាបែបណាខ្លះ ?***

**ក. មែកធាងរបស់សង្គមធម៌**

***សង្គមធម៌***

- សង្គម សំភារៈ
  - ប្រដាប់ប្រដាប្រើប្រាស់
  - ប្រដាប់ Technique
  - មុខរបរ វិជ្ជាជីវៈ
- របបសង្គម (សង្គមវិធី)
  - សេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម
  - ពាណិជ្ជកម្ម
  - សង្គមកិច្ច សន្តិសុខ សុខមាលភាព
  - របបនយោបាយក្នុង និងក្រៅប្រទេស
- ទម្រង់សង្គម
  - ឋានៈសង្គម Classe Sociale
  - ស្ថាប័នរដ្ឋ Institution
  - រដ្ឋ ប្រជាជន Etat-nation កន្លងមក

យើងតែងតែឮគេនិយាយពាក្យជាប់គ្នាថា : វប្បធម៌ អរិយធម៌ ចំណែកឯពាក្យបារាំង ក៏គេនិយាយជាប់គ្នាដែរ *Culture et La Civilisation* ហេតុដូចម្តេចបានជាគេនិយាយយ៉ាងនេះ ក៏មិននិយាយត្រឹមតែអរិយធម៌ ពីព្រោះអរិយធម៌វា ក្តោបក្តាប់សង្គមធម៌ បញ្ហានេះមានយោបល់ប្លែកៗគ្នាជាច្រើន ÷

❖ ខ្លះគេយល់ថា គេត្រូវនិយាយវប្បធម៌ ពីព្រោះវាមានឥទ្ធិពលខ្លាំង សម្រាប់ទ្រទ្រង់អរិយធម៌ បើគ្មានវប្បធម៌ អរិយធម៌ក៏គ្មានដែរ ។ ដូចមានពាក្យមួយពោលថា ដើម្បីបានអរិយធម៌ ត្រូវតែបណ្តុះបណ្តាលវប្បធម៌សិន ។ម្យ៉ាងទៀត គេពន្យល់ថាមនុស្សទាំងឡាយពុំបានទទួលនូវការសិក្សា មនុស្សទាំងនោះពុំក្លាយទៅជាអរិយជនបានទេ " អរិយបុគ្គល " ។

❖ អ្នកខ្លះទៀតយល់ថា : គេអោចមើលឃើញវប្បធម៌របស់មនុស្សម្នាក់បានដោយងាយ ហើយក៏អាចមើលឃើញ នូវអរិយធម៌របស់ជនជាតិនីមួយៗបានដែរ ។ ដូចនេះ ការនិយមហៅ វប្បធម៌ តែងតែនៅមុខអរិយធម៌ជានិច្ច ។

*ហេតុអ្វីបានជាគេតែងតែនិយាយថា វប្បធម៌ អរិយធម៌ មិនដែលនិយាយថា សង្គមធម៌ អរិយធម៌ ?*

បានជាគេនិយាយថា វប្បធម៌ អរិយធម៌ ពាក្យវប្បធម៌ តែងតែនៅមុខពាក្យអរិយធម៌ជានិច្ច ពីព្រោះវប្បធម៌ សំដៅទៅលើមនុស្សម្នាក់ៗ ដែលធ្វើសកម្មភាពពលកម្ម និយាយស្តី ដេក ដើរ ឈរ អង្គុយ គេអាចវាយតម្លៃបានភ្លាមៗ ទៅលើអ្នក នោះថា មានកម្រិតវប្បធម៌ទាប ឬអ្នកនេះមានកម្រិតវប្បធម៌ខ្ពស់ ។

ចំណែកឯសង្គមធម៌វិញ គេពុំសូវនិយាយជាប់នឹងពាក្យអរិយធម៌ទេ ពីព្រោះសង្គមធម៌តែងតែស្ថិតនៅជាប់ក្នុងសង្គមមនុស្ស ហើយសង្គមធម៌ក៏មិនស្ថិតជាប់នៅនឹងមនុស្សម្នាក់ៗដែរ គេអាចស្គាល់សង្គមធម៌ នៃប្រជាជននីមួយនៅ ក្នុងសង្គមនីមួយៗបាន លុះត្រាតែឆ្លងកាត់ធ្វើការស្រាវជ្រាវលើឯកសារ និងពិនិត្យជាក់ស្តែងទៅលើសំភារៈសង្គម សង្គម វិធី និងទម្រង់សង្គម ។ ពោលគឺសំដៅទៅលើចង្កោមមនុស្ស ដែលមានទីលំនៅ មានមុខរបររកស៊ី មានជីវភាពទាក់ទងគ្នា ទៅវិញទៅមក ដែលមានការស្រាវជ្រាវត្រួតពិនិត្យទៅលើឯកសារផ្សេងៗ នៅតាមក្រសួង មន្ទីរ ស្ថាប័នរដ្ឋ ក្រុមហ៊ុន នានា អង្គការផ្សេងៗ ទើបអាចវាយតម្លៃថាសង្គមនេះ អន់ថយ ឬសង្គមនោះជឿនលឿនបាន ។

### ១. ទំនាក់ទំនងរវាងវប្បធម៌ និងសង្គមធម៌

មានមតិច្រើនយ៉ាងណាស់ ដែលឱ្យតម្លៃប្លែកៗគ្នាទៅលើវប្បធម៌ និងសង្គមធម៌ ÷

❖ *មតិទី ១ :* គឺតម្លៃអរិយធម៌ស្ថិតនៅលើវប្បធម៌ បានសេចក្តីថាចំណេះដឹង ការសិក្សាអប់រំ អក្សរសិល្ប៍ សាសនា អក្សរ អក្សរ ជាដើម ជាកម្លាំងវប្បធម៌ អាចកែប្រែសង្គមមនុស្សឱ្យមានតម្លៃកម្រិតជីវភាពខ្ពង់ខ្ពស់ ។

❖ *មតិទី ២ :* កម្លាំងអរិយធម៌ស្ថិតនៅលើសង្គមធម៌ ពោលគឺសង្គមធម៌ជាបុព្វហេតុនៃការជឿនលឿន ពីព្រោះសង្គមធម៌ អាចកែប្រែផ្លាស់ប្តូរជីវភាពទាំងទស្សនៈ ចិត្តគំនិត ចំណង់ចំណូលចិត្តរបស់មនុស្ស ឱ្យមានការរីកចំរើនយ៉ាងណាមិញ ប្រដាប់ប្រដារប្រើប្រាស់គ្រប់បែបយ៉ាង ដែលមនុស្សម្នាក់ៗប្រើប្រាស់ ឬរបៀបបង្កបង្កើនផល និងចែកចាយផល ឬច្បាប់ គ្រប់គ្រងសង្គម របៀបរៀបចំសង្គមក៏អាចបញ្ជាក់ឱ្យឃើញតម្លៃ នៃការរីកចំរើនដែរ ។ រួមសេចក្តីមកទស្សនៈទាំងពីរ ខាង លើនេះ ខុសគ្នាខ្លះ ត្រូវគ្នាខ្លះ ពីព្រោះជួនកាលកម្លាំងអរិយធម៌ស្ថិតនៅលើវប្បធម៌ ជួនកាលស្ថិត

នៅលើសង្គមធមិ ពុំមែនស្ថិតនៅដាច់តែឯកឯងនោះទេ។ បើនិយាយឱ្យងាយស្តាប់ គឺត្រូវទាក់ទងគ្នាជានិច្ច។ យ៉ាងណាមិញ សង្គមធមិ ដែលលូតលាស់ទៅកើត អាស្រ័យលើវប្បធមិនេះឯង ដូចជាគ្រឿងប្រដាប់ប្រើប្រាស់ផ្សេងៗ ដែលអាច ផលិតទៅកើត
លុះត្រាតែមានចំណេះដឹងប្រកបដោយបច្ចេកទេស វិទ្យាសាស្ត្រគ្រប់គ្រាន់ ទើបសំភារៈប្រដាប់ប្រដារប្រើ ប្រាស់នោះអាចសំរេចទៅបាន។

សង្ខេបសេចក្តីមកឃើញថា អរិយធមិអាចដុះដាលរីកចំរើនលូតលាស់ទៅបាន អាស្រ័យទៅលើវប្បធមិ និង សង្គមធមិ ដែលទាក់ទង និងពាក់ព័ន្ធគ្នាទៅវិញទៅមកជាចាំបាច់។

**IV. អត្ថន័យ នៃពាក្យអរិយធម៌**

**ក. អរិយធម៌ជាអ្វី ?**

អរិយធមិ > អរិយ + ធមិ

អរិយៈ សុភាព ស្លូតត្រង់ ត្រឹមត្រូវ ល្អប្រសើរ

អាឃិ : បែបបទល្អ - អារ្យ : ថ្លៃថ្នូរ ខ្ពង់ខ្ពស់

អរិយធមិមានអត្ថន័យច្រើនយ៉ាង ÷:

*ទី ១ :* តាមវចនានុក្រមខ្មែរ ភាគ ២ បានពន្យល់ថា អរិយធមិ គឺជាអ្វីៗ ដែលនាំមកនូវសេចក្តីសុខចំរើន ឬ បែបបទសណ្តាប់ធ្នាប់ របៀបរៀបរយល្អ។

*ទី ២ :* តាម La rousse ស.វទី ២០ ថា អរិយធមិ គឺជារបៀបរៀបរយផ្សេងៗនៃការរីកចំរើនខាងផ្នែកចំណេះ ដឹង សីលធមិ ឧស្សាហកម្ម នៃសង្គមមនុស្ស។

*ទី ៣ :* តាមលោក La Lande គ.ស " ១៧៣២-១៨០៧ " ជាតារាវិទូជនជាតិបារាំងថា អរិយធមិ គឺជាមែកធាងច្រើនបែបច្រើនយ៉ាង នៅក្នុងសង្គមមនុស្ស ដែលមានលក្ខណៈសិល្បៈ សាសនា តិចនិក ជាជីវិតបន្តគ្នាក្នុងកាល អាកាស។

*ទី ៤ :* តាមលោក Mirabeau " ១៧១៥-១៧៨៩ " ជនជាតិបារាំងថា អរិយធមិ គឺជាការរីកចំរើនលូតលាស់ នៃជនជាតិ ដែលមានភាពផ្ទុយគ្នានឹងភាពព្រៃផ្សៃ។

*ទី ៥ :* តាមលោក Wibeur "១៨៦៤-១៩២០ " ជនជាតិអាល្លឺម៉ង់ថា អរិយធមិ គឺជាកម្រងវិជ្ជាតិចនិចវិជ្ជាវិវត្ត គោលច្បាប់ សំរាប់ជាមធ្យោបាយទប់ទល់នឹងធម្មជាតិ។

*ទី ៦ :* តាមលលោក ***កាលម៉ាក្ស*** " ១៨១៨-១៨៨៣ " ថា អរិយធមិ គឺជាតម្លៃខាងសំភារៈ។

តាមទស្សនៈខាងលើ ទោះបីមានអត្ថន័យប្លែកៗគ្នាក៏ដោយ ប៉ុន្តែអត្ថន័យនីមួយៗប្រហាក់ប្រហែលគ្នា គឺជាការឱ្យតម្លៃទៅលើការរីកចំរើនរបស់សង្គមមនុស្សទាំងផ្នែកស្មារតី និងសំភារៈ។

*ពួកអារ្យ ជានរណា ?*

នៅសតវត្សទី ១៥ មុនគ.ស ជនជាតិអារ្យ (*Aryen*) ដែលស្ថិតនៅក្នុង *Empire Perse* នៅតំបន់ *Cocace* លើខ្ពង់រាប *Pamir* បានវាយប្រហារទៅលើជនជាតិដើម គឺពួក *Dravidien* នៅប្រទេសឥណ្ឌា។ ក្រោយមក បានទទួលជ័យជំនះលើពួក *Aryen* បានតាំងខ្លួនជាអ្នកគ្រាន់បើខ្ពង់ខ្ពស់ ហើយបានចាត់ទុកជាជនជាតិដែលខ្លួនវាយឈ្នះនោះ ថាខ្វះការរីកចំរើន ឬអ្នកអន់ថយ។ ដូចនេះ គេឱ្យយកពួកអារ្យ នេះសម្គាល់ថា រុងរឿងខ្ពង់ខ្ពស់ជាងគេ។

*ហេតុដូចម្តេចបានជាគេនិយាយថា វប្បធម៌ឥណ្ឌាជាប្រភពដ៏សំខាន់ក្នុងការបង្កើតវប្បធម៌ខ្មែរ ?*

វប្បធម៌ឥណ្ឌាជាប្រភពដ៏សំខាន់ ក្នុងការបង្កើតវប្បធម៌ខ្មែរ ព្រោះថា នៅក្នុងវប្បធម៌ខ្មែរ គេសង្កេតឃើញមានវប្បធម៌ឥណ្ឌាជាច្រើនដូចជា ភាសា អក្សរ អក្សរសិល្ប៍ សិល្បៈ សាសនា (ព្រះពុទ្ធសាសនា និងព្រាហ្មណ៍សាសនា) ចម្លាក់ សំណង់ប្រាសាទ ទំនៀមទំលាប់ប្រពៃណី ការគ្រប់គ្រង (របបរាជាធិបតេយ្យ)។ ប៉ុន្តែវប្បធម៌ឥណ្ឌាពុំមានប្រភពកំណើត ក្នុងការបង្កើតវប្បធម៌ខ្មែរនោះឡើយ ពីព្រោះថាជនជាតិខ្មែរមានកំណើត និងមានវប្បធម៌ដើមរបស់ខ្លួនរួចជាស្រេចហើយ មុនពេលអរិយធម៌ឥណ្ឌាចូលមក។ ខ្មែរបានក្រឡៃ ច្នៃប្រឌិតវប្បធម៌បរទេសឱ្យមកជារបស់ខ្មែរ។

រួមសេចក្តីមកគំនិតដែលថា វប្បធម៌ឥណ្ឌាជាប្រភពដ៏សំខាន់ក្នុងការបង្កើតវប្បធម៌ខ្មែរនោះ គឺជាការភន្តច្រឡំ។ ត្រូវនិយាយថា វប្បធម៌ឥណ្ឌាបានជះឥទ្ធិពលលើវប្បធម៌ខ្មែរ។

### ខ. មែកធាងនៃអរិយធម៌

***អរិយធម៌***

- វប្បធម៌
  - ចំណេះដឹង
    - ជំនឿ
    - សាសនា
    - វិទ្យាសាស្ត្រ
  - កំណត់ផ្សាយ
    - ភាសា អក្សរ
    - សញ្ញា
    - អក្សរសាស្ត្រ អក្សរសិល្ប៍
    - សិល្បៈ ពតិមាន
    - វិទ្យុ ទូរទស្សន៍
  - អនុវត្ត
    - ទំនៀមទំលាប់ "ប្រពៃណី"
    - ការសិក្សា ការអប់រំប្រដៅទូន្មាន " ច្បាប់ "
    - កីឡា ល្បែងកំសាន្តផ្សេងៗ
- សង្គមធម៌
  - គ្រឿងសង្គម
    - ប្រដាប់រស់នៅ "លំនៅ ចំណីអាហារ សំលៀកបំពាក់"
    - ប្រដាប់តិចនិច "ម៉ាស៊ីនចំណង់ បង្កបង្កើនផល ធ្វើដំណើ
    - មុខរបរ "វិជ្ជាជីវៈ"
  - សង្គមវិធី
    - សេដ្ឋកិច្ច កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម
    - សង្គមកិច្ច សុខាភិបាល សន្តិសុខ ការងារ

- នយោបាយ របៀបរបប ច្បាប់គ្រប់គ្រង ច្បាប់រដ្ឋ

- ទម្រង់សង្គម
  - ស្នូលសង្គម " គ្រួសារ "
  - វណ្ណៈសង្គម " វណ្ណៈជាតិកំណើត វណ្ណៈការងារ វណ្ណៈចំណេះវិជ្ជា អង្គការសង្គម " ស្ថាប័នផ្សេងៗ នយោបាយ វប្បធម៌

*ហេតុអ្វីបានជាខ្មែរត្រូវចេះអរិយធម៌ខ្មែរ ? តើការចេះអរិយធម៌ខ្មែរជាការគ្រប់គ្រាន់ហើយឬនៅ ?*

បានជាខ្មែរត្រូវចេះអរិយធម៌ខ្មែរ ព្រោះ ÷

អរិយធម៌ខ្មែរជាមូលដ្ឋានគ្រឹះ សំរាប់សង្គមខ្មែរ។ មនុស្សខ្មែរ ត្រូវតែយល់ឱ្យបានច្បាស់អំពីអ្វី ដែលខ្លួនមាន ដែលល្អ ហើយគេទទួលស្គាល់ គេស្រឡាញ់ចូលចិត្តតាំងពីបុរាណកាលមក។ កូនខ្មែរ ត្រូវតែបណ្តុះមនោសញ្ចេតនា ស្រឡាញ់ និងការពារវប្បធម៌ អរិយធម៌របស់ខ្លួន ដោយផ្សព្វផ្សាយ និងពង្រីកពង្រឹងបន្ថែម។

ការស្គាល់វប្បធម៌ អរិយធម៌របស់ខ្លួនឱ្យបានច្បាស់នេះ ដើម្បីប្រៀបធៀបវប្បធម៌ អរិយធម៌បរទេស រួចរកចំណុចខ្លាំង និងចំណុចខ្សោយ។ ការចេះអរិយធម៌ខ្មែរ ពិតជាពុំទាន់គ្រប់គ្រាន់នៅឡើយទេ យើងត្រូវស្វែងយល់នូវវប្បធម៌ អរិយធម៌បរទេសបន្ថែមទៀត ដោយត្រូវជ្រើសរើសយកអ្វីដែលល្អ ដើម្បីកែច្នៃឱ្យមកជារបស់ខ្លួន សមស្របតាមចំណង់ចំណូលចិត្តរបស់ប្រជាជាតិខ្លួន (ជាតូបនីយកម្ម) បន្ថែមទៀត ប៉ុន្តែមិនត្រូវមើលស្រាល ដល់វប្បធម៌ អរិយធម៌បរទេសឡើយ។

**V. ធាតុសំខាន់ៗ ដែលសំរេចឱ្យកើតមានវប្បធម៌ អរិយធម៌របស់ជនជាតិមួយ**

ម្នាក់ៗ តែងតែចោទសួរថា តើវប្បធម៌ អរិយធម៌មកពីណា? បញ្ហានេះមានយោបល់ជាច្រើន ដែលបានឆ្លើយនឹងសំនួរនេះ ÷

✡ ខ្លះយល់ថា អរិយធម៌របស់ជនជាតិនីមួយៗ កើតឡើងដោយឯកឯង គឺវាស្ថិតនៅជាប់នឹងមនុស្សម្នាក់របស់ជនជាតិនោះ ពុំមាននរណាបង្កើតវាទេ។

✡ អ្នកខ្លះទៀតយល់ថា វប្បធម៌កើតឡើងដោយអាទិទេពជាអ្នកកំណត់ គឺព្រហ្មលិខិតរបស់មនុស្សម្នាក់ៗ កើតឡើងដោយសារអាទិទេព ពីព្រោះអាទិទេពជាអ្នកបង្កើត និងបំផ្លាញលោក។ យើងដឹងហើយថានៅក្នុងលោកនេះ ពុំមានអាទិទេពណាមួយ ឬបុគ្គលណាមួយបង្កើតអ្វីមួយឱ្យមហាជនគេនិយមពេញចិត្តនោះទេ ។ វប្បធម៌ ត្រូវបង្កើតឡើងដោយប្រជាជនខ្លួនឯង ទើបគេពេញចិត្ត។

*ឧទាហរណ៍ :* រាំវង់ រាំក្បាច់ សុទ្ធតែជារបាំរបស់ប្រជាជន។ យើងដឹងហើយថា មនុស្សជាអ្នកកសាងប្រវត្តិសាស្ត្រ ពុំមែនអាទិទេពជាអ្នកកសាងប្រវត្តិសាស្ត្រនោះទេ ហើយក៏ពុំមែនអាទិទេពជាអ្នកបង្កើតមនុស្សដែរ។ តាមន័យវប្បធម៌ ជាសញ្ញាណទូលំទូលាយក្តោបក្តាប់គ្រប់តម្លៃច្នៃប្រឌិតទាំងកាយពលកម្ម និងបញ្ញាពលកម្មទៅនឹងបាតុភូតផ្សេងៗ នៃធម្មជាតិ។

*តើធាតុសំខាន់ៗ ដែលជះឥទ្ធិពលដល់ការបង្កើតវប្បធម៌ អរិយធម៌របស់ជាតិនីមួយៗមានអ្វីខ្លះ ?*

យើងរកឃើញធាតុសំខាន់ៗ ដែលសំរេចវប្បធម៌ អរិយធម៌របស់ជាតិមួយគឺ ÷

**ក. កត្តាពលកម្ម**

ពលកម្ម គឺជាសកម្មភាពដែលមានបំណង ពលកម្មសម្រេចអ្វីៗទាំងអស់ដែលមនុស្សបានធ្វើ។ អ្វីៗ ដែលមនុស្សទទួលបាន ក៏ដោយសារពលកម្ម។ ស្វាមនុស្ស ដែលក្លាយមកជាមនុស្ស ក៏ដោយសារពលកម្ម គឺបានឆ្លងកាត់ពីដំណាក់កាលនីមួយៗ ធ្វើឱ្យមនុស្សមានប្រាជ្ញា ចេះកសាង និងច្នៃប្រឌិតសំភារៈផ្សេងៗ។ ដូច្នេះ ពលកម្មជាធាតុមួយដែលសម្រេចឱ្យបង្កើតវប្បធម៌។

*ឧទាហរណ៍ :* ប្រាសាទអង្គរវត្ត ក៏ជាស្នាដៃរបស់ប្រជាជន កើតឡើងដោយសារការធ្វើពលកម្មយ៉ាងខ្លាំងក្លាបំផុត។ ប្រាសាទនោះ តំណាងឱ្យចំណេះដឹងដ៏ខ្ពង់ខ្ពស់របស់ប្រជាជនខ្មែរ ទើបគេនិយាយថាប្រាសាទអង្គរវត្តជាដួងព្រលឹងរបស់ប្រជាជាតិខ្មែរ។ សិល្បៈមួយចំនួន មហាជនគេបានយកការងារពលកម្ម ដែលបានធ្វើប្រចាំថ្ងៃមកសម្តែងសិល្បៈទាំងនោះ ក៏តំណាងនូវការងារពលកម្មរបស់មហាជនដែរ។ ពលកម្មតែងតែឆ្ពោះទៅរកភាពសុក្រឹត ស្របទៅតាមការរីកចម្រើន នៃប្រវត្តិសាស្ត្រ។ ដូចនេះ វប្បធម៌ក៏រីកចំរើនទៅតាមប្រវត្តិសាស្ត្រដែរ។

**ខ. កត្តាភូមិសាស្ត្រ**

ដើម្បីរស់រានមានជីវិត មនុស្សតែងតែត្រូវការចាំបាច់នូវធម្មជាតិ ហើយទំនាញផលពីធម្មជាតិនោះ ដើម្បីយកផលមកបំរើសេចក្តីត្រូវការរបស់ខ្លួន ។ ដូចនេះ លក្ខណៈធម្មជាតិ ភូមិសាស្ត្រ ទឹកដី ព្រៃភ្នំ បឹងបួរ អាកាសធាតុសុទ្ធតែជះឥទ្ធិពលមកលើមនុស្ស ធ្វើឱ្យមនុស្សងាយស្រួល ឬលំបាកក្នុងការងារពលកម្ម។

*ឧទាហរណ៍ :* នៅប្រទេសក្តៅជីវភាពរស់នៅ និងទំនៀមទំលាប់ប្រពៃណីរបស់ប្រជាជនគេ ខុសប្លែកពីជីវិតរស់នៅរបស់ប្រជាជននៅប្រទេសត្រជាក់។

**គ. កត្តារបបសង្គម**

របបសង្គមនាំឱ្យមានឥទ្ធិពល និងបង្កើតឡើងនូវវប្បធម៌ អរិយធម៌របស់ជាតិមួយ ក្នុងដំណាក់កាលណាមួយនៃប្រវត្តិសាស្ត្រ។ ការរីកចំរើននៃរបបសង្គម វាផ្លាស់ប្តូរសមស្របទៅតាមបែបផែនផលិតកម្ម។ បើនរណាក្តាប់មធ្យោបាយផលិតកម្ម និងជាអ្នកក្តោបក្តាប់ស្មារតីថែមទៀត គឺអ្នកនោះមានសិទ្ធិបែងចែកភោគផលផលិតកម្មនោះ។ អ្វីៗទាំងអស់នៅក្នុងសង្គមមួយ តែងតែបម្រើឱ្យរបបសង្គម និងវណ្ណៈជាអ្នកក្តោបក្តាប់ក្នុងសង្គមនោះ។ វប្បធម៌ អរិយធម៌ ដែលជាមនសិការសង្គម នៃរចនាសម្ព័ន្ធជាន់ខ្ពស់ ត្រូវតែបម្រើ និងជួយពង្រឹងវណ្ណៈគ្រប់គ្រងក្នុងសង្គមនោះផងដែរ។ ដូចនេះ យើងអាចបញ្ជាក់វប្បធម៌ អរិយធម៌របស់ជនជាតិមួយ ប្រកាន់នូវលក្ខណៈជាចរិតវណ្ណៈរបស់ជាតិនោះ។ ម្យ៉ាងវិញទៀត យើងអាចបញ្ជាក់ថាវប្បធម៌ អរិយធម៌របស់ជនជាតិនីមួយៗ ពុំអាចនៅស្ថិតស្ថេរនឹងថ្កល់ពុំរីកចំរើននោះទេ។ ទោះបីជាវប្បធម៌ អរិយធម៌របស់ជាតិមួយបានរីកចំរើនឡើងផ្លាស់ប្តូរចរិត និងលក្ខណៈក៏ដោយ ក៏លក្ខណៈនៅស្ថិតស្ថេរគឺលក្ខណៈជាតិរបស់គេ។

**ឃ. កត្តាសាសនា**

សាសនាអប់រំទូន្មានប្រៀនប្រដៅ ឬបណ្ដាំផ្ញើ នៅក្នុងប្រទេសកម្ពុជាយើង សាសនាមានច្រើន ដែលមានកំណើតនៅក្នុងសតវត្សទី ៦ មុនគ.ស។ សាសនាទាំងនោះ រួមមាន ÷

- ព្រហ្មញ្ញសាសនា ឬសាសនាព្រាហ្មណ៍មានកំណើតមកពីប្រទេសឥណ្ឌា
- ពុទ្ធសាសនា ឬសាសនាព្រះពុទ្ធមានកំណើតមកពីប្រទេសឥណ្ឌា
- គ្រីស្ដសាសនា មានកំណើតមកពីប្រទេសស៊ីរី
- អ៊ីស្លាមសាសនា មានកំណើតមកពីប្រទេសអារ៉ាប់
- សាសនាតៅ មានកំណើតមកពីប្រទេសចិន
- សាសនាស៊ិនតូ មានកំណើតមកពីប្រទេសជប៉ុន

## VI. ទំនាក់ទំនងអរិយធម៌ខ្មែរ និងអរិយធម៌បរទេស

### ✡ មូលធម៌អរិយធម៌ខ្មែរ_មន "មុនគ.ស "

នៅលើសកលលោកនេះ ពុំដែលមានជាតិសាសន៍ណាមួយ ដែលមានលក្ខណៈសុទ្ធសាធ គ្មានល្បាយសាសន៍នៃអរិយធម៌បរទេសនោះឡើយ ។ លើកលែងតែជាតិសាសន៍នោះ ស្ថិតនៅឆ្ងាយដាច់តែឯកឯងពីគេ គ្មានទំនាក់ទំនងនឹងប្រទេសដទៃ។ ការប៉ះទង្គិចរវាងជាតិសាសន៍មួយទៅនឹងជាតិសាសន៍ផ្សេងៗទៀត រមែងទទួលឥទ្ធិពលទៅវិញទៅមកជាដរាប។ បើយើងក្រឡេកមកប្រទេសកម្ពុជាយើងវិញ នោះយើងឃើញថាជនជាតិខ្មែរ ដែលធ្លាប់តែមានអរិយធម៌ល្បីល្បាញ តាំងពីយូរណាស់មកហើយ ក៏មានទទួលនូវឥទ្ធិពលអរិយធម៌បរទេសជាច្រើនដែរ។

*តើខ្មែរទាក់ទងជាមួយជនជាតិណាខ្លះ? ហើយទទួលឥទ្ធិពលអ្វីខ្លះ ?*

យើងដឹងហើយថា កាលដើមឡើយ ខ្មែរយើងជឿលើព្រលឹងអារក្សអ្នកតា លើសពីនេះទៅទៀតនៅសម័យដើម គេចាត់ទុកស្ត្រីជាធំ (របបមាតាធិបតេយ្យ)។ ពេលធ្វើស្រែ គេនិយមបាចទឹកបញ្ចូលស្រែ។ ជនជាតិខ្មែរមុនគ.ស បានចេះផ្សាំងសត្វខ្លះហើយ។ ពួកគេមានទំនាក់ទំនងទំនៀមទំលាប់ពិសេសមួយទៀត គឺនៅពេលមានមនុស្សស្លាប់ គេយកទៅកប់នៅក្រោមថ្មដុល ឬដាក់ក្នុងក្រឡ។ ចំពោះភាសានិយាយវិញ ពុំសូវដូចភាសារបស់ជាតិសាសន៍ដទៃឡើយ ពីព្រោះភាសាខ្មែរមានអន្តរបទ ឬផ្នត់ដែក។

ទាំងអស់ខាងលើនេះ គឺជាមូលធម៌ខ្មែរមនមុនគ.ស ពុំទាន់មានទំនាក់ទំនងជាមួយនឹងបរទេស។

### ✡ ឥទ្ធិពលឥណ្ឌា " សតវត្សទី ១ "

លុះមកដល់សតវត្សទី ១  ឥទ្ធិពលបរទេស ដែលបានចូលមកដល់ស្រុកខ្មែរយើងមុនគេ  គឺឥទ្ធិពលឥណ្ឌា។ គឺនៅពេលនោះហើយ ដែលខ្មែរយើងបានពើបប្រទះនឹងទស្សនៈរាជាធិបតេយ្យ  ភាសា  អក្សរ  អក្សរសិល្ប៍  ទំនៀម










ទំលាប់  ជំនឿសាសនា  និងច្បាប់ផ្សេងៗ ( ដោយព្រះនាង **លីវយី**  ទទួលបរាជ័យជាមួយទ័ពរបស់ព្រះបាទ  **ហ៊ុន ទៀន** ( **កៅណ្ឌិន្យ** ) ទើបរៀបអភិសេក  រួចបានឡើងធ្វើជាស្តេចសោយរាជ្យនៅពេលនោះ ) ។  ជាមួយគ្នានោះដែរ  ព្រះបាទ **អសោកៈមហារាជ** ដែលបានបញ្ជូនសាមណទូតពីរព្រះអង្គ គឺ **សោណត្ថេរ**  និង **ឧត្តរត្ថេរ**  ក្នុងកំឡុងសតវត្សទី ២  ដើម្បី ផ្សព្វផ្សាយអំពីសាសនា។

✡ ឥទ្ធិពលចិន "សតវត្សទី ៣ "

បន្ទាប់ពីឥទ្ធិពលឥណ្ឌាមក មានឥទ្ធិពលចិន ដែលបានជ្រៀតចូលយ៉ាងក្លាំងក្លានៅសតវត្សទី៣។ ចិនបានចេញចូលទាក់ទងខាងផ្នែកជំនួញ ដែលជាហេតុធ្វើឱ្យជនជាតិខ្មែរយើងចេះធ្វើជំនួញ មិនតែប៉ុណ្ណោះពួកចិន ដែលបានចូលមកដល់ស្រុកខ្មែរហើយ បានរៀបការជាមួយស្ត្រីខ្មែរក្នុងគោលបំណងឱ្យមានភាពងាយស្រួល ក្នុងមុខរបរប្រកបជំនួញ។ លើសពីនេះទៅទៀត ពួកចិនបានបញ្ចូលមកជាមួយនូវ សិល្បៈ ល្ខោនហ៊ី និងភាសា.....។ ដែលយើងឃើញនៅមានសេសសល់ រហូតមកដល់សព្វថ្ងៃនេះ។

✡ ឥទ្ធិពលចាម ជ្វា " សតវត្សទី ៥ "

មកដល់សតវត្សទី ៥ ទើបមានឥទ្ធិពលចាម-ជ្វា ដែលនៅក្នុងនោះ យើងឃើញមានការរីកចំរើនខាងស្ថាបត្យកម្ម " សំណង់ប្រាសាទភ្នំ និងក្បាច់លំអផ្សេងៗ "

✡ ឥទ្ធិពលថៃ វៀតណាម " សតវត្សទី ១៣ "

លុះមកដល់សតវត្សទី ១៣ ទើបមានឥទ្ធិពលថៃ វៀតណាមមកដល់ដែរ។ នៅពេលនោះហើយ ដែលខ្មែរយើងសំបូរពាក្យពេចន៍និយាយ ពិសេស គឺការខ្ចីគ្នាទៅវិញទៅមកក្នុងឋានៈជាប្រទេសជិតខាង។

✡ ឥទ្ធិពលអឺរ៉ុប "សតវត្សទី ១៦ "

**ក. ទំនាក់ទំនងខ្មែរ-ឥណ្ឌា**

ជាទំនាក់ទំនងដែលមានចំណាស់ជាគេ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល លើកលែងតែប្រទេសវៀតណាម និងប្រទេសហ្វីលីពីនចេញ ព្រោះតាមការស្រាវជ្រាវគេបានរកឃើញវត្ថុជាច្រើនមកពីឥណ្ឌាដូចជា ត្រាឆ្លាក់អក្សរសិរិទ្ធនៅអូរកែវ នៅម៉ាលេស៊ា និងព្រះពុទ្ធរូបនៅកោះសេឡែប។ ឥណ្ឌាចូលមកប្រទេសខ្មែរ ដំបូងតាមរយៈ ÷

- ឈ្នួញសំពៅអ្នកលក់ដូរ
- តាមរយៈអ្នកដឹកនាំខ្មែរ សិក្សារៀនសូត្រមន្តអាគមពីឥណ្ឌា
- តាមរយៈគ្រួសារខ្មែរ យកប្តីប្រពន្ធឥណ្ឌា។

ដំណើររបស់ជនជាតិឥណ្ឌាមកកាន់ប្រទេសខ្មែរយើង មានគោលបំណងធ្វើពាណិជ្ជកម្ម និងបញ្ជាផ្សព្វផ្សាយសាសនា ដោយគេយល់ថា នៅភូមិភាគនេះ សំបូរទៅដោយមាស និងគ្រឿងទេសមានឈើក្រអូបជាដើម។

តាមឯកសាររបស់លោក **ត្រឹង ងា** ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ មុនឆ្នាំ ១៩៧៥ បានឱ្យយោបល់ថា ការធ្វើដំណើរមកដល់ នៃជនជាតិឥណ្ឌាមានកត្តា ៣ គឺ ÷

***១ -*** ការរីកចំរើនផ្នែកនាវាចរណ៍របស់ឥណ្ឌា ពីព្រោះគេអាចធ្វើសំពៅធំៗផ្ទុកមនុស្សបានចំនួនពី ៦០០-៧០០ នាក់ និងការរកឃើញនៃការផ្លាស់ប្តូរខ្យល់រដូវ ដែលសរសេរដោយលោក **ហ៊ី ប៉ាឡូស** នៅក្នុងសតវត្សទី ១ នៃគ.ស ដែលជាហេតុនាំឱ្យវិស័យជំនួញរវាងប្រទេសឥណ្ឌា និងកំពង់ផែទាំងឡាយនៅតាមឆ្នេរសមុទ្រក្របាមមានភាពងាយស្រួល។

***២ -*** ដោយសាសនាបានលុបចោលនូវប្រព័ន្ធវណ្ណៈ បណ្តាលឱ្យពួកឥណ្ឌាឈប់ខ្លាចបាត់បង់ភាពបរិសុទ្ធខាងជាតិសាសន៍ក្នុងទំនាក់ទំនងជាមួយជនជាតិដទៃ។

**៣ -** គេសង្កេតឃើញការរីកធំធាត់ផ្សារជំនួញចិន ក្រោយពេលដែលជនជាតិនេះបានវាយលុកយកបានតំបន់មួយចំនួននៅភាគខាងត្បូង នៃទន្លេយ៉ង់សេ ។

សរុបមកតាមលោក **ហ្សកហ្សេរ៉ង់** បានធ្វើសមតិកម្មចំពោះការមកដល់នៃជនជាតិឥណ្ឌានៅភូមិភាគអាស៊ីអាគ្នេយ៍ថា ពួកចំណូលថ្មី " ឥណ្ឌា " បានមកទាក់ទងជាមួយមេដឹកនាំ តាមរយៈការព្យាបាលជម្ងឺ ការផ្តល់នូវយ័ន្តគាថា ព្រមទាំងបានរៀបការជាមួយនឹងកូនស្រីរបស់ពួកមេដឹកនាំ ដែលជាមូលហេតុនាំឱ្យឥណ្ឌាមានលទ្ធភាពផ្សព្វផ្សាយអរិយធម៌របស់ខ្លួនដោយជោគជ័យ ។

**ខ. ទំនាក់ទំនងខ្មែរ-ចិន**

តាមប្រវត្តិសាស្ត្របានបញ្ជាក់ថា នៅសតវត្សទី ៣ នៃគ.ស មានជនជាតិចិនពីរនាក់បានមកធ្វើទស្សនកិច្ចនៅនគរភ្នំ គឺលោក **កាំង ថៃ** និងលោក **ជូ យីង** ទើបសម័យក្រោយៗមក ( សម័យចេនឡា សម័យអង្គរមានទំនាក់ទំនងជាហូរហែរ ) ។ ជាពិសេសមកដល់សតវត្សទី ១៨ និងទី ១៩ ជនជាតិចិនមកកាន់ប្រទេសខ្មែរយើងកាន់តែច្រើនឡើងៗ ដោយសារស្រុករបស់គេកើតមានបញ្ហាអសន្តិសុខ ដែលជាហេតុធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងទំនៀមទំលាប់ប្រពៃណី សិល្បៈ ភាសា មានល្បាយសាសន៍ ។ *ឧទាហរណ៍ :* តៅហួ យិនឆាយ ចែ សោ ឆារឆៅ ចាប់ឆាយ និងរបៀបរបបធ្វើជំនួញ លក់ ទិញ ថ្លឹង គិតលេខតាមក្បួន ( ក្បាច់ ) សព្វសារពើរ ។

**គ. ទំនាក់ទំនងខ្មែរ-ចាម ជ្វា**

នៅក្នុងវប្បធម៌ខ្មែរ គេសង្កេតឃើញឥទ្ធិពលចាម-ជ្វា ផ្នែកស្ថាបត្យកម្មដូចជា ក្បាច់លម្អ រូបរាហុ និងការកសាងប្រាសាទភ្នំ ដែលយើងទទួលឥទ្ធិពលពីឥណ្ឌាផង ប៉ុន្តែឥទ្ធិពលនេះ ត្រូវបានព្រះបាទជ័យវរ្ម័នទី ២ ប្រកាសឈប់ទទួលសិទ្ធិគ្រប់បែបយ៉ាងរបស់ចាម-ជ្វា រាប់ទាំងវប្បធម៌ផងដែរ ។

**ឃ. ទំនាក់ទំនងខ្មែរ-ថៃ**

យើងដឹងហើយថា កាលដើមឡើយជនជាតិថៃជាជនជាតិភាគតិចនៅខេត្តយូណាន នៃប្រទេសចិន ប៉ុន្តែក្រោយមកមានបញ្ហាជនជាតិម៉ុងហ្គោល និង ចិន បណ្តាលឱ្យជនជាតិថៃនាំគ្នាធ្វើដំណើរមកទិសខាងត្បូងតាមដងទន្លេមេណាម រួចបានក្លាយទៅជាជនជាតិភាគតិចនៅក្នុងទឹកដីខ្មែរ ។

មកដល់ឆ្នាំប្រមាណជា ១២២០ ជនជាតិភាគតិចថៃមានការរីកចំរើននៅត្រង់វាលទំនាប នៃទន្លេមេណាម ធ្វើឱ្យមានការប៉ះទង្គិចរវាងចៅហ្វាយខេត្តខ្មែរ ជាមួយមេដឹកនាំថៃ បណ្តាលឱ្យចៅហ្វាយខេត្តខ្មែរភៀសខ្លួនចេញពីសុខោទ័យ រួចមេដឹកនាមថៃម្នាក់នាមថា **ឥន្ទ្របតីន្ទ្រាទិត្យ** ឡើងសោយរាជនៅទីនោះ ។ ចាប់ពីពេលនោះមក ជនជាតិថៃបានពង្រីង និងពង្រីកអនុភាពរបស់ខ្លួនបន្តិចម្តងៗ រហូតហ៊ានចេញប្រឆាំងនឹងជាជាតិខ្មែរដោយចេញមុខ ដើម្បីពង្រីកទឹកដី ពិសេសនៅសម័យអង្គរ ជនជាតិថៃបានវាយបំបែកក្រុងអង្គរដល់ទៅពីរលើក ÷

ក្នុងរាជ្យព្រះរាជាខ្មែរ " **លំពង្សរាជា** " ១៣៤៦ - ១៣៥១ ស្តេចសៀមនាម **រាមាធិបតី** ដែលតាំងរាជធានីនៅក្រុងអាយុធ្យាបានលើកទ័ពចូលមកវាយខ្មែរ ប៉ុន្តែត្រូវបានព្រះរាជឧបរាជខ្មែរ គឺព្រះបាទ **សុរិយោទ័យ** ត្រូវជា

អានុជរបស់ ព្រះបាទ **លំពង្សរាជា** វាយទប់ស្ទាត់ទាន់ពេលវេលា។ ជាមួយគ្នានោះ ព្រះរាជាខ្មែរបានរំសាយកងទ័ព ដែលជាហេតុធ្វើឱ្យទ័ព សៀមលើកទ័ពចូលមកម្តងទៀតឡោមព័ទ្ធជុំជិតអស់រយៈពេល ១ ឆ្នាំ ៥ ខែ ចុងក្រោយក្រុងអង្គរត្រូវធ្លាក់ចូលទៅក្នុងកណ្តាប់ដៃរបស់ថៃ ក្នុងឆ្នាំ ១៣៥២។

នៅឆ្នាំ ១៣៥៧ ព្រះរាជាខ្មែរព្រះនាម **សុរិយោវង្ស** ជាព្រះអានុជរបស់ព្រះបាទ **លំពង្សរាជា** ដែលបានភៀសខ្លួនទៅរស់នៅប្រទេសឡាវ បានលើកទ័ពមកវាយរំដោះបានវិញក្នុងឆ្នាំ ១៣៥៧។

នៅឆ្នាំ ១៨៧៣ ក្នុងរាជព្រះបាទ **ធម្មសោក** ជាអានុជព្រះបរមរាមា ព្រះមហាក្សត្រថៃនាម **រាមាសួរ** បានអនុវត្តនយោបាយពង្រីកទឹកដីម្តងទៀត ក្រុងអង្គរត្រូវឡោមព័ទ្ធសារជាថ្មីរយៈពេល ៧ ខែ។ ដោយសង្កេតឃើញថាពុំអាចយកជ័យជំនះលើកងទ័ពខ្មែរ សៀមបានឱ្យទាហានចំនួន ១៥ នាក់ មកសុំចុះចូលដោយនិយាយថាស្តេចសៀមធ្វើបាបខ្លួនពេក ប៉ុន្តែទាហានទាំង ១៥ នាក់នេះ តាមពិតជាមធ្យោបាយធ្វើគត់ព្រះមហាក្សត្រខ្មែរប៉ុណ្ណោះ (១៣៩៣)។ ក្រោយកាន់កាប់ក្រុងអង្គរ លើកទី ២ ព្រះចៅសៀមបានរៀបអភិសេកបុត្រាឈ្មោះ **ពញាកែ្រក** ឱ្យឡើងសោយរាជ្យនៅឆ្នាំ ១៣៩៤ ដែលមាននាមថា **ឥន្ទរាជា**។ ៥ ខែ ក្រោយមក ព្រះបាទ **ចៅពញាយ៉ាត** បានវាយរំដោះក្រុងអង្គរឡើងវិញដោយសារតែបញ្ជាទាហានស្ម័គ្រចិត្ត ១២ រូប សុំចុះចូលជាមួយស្តេចសៀម ហើយបានដកអាវុធ ធ្វើគតស្តេចសៀមបានសម្រេច។ ទ្រង់បានទទួលការរៀបចំឡើងគ្រងរាជ្យដោយសុខសាន្ត ប៉ុន្តែអំណាចចក្រភពអង្គរបានចុះខ្សោយជាលំដាប់។ មកដល់ឆ្នាំ ១៥៩៥ ជាឆ្នាំដែលជនជាតិសៀមបាន វាយបំបែកក្រុងលង្វែក និងបានប្រមូលយកគម្ពីរក្បួនខ្នាត សម្បត្តិវប្បធម៌ខ្មែរជាច្រើនទៅប្រទេសគេ។ នៅពេលឈ្នះសង្គ្រាមម្តងៗ (ចាប់ពីឆ្នាំ ១៣៥២ មក) កងទ័ពសៀមបានចាប់អ្នករស់នៅទីក្រុងរាប់ម៉ឺននាក់យកធ្វើជាឈ្លើយសឹក ប្រមូលយកទ្រព្យសម្បត្តិ សម្បត្តិបីតិកភ័ណ្ឌជាតិ សម្បត្តិវប្បធម៌ខ្មែរ និងថែមទាំងដុតបំផ្លាញទីក្រុងអង្គរទៀតផង។ ចាប់ពីពេលនោះមក យើងសង្កេតឃើញថា វប្បធម៌សៀមមានលទ្ធភាពជះឥទ្ធិមកក្នុងសង្គមខ្មែរជាច្រើន គឺផ្នែកភាសាដូចជា ផាមួង វែនតា ស្មៀន បាឡាត់ យោក្បាត់ .....។ ប៉ុន្តែជនជាតិសៀមក៏យកភាសាខ្មែរជាច្រើនទៅប្រើដែរ ដែលយើងសង្កេតឃើញជាអាទិ៍ ÷

- ក្លាហាន ថៃអានថា ក្លាហាន
- ស្ពាន - សះផាន
- ណែនាំ - ណែះណាំ
- ក្រដាស - ក្រះដាស
- រដ្ឋមន្ត្រី - រ៉ុត់ម៉ុទ្រី
- កម្មករ - ក័មម៉ះកន
- ប្រទេស - ប្រថេប
- ប្រជាជាតិ - ប្រឆាឆាត.........

ទឹកដីខ្មែរ ដែលបានបាត់បង់ដោយសារប្រទេសសៀមមានចំនួន ១២ ខេត្ត គឺ ÷

១- នគររាជ

២- បុរីរម្យ

៣- ធនបុរី

៤- ត្រាច

៥- ច័ន្ទបុរី

៦- សិរីសាកេត

៧- គោកខ័ណ្ឌ

៨- សង្កិត

៩- សុរិន្ទ

១០- ស្ទឹងជ្រៅ

១១- បស្ទឹមបុរី

១២- អ៊្សូប៊ុន




## ខ- ទំនាក់ទំនងខ្មែរ-វៀតណាម

កាលដើមឡើយជនជាតិវៀតណាម គេហៅថា " ដាយវៀត "។ ចាប់ពីសតវត្សទី ១ ដល់សតវត្សទី ១០ ជនជាតិវៀតណាម ត្រូវស្ថិតនៅក្រោមការឈ្លានពាន និងក្រោមអានិគមចិន។ ចាប់ពីសតវត្សទី ១០ មក ជនជាតិនេះ បានរំដោះខ្លួនចេញពីចិនថែមទាំងបានពង្រីកអនុភាពរបស់ខ្លួនក្លាយទៅជាប្រទេសវៀតណា។

ក្រោយពីការឈ្លានពានយកប្រទេសចម្ប៉ារបស់កងទ័ពវៀតណាមចាប់ពីឆ្នាំ ១៤៧១ បានហើយ វៀតណាម បានធ្វើដំណើរឆ្ពោះទៅទិសខាងត្បូងទៀត។ នៅឆ្នាំ ១៦១៨ ព្រះបាទ **ស្រីសុរិយោពណ៌** បានដាក់រាជថ្វាយជូនបុត្រាច្បង របស់ព្រះអង្គ ដែលមានឈ្មោះថា **ជ័យជេដ្ឋាទី ២** ។ ក្នុងព្រះរាជបំណងយកកម្លាំងកងទ័ពវៀតណាម មកទប់ទល់នឹងកង ទ័ពសៀម ព្រះបាទ **ជ័យជេដ្ឋាទី ២** បានរៀបអភិសេកជាមួយនឹងបុត្រីរបស់ស្តេចវៀតណាម ដែលមាននាមឈ្មោះថា **អង្គចូវ**។ បន្ទាប់ពីព្រះបាទ **ជ័យជេដ្ឋាទី ២** ( ១៦១៨ - ១៦២៨ ) បានរៀបអភិសេកជាមួយក្សត្រីវៀតណាមរូបនេះ ( **អង្គចូវ** ) នៅក្នុងសតវត្សទី ១៧ រួចមក នៅពេលនោះហើយ ដែលវៀតណាមសុំខ្ចីដីខ្មែរនៅត្រង់ព្រៃនគរកំពង់ក្របី ដើម្បីដាក់កងទ័ពវៀតណាម សម្រាប់ធ្វើចម្បាំងជាមួយចិន។ ប្រាំឆ្នាំក្រោយមក ខ្មែរបានទាមទារសុំដីនោះមកវិញ តែ វៀតណាមសុំអង្វរបន្ត ដោយមានអន្តរាគមន៍ពី ព្រះនាង ***អង្គចូវ*** ផង។




ក្រោយមកការទាមទារនោះ ក្លាយជាអាសារបង់ ពីព្រោះនៅពេលនោះ មានការបាក់បែកផ្ទៃក្នុង មានទំនាស់ជាញឹកញាប់ ជាហេតុដែលពុំអាចដោះស្រាយរួច រហូតមកដល់សព្វថ្ងៃនេះ ដែលបណ្ដាលឱ្យខេត្តខ្មែរទាំងប៉ុន្មានបានក្លាយជារបស់វៀតណាម ដែលគេហៅថា " កម្ពុជាក្រោម " (ជាមួយគ្នានោះពួកអាណានិគមបារាំង បានកាត់ទឹកដីខ្មែរឱ្យវៀតណាមនៅឆ្នាំ ១៩៤៩ ) ។

ល្បាយសាសន៍ជនជាតិវៀតណាមកន្លងមក យើងអាចថា មនុស្សវៀតណាម គេមានទ្រឹស្ដីមួយ " កើតមកជាមនុស្សត្រូវធ្វើមុខក្រាស់ ដៃរហ័ស ចិត្តហ៊ាន " ខុសពីខ្មែរយើង ដែលមានទ្រឹស្ដីថា " ឱ្យគេវ៉ានៅ ស៊ីទៅវ៉ាអស់ " មានន័យថា ចិត្តល្អ។ ភាសានិយាយ គេសង្កេតឃើញមានពាក្យពេចន៍មួយចំនួន ចេញពីពាក្យវៀតណាមដូចជា បញ្ញើរ ចៃវ បាញ់ហយ ឡឿងហែម ក្តារឿរ....។

ទឹកដីខ្មែរ ដែលបានបាត់បង់ ដោយបារាំងកាត់ ឱ្យវៀតណាមចំនួន ២១ ខេត្ត ÷

***ឈ្មោះដើម*** ***ឈ្មោះថ្មី*** ***វៀតណាមកែ***

១- កំពង់ស្រកាត្រី បៀងហ្វា ភឿកថាញ់

២- រោងដំរី តៃនិញ ឡុងនិញ
៣- ព្រៃនគរ សៃហ្គន ហូជីមិញ
៤- ផ្សំអំបិល សៃតែ កៀនហ្វា
៥- មេស មេស ឱញភឿង
៦- គោះគង ឡុងអាន
៧- ព្រៃកប្ញស្សី គិនធឹ ជុងឃីញ
៨- លុងហោ វិញឡុង
៩- ព្រះត្រពាំង ត្រាវិញ វិញមិញ
១០- ផ្សារដែក សាដែក ភៀនផុង
១១- មាត់ជ្រូក ចូវដុក អាងយ៉ាង ( ឡុងសៀង )
១២- បារាជ ភឿឡៀ
១៣- ឃ្លាំង ស្រុកទ្រាំង ខាយហ្វុង ( បាសៀង )
១៤- ពាម ហាទៀង
១៥- ក្រមួនស រ៉ាជយ៉ា កៀងយ៉ាង ( ជឿនធឿន )
១៦- ពលលាវ បាក់លីវ
១៧- ពាមបារាជ ឡុងសៀង អានយ៉ាង
១៨- ទួលតាមោក ធូយ៉ូវម៉ាក បិញហឿង (បិញឡុង)
១៩- ព្រះសួគ៌ា ទឿកឡៀ ហ្សឿង (បិញទ្វី )
២០- អូរកាប់ វុងតាវ
២១- ឈ្មោះថ្មី កិនអាន

**ច_ ទំនាក់ទំនងខ្មែរ_អឺរ៉ុប**

លុះក្រោយមកទៀត នៅពេលដែលខ្មែរយើងចុះអន់ថយហើយ ត្រូវពួកជនជាតិនៅអឺរ៉ុបចូលមកធ្វើជំនួញ និងធ្វើអាណានិគម ពេលនោះទើបមានឥទ្ធិពលអឺរ៉ុប បានជ្រៀតចូលទៅក្នុងអរិយធម៌ខ្មែរនៅសតវត្សទី ១៦ តាមរយៈប្រដាប់ប្រដារប្រើប្រាស់ វិទ្យាសាស្ត្រ បច្ចេកទេស និងទំលាប់ខ្លះៗទៀតដូចជា ចាប់ដៃ ងក់ក្បាលជាដើម។

*តើឥទ្ធិពលបរទេសដែលបានជ្រៀតចូលមក អាចធ្វើឱ្យ ឬមានការកែប្រែលក្ខណៈអរិយធម៌ខ្មែរដែរឬទេ?*

ពិតមែនតែឥទ្ធិពលបរទេសបានជ្រៀតចូលមកច្រើនបែបច្រើនយ៉ាងក៏ដោយ ក៏ខ្មែរយើងពុំនិយម និងអនុវត្តតាមទាំងស្រុងនោះទេ។ ខ្មែរតែងតែយកឥទ្ធិពលទាំងនោះមកកែច្នៃឱ្យសមស្របតាមចំណង់ចំណូលចិត្ត និងទស្សនៈរបស់ខ្មែរ ដែលជាហេតុធ្វើឱ្យអរិយធម៌ខ្មែររឹតតែសម្បូណ៌រុងរឿង និងរីកចំរើនកើនឡើងថែមទៀត។ ប៉ុន្តែវត្តមានអរិយធម៌

បរទេសនៅក្នុងអរិយធម៌ខ្មែរ បានធ្វើឱ្យអរិយធម៌ខ្មែរផ្នែកខ្លះរលប់ដានស្ទើរតែរកប្រភពដើមពុំឃើញ។ ដូចនេះហើយបានជាអ្នកប្រាជ្ញខ្លះ ខំទាញសម្មតិកម្ម និងទស្សនៈផ្ទាល់ខ្លួនមកធ្វើជាអំណះអំណាង ក្នុងការធ្វើនិទស្សន៍ស្តីពីអរិយធម៌ខ្មែរនេះ។

✡ ទស្សនៈរបស់លោក *Jentaupain* នៅក្នុងសៀវភៅរបស់លោក ដែលមានចំណងជើងថា " *Etude sur la littérature Khmère* " គាត់មានសរសេរថា អក្សរសិល្ប៍ជាភាសាខ្មែរ ដែលសម្គាល់ " លក្ខណៈខ្មែរ "។

✡ នៅក្នុងសៀវភៅរបស់អ្នកស្រាវជ្រាវម្នាក់ ដែលមានចំណងជើងថា " *Le peleri D'ankor la peuple Khmère*" បញ្ជាក់ថា ប្រជាជនខ្មែរមានមែកធាងចេញពីអំបូរអារ្យ។

✡ ទស្សនៈរបស់លោក **កែប វណ្ណឌី** លោក **ពៅ ឈិន** និងលោក **ឈឹម ក្រសេម** ក៏បានបញ្ចេញយោបល់ថា អរិយធម៌ខ្មែរ មានប្រភពចេញពីឥណ្ឌាដែរ។

តាមទស្សនៈអ្នកប្រាជ្ញមួយចំនួនដូចបានពោលខាងលើ រួមទាំងលោក **ហង់ឡ៊ើកកែន ព្យែហ្គូ** សុទ្ធតែយល់ថា ខ្មែរ គឺជាជនជាតិអន្តោប្រវេសន្តន៍ចេញពីឥណ្ឌា។

*តើជនជាតិខ្មែរមានកំណើតកើតមកពីឥណ្ឌាមែនឬទេ ?*

ជនជាតិខ្មែរ គឺជាជនជាតិម្ចាស់ស្រុករស់នៅលើទឹកដីរបស់ខ្លួនមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ មានទំនៀមទំលាប់ប្រពៃណី ពោលគឺមានអរិយធម៌របស់ខ្លួនជាក់លាក់មុនពេលដែលខ្មែរមានល្បាយជាតិសាសន៍។ ដោយផ្អែកទៅលើការសិក្សាស្រាវជ្រាវស្ថានីយ៍បុរេប្រវត្តិសាស្ត្រនៅល្អងស្ពាន នៅភ្នំទាកទ្រាំខេត្តបាត់ដំបង ដែលសិក្សាដោយលោក **ស្រី មួរ៉េ** (Mourer) ដែលជាសាស្ត្រាចារ្យបុរាណវិទ្យា នៅមហាវិទ្យាល័យបុរាណវត្ថុ នៃសាកលវិទ្យាល័យវិចិត្រសិល្បៈនៅឆ្នាំ ១៩៦៦ - ១៩៦៩ បានបញ្ជាក់ថា ទឹកដីនេះមានមនុស្សរស់នៅតាំងពី ៤២៩០ ឆ្នាំ មុនគ.ស។ ជាមួយគ្នានោះលោក **កាបូណែល** *Carbonel* និងលោក *Dalibrias* បានបញ្ជាក់ថា ទឹកដីនេះ មានមនុស្សរស់នៅប្រមាណជា ៣៤២០ ឆ្នាំមុនគ.ស នេះបើតាមឯកសារស្រាវជ្រាវនៅស្ថានីយ៍បុរេប្រវត្តិសាស្ត្រភ្នំក្បាលរមាសខេត្តកំពត។

ផ្អែកលើវត្ថុតាងនៅតាមស្ថានីយ៍បុរេប្រវត្តិសាស្ត្រសំរោងសែន ដែលស្រាវជ្រាវដោយលោក *Roque* ឆ្នាំ ១៨៧៦ និងស្ថានីយ៍អន្លង់ផ្តៅ ដែលសិក្សាស្រាវជ្រាវដោយលោក *Mansuy* នៅឆ្នាំ១៩៦២ និងស្ថានីយ៍ម្លូព្រៃ ដែលសិក្សាស្រាវជ្រាវដោយលោក *Paul lévy* នៅឆ្នាំ ១៩៤៣ គេបានរកឃើញវត្ថុផ្សេងៗធ្វើអំពីថ្មរំលីង ឆ្អឹងសត្វ សំបកខ្យង លង្ហិនដែក ដូចជា ពូថៅ សន្ទូច កាំបិត កណ្ដៀវ ពន្លាក និងគ្រឿងអលង្ការផ្សេងៗ។ គេបានសន្និដ្ឋានថា នៅលើទឹកដីនេះមានមនុស្សរស់នៅតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្លេះ។ ប៉ុន្តែបើតាមវត្ថុតាងនៅស្ថានីយ៍សំរោងសែនគេវាយតម្លៃថា នៅលើទឹកដីនេះ មានមនុស្សរស់នៅប្រមាណជា ២០០ ឬ ១០០ឆ្នាំមុនគ.ស។

តាមការសិក្សាស្រាវជ្រាវរបស់ប្រវត្តិវិទូ និងអ្នកប្រាជ្ញខ្លះ ដូចជាលោក **ហង់រីម៉ាក់សែល** លោក **ក្រូលីយេ** លោក **អែម៉ូ នីញ៉េ** បានបញ្ជាក់ថា ខ្មែរជាជនជាតិពិសេសមួយស្ថិតនៅក្នុងអំបូរ "មន-ខ្មែរ "។

*តើមនជានរណា ?* ជាជនជាតិរស់នៅតាមតំបន់មេណាមប្រទេសសៀម និងតំបន់វាលទំនាបតាមទន្លេឥរាវតី នៃប្រទេសភូមាសព្វថ្ងៃ។ មនបានបាត់បង់ទឹកដីរបស់ខ្លួន តាំងពីសតវត្សទី ១៦ មកម្លេះ។

តាមការសិក្សាស្រាវជ្រាវ ខ្មែរមានកំពស់ជាមធ្យម ១ : ៦១ ម៉ែត្រ និងមានសន្ទស្សន៍លលាដ៏ក្បាល ៨៤.៥ និងក្បាលរាងមូល ។

*ឥណ្ឌា ស* ( ពួកអារ្យាង្គ ) មានកំពស់មធ្យម ១:៧២ ម៉ែត្រ សន្ទស្សន៍លលាដ៏ក្បាល ៧៣.៨ ក្បាលរាងពយ

*ឥណ្ឌា ខ្មៅ* ( ពួកដ្រាវីដ ) មានកំពស់មធ្យម ១:៦១ ម៉ែត្រ សន្ទស្សន៍លលាដ៏ក្បាល ៧៦.២ ក្បាលរាងពយ

*មន* មានកំពស់មធ្យម ១:៦២ សន្ទស្សន៍លលាដ៏ក្បាល ៨៥.៦ ក្បាលរាងមូល

មុនពេលព្រះបាទ **ហ៊ុន ទៀន** ឬហៅថាព្រះបាទ **កៅណ្ឌិន្យ** ចូលមកដល់ស្រុកខ្មែរ នៅពេលនោះ យើងមានរចនាសម្ព័ន្ធគ្រប់គ្រងប្រទេស មានទឹកដី មានកងទ័ព មានទំនៀមទំលាប់ប្រពៃណី ថែមទាំងមានព្រះមហាក្សត្រិយ៍ គឺព្រះនាង **លីវយី** ឬព្រះនាង **សោមា** សោយរាជ្យនៅទីនោះរួចជាស្រេចទៅហើយ ។ ដូចនេះ ខ្មែរពុំមែនមានដើមកំណើតកើតពីឥណ្ឌានោះទេ ។

## VII. ដើមកំណើតជនជាតិខ្មែរ

*ពាក្យខ្មែរមកពីណា ? ពាក្យកម្ពុជាមកពីណា ?*

នៅក្នុងអំបូរភាសាមន-ខ្មែររបស់លោក **គង់ អិន** និងលោក **ឡុច ផ្លេង** ចុះក្នុងទស្សនាវដ្តីខេមរៈយានកម្ម ខែ តុលា ឆ្នាំ ១៩៦៩ បានបញ្ជាក់ថា ខ្មែរបាននាំគ្នាមករស់នៅតាមវាលទំនាបទន្លេមេគង្គ ។ មនបានរស់នៅតាមតំបន់មេណាម នៃប្រទេសសៀម និងតំបន់វាលទំនាបទន្លេឥរាវតី នៃប្រទេសភូមាសព្វថ្ងៃ ហើយបានបាត់បង់ទឹកដីរបស់ខ្លួនតាំងពីសតវត្សទី ១៦ មកម្លេះ ។

- លោក **រស់ សារ៉េត** បានបញ្ជាក់នៅឆ្នាំ ១៩៧១ ថាខ្មែរជំនាន់ដើមមានទីក្រុងមួយឈ្មោះថា ក្រុងខម "ឧបទ្វីបដែនដីសុវណ្ណភូមិ " ខម = មាស ។ ខម > កម > កមេរុ > ខមេរុ > ខ្មែរ ។
- លោក **កេង វ៉ាន់សាក់** យល់ថាជនជាតិខ្មែរជាម្ចាស់ស្រុកដើម មានទឹកដីពិតប្រាកដ ដោយខ្មែរគោរពមេជាធំ " របបមាតាធិបតេយ្យ " ។ មេដាក់បុព្វបទ ( ក ) កមេ > ក្មេរ > ខ្មេរ > ខ្មែរ រីឯពាក្យកម្ពុជាក្លាយមកពីពូជអ្នកជាមិនមែនអ្នកខ្ញុំគេ ទើបហៅ កពូជជា > កពូជជា ( តាមបាលី និងសំស្ក្រឹត ) > កម្ពុជា ។
- លោក **ហ្សក ហ្សឺដេស** បានពន្យល់ថា ខ្មែរមកពីរឿងព្រេងនៅក្នុងសិលាចារឹកបក្សីចាំក្រុង នៅក្នុងសតវត្សទី







១០ និទានថា ស្តេចខ្មែរមានដើមកំណើតពីឥសីកម្ពុ （ស្វ័យម្ភូ） និងនាង **មេរា**（**អប្សរា**）គឺនាងទេពអប្សរ ដែលជាអំណោយរបស់ព្រះសីវៈ ។

ឥសីកម្ពុ > មេរា > កម្ពុមេរា > កម្ពុជា

• ទស្សនៈលោក **ស័រ ហ្សឺដេស** និងលោក **វិរិយភិក្ខុប៉ាងខាត់** ៖ លោក **ស័រ ហ្សឺដេស** ជាអ្នកប្រាជ្ញបារាំងដ៏ល្បីល្បាញម្នាក់ ដែលបានសិក្សាស្រាវជ្រាវអំពីសិលាចារឹកនៅប្រទេសកម្ពុជា ហើយបានចំណាយពេលមួយភាគធំ នៃជីវិតរបស់លោក ដើម្បីសិក្សាស្រាវជ្រាវអំពីដើមកំណើតខ្មែរ។ លោកបានធ្វើមរណៈកាលក្នុងជន្មាយុ ៨៣ ឆ្នាំនៅទីក្រុងបារីស។ លោក **ហ្សឺដេស** បានបន្សល់ទុកនូវស្នាដៃ ដែលមានតម្លៃជាច្រើន ហើយដែលទាក់ទងទៅនឹងអរិយធម៌ខ្មែរ គឺសៀវភៅមួយ ដែលមានចំណងជើងថា *Histoire Ancienne Des Etats Hindouises* ដែលយើងបានដកស្រង់ក្នុងទំព័រទី ៨០ ក្នុងឃ្លាមួយដែលបាននិយាយអំពីដើមកំណើត នៃពាក្យខ្មែរ ហើយដែលយើងបកប្រែជាភាសាជាតិ ដូចខាងក្រោមនេះ ៖

តាមរឿងព្រេងទាក់ទងនឹងសន្តិវង្ស *Dynastie* ខ្មែរ ដែលបានរក្សាទុកនៅក្នុងសិលាចារិកនាសតវត្សទី ១០ បានឱ្យដឹងអំពីដើមកំណើត នៃស្តេចខ្មែរ ដែលចេញមកពីការរួមសម្ព័ន្ធរវាងឥសីកម្ពុ " ស្វ័យម្ភូ : កើតឯង " បុព្វបុរសដំបូងរបស់កម្ពុជា និងនាងអប្សរាមេរា "អំណោយរបស់ព្រះសីវៈ " ហើយដែលឈ្មោះនោះប្រហែលប្រែប្រួល ដើម្បីពន្យល់អំពីខ្មែរ។ ទស្សនៈរបស់លោក **ស័រ ហ្សឺដេស** នេះ បានត្រូវគាំទ្រដោយព្រះភិក្ខុ **ប៉ាងខាត់** ថែមទាំងបានយកទៅធ្វើបឋកថាតាមទស្សនាវដ្តីពុទ្ធសិក្សាឆ្នាំទី ១ លេខ ៥ ឆ្នាំ ១៩៥៧ ដូចមានអត្ថបទដកស្រង់ខាងក្រោមនេះ " ក្នុងអតីតកាល ផែនដីយើង ដែលហៅថាកម្ពុជាសព្វថ្ងៃនេះ មានពីរភាគធំៗ ភាគខាងលើហៅថា ចេនឡា "ចេនឡា" ភាគខាងក្រោមហៅថា ហ្វូណន " ភ្នំ "។ ដើមឡើយចេនឡា នៅក្រោមអំណាចហ្វូណន គឺសមន្តរាជនគរហ្វូណន។ ឯស្តេចសោយរាជ្យបន្តរហូតមក ក្នុងភាគដែនដីទាំងពីរនេះ មានវង្សផ្សេងៗគ្នា គឺខាងនគរភ្នំនៅខាងត្បូងជាសោមវង្ស ឯភាគខាងជើង គឺចេនឡាសូរ្យវង្ស សោមវង្ស និងសូរវង្សនេះ ជាវប្បធម៌ឥណ្ឌា។ ប្រទេសឥណ្ឌាមានប្រពៃណីនេះអស់កាលដ៏យូរលង់មកហើយ គឺថា ៖

**ក-** សោមវង្សជាប្រពៃណីកើតចេញមកពីសោមទេព "ព្រះច័ន្ទ " ដែលទេពតាមួយអង្គ ក្នុងលទ្ធិសាសនាព្រាហ្មណ៍ មានរូបតំណាងព្រះគ្រឹស្ណៈ ដែលជាអវតារបស់ព្រះវិស្ណុ ក្នុងរឿងមហាភារត។

**ខ-** សូរ្យវង្ស ជាប្រពៃណីកើតចេញពីសូរ្យទេព " ព្រះអាទិត្យ " ដែលមានតួអង្គតំណាងគឺ ព្រះរាម ជាអវតារបស់ព្រះវិស្ណុ ក្នុងរឿងរាមាយណៈ។

ចំណែកនៅប្រទេសខ្មែរយើងវិញ តាមសិលាចារឹកនៅប្រាសាទតាព្រហ្ម ព្រះរាជធីតាខាងសូរវង្ស " វង្សស្រី កម្ពុមេរា " បានព្រះបាទ **ភវវ៌ន** ខាងសោមវង្សជាស្វាមី។

យើងបានចម្លងយកប្រពៃណីនេះ មកប្រើដូចជាប្រពៃណីសកលលោកដែរ ក្នុងកាលដែលវប្បធម៌ឥណ្ឌាហូរ

ចូលមកក្នុងប្រទេសយើងហើយ ។ ឯបបុព្វហេតុ ដែលនាំឱ្យកើតបានជាប្រពៃណីឡើងមុនដំបូងនោះ គឺ ÷

សោមវង្សខាងនគរភ្នំកើតឡើង អាស្រ័យយកការសម្ព័ន្ធរាជាពីបុរាណគឺ ព្រះបាទ ***ហ៊ុនទៀន*** ឬ ***កៅណ្ឌិន្យ*** និងនាង **លីវ យី** ឬនាង ***សោមា*** គឺ **កៅណ្ឌិន្យ** និងព្រះរាជធីតា នៃព្រះសោម " សិលាចារឹកបក្សីចាំក្រុងគាថា ១៦ " សិលាចារឹកមីសឺន Nhatrang គ.ស ៦៥៨ ថាមានព្រាហ្មណ៍ម្នាក់មកពីប្រទេសឥណ្ឌា **គោតរៈ គោត្រៈកៅណ្ឌិន្យ** បានលំពែងពីអស្វាតម័ន ជាបុត្រ **ទ្រោណៈ** ហើយតម្កល់ទុកក្នុងភវបុរៈ ពោលគឺបានទឹកដី បានរាជធីតារបស់ព្រះសោមជាទេពី ។ សូរវង្សកើតឡើងពីសម្ព័ន្ធ **ឥសីកម្ពុ** និងនាង **មេរា សុរសុន្ទរី** ។ បើតាមការប្រមើមើលមកពីសិលាចារឹកប្រាសាទបក្សីចាំក្រុងវិញត្រង់គាថា ១១ - ១២ ប្រហែលជាព្រះ **ថោង** និង **នាគី** ( រឿងព្រះថោងនាងននាគ ) ។

តាមប្រវត្តិសាស្ត្រ ការផ្លាស់ប្តូរសម័យនគរភ្នំទៅជាសម័យចេនឡាវិញនេះ ដោយមានបុព្វហេតុថា ក្នុងរវាងសតវត្សទី ៦ ព្រះរាជវត្តាព្រះបាទ **រុទ្រវរ្ម័ន** ព្រះនាម **វីរវរ្ម័ន** ខាងសោមវង្សបានព្រះនាង **កម្ពុជាជល្សី** ខាងសូរ្យវង្សជាព្រះទេពី ។ ព្រះរាជកុមារអង្គនេះ បានវាយដណ្តើមយកសមន្តរាជ "សមន្តរាជចេនឡា" ហើយឡើងសោយរាជ្យមានព្រះបរមនាមថា **ព្រះបាទភវវរ្ម័នទី ១** ។ ព្រះមហាក្សត្រអង្គនេះ មានព្រះអានុជព្រះនាមចិត្រសេនា ជំនាញខាងយុទ្ធវិធី បានលើកពលរេហ៍ទៅវាយកនគរភ្នំក្រុង វ្យាធបុរៈ = វយធបុរៈ សព្វថ្ងៃគឺបាភ្នំ ខេត្តព្រៃវែង ហើយយកនគរភ្នំជាសមន្តរាជចេនឡាវិញ ។ ដោយ សារជ័យជំនះលើនគរភ្នំនេះហើយ ទើបអ្នកប្រាជ្ញប្រវត្តិសាស្ត្របានឱ្យឈ្មោះសម័យនោះថា ជាសម័យចេនឡា ដែលមានស្តេចសោយរាជ្យសន្តិវង្សគឺ **ភវវរ្ម័នទី១ ចិត្រសេនាមហេឥន្ទ្រវរ្ម័ន ព្សានវរ្ម័ន ភវវរ្ម័នទី ២ ជ័យវរ្ម័នទី ១** តមកទៀតចេនឡាក៏បែកបាក់ជាពីរគឺ ចេនឡាលើ និងចេនឡាក្រោម ប្រហែលឆ្នាំ ៨០២ នៃគ.ស មានព្រះមហាក្សត្រមួយអង្គព្រះនាម **ជ័យវរ្ម័នទី ២** ផ្នែកខាងសូរ្យវង្សបានឡើងគ្រងរាជ្យ ដោយឫទ្ធានុភាពបានប្រមូលផ្តុំចេនឡាទាំងពីរឱ្យឯកភាពគ្នាឡើងវិញ ។ សម័យក្រោយនេះ ហៅថាសម័យមហានគរ ពីព្រោះសម័យនេះ មានប្រាង្គប្រាសាទធំៗ ខ្ពស់ស្កឹមស្កៃជាច្រើន ។ សេចក្តីបានដកស្រង់មកខាងលើនេះ បានបង្ហាញឱ្យឃើញច្បាស់ថា វប្បធម៌ អរិយធម៌ខ្មែរពិតជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយឥណ្ឌា និងទទួលឥទ្ធិពលឥណ្ឌា ។ ដូចនេះ ទស្សនៈរបស់លោក **ហ្សឺដេស** ដែលសន្និដ្ឋានថាខ្មែរ មានដើមកំណើតមកពី **ឥសីកម្ពុ** និងនាង **មេរា** ដែលនាំឱ្យកើតឈ្មោះកម្ពុជា ឬខ្មែរនេះ ជាការសមរម្យណាស់ ។

ដើម្បីឱ្យកាន់តែយល់ច្បាស់ពីដើមកំណើត នៃពាក្យខ្មែរ និងកម្ពុជា យើងលើកយកសេចក្តីអធិប្បាយរបស់ព្រះភិក្ខុ **វិរិយប៉ាងខាង** តទៅទៀត ។

ពាក្យថាខ្មែរ កាលពីសម័យបូរាណក្នុងប្រវត្តិសាស្ត្រតាង *Histoire distang* គ.ស ៦០៨ - ៦៨០ ។ ចិនហៅ " គីម៉ាវ " ។ សិលាចារឹកចាមនៅញ៉ាត្រាង ( *Nhatrang* ) ខ្មែរថា " គ្មី " សៀម ឡាវហៅថា "ក្មែរ" វៀតណាមហៅថា " កាម៉ែន ឬការមៀន " ។ ចំពោះជនជាតិដទៃទៀតហៅដូចខាងលើនេះ ប្រហែលគេហៅខ្មែរយើងពុំច្បាស់ចំឈ្មោះ តាមលោក **ស៊ែរ ហ្សឺដេស** យើងអាចនៅមានពាក្យ កម្ពុ + មេរា > កម្ពុមេរា > កម្ពុជា ។ ក + មេរ > ក្មែរ >

ខ្មែរ > ខ្មែរ  តាមដំណើរនេះ ក៏ទំនងសមរម្យ  និងយកជាការបានដែរ។ ម្យ៉ាងទៀតតាមសិលាចារឹក  គេពិនិត្យឃើញ សរសេរតែ " ក្មែរ " ប៉ុណ្ណោះ។

*តើអរិយធម៌ខ្មែរមានលក្ខណៈពិសេសដូចម្ដេចខ្លះ ?*

អរិយធមិខ្មែរមានលក្ខណៈពិសេសពីរយ៉ាងគឺ ÷

❖ **លក្ខណៈជាតិ :** ជាលក្ខណៈស្ថិតស្ថេររបស់ប្រជាជាតិកម្ពុជា ដែលរួមមាន  ទំនៀមទំលាប់ប្រពៃណី  សិល្បៈ សាសនា  ភូមិសាស្រ្ត  ទឹកដី ....... ( ព្រលឹងជាតិ  អត្តសញ្ញាណជាតិ ) ។  ឥទ្ធិពល  ដែលមិនសមស្របតាមចំណង់ចំណូល ចិត្តរបស់ប្រជាជាតិខ្មែរ  ត្រូវបានទាត់ចោលទាំងស្រុង។

❖ **លក្ខណៈសំយោគ :** ជាលក្ខណៈ ដែលបត់បែនទន់ភ្លន់ទៅតាមអ្វី ដែលមានលក្ខណៈរីកចម្រើន  ដោយយកមក កែច្នៃ ប្រឌិតឱ្យមកជាលក្ខណៈជាតិ ( ជាតូបនីយកម្ម)  មានន័យថា ខ្មែរមិនទទួលយកអរិយធមិបរទេសទាំងស្រុងឡើយ។

ដើម្បីឱ្យយល់កាន់តែច្បាស់ស្ដីអំពីវប្បធមិ អរិយធមិខ្មែរ  យើងត្រូវតែសិក្សាបន្ថែមទៀតទៅលើវប្បធមិ អរិយធមិ "**អូស្រ្តូអាស៊ី** "





## VII. វប្បធម៌  អរិយធម៌  អូស្រ្តូអាស៊ី  (អាស៊ីខាងត្បូង)

អូស្រ្តូអាស៊ីខាងត្បូង ដែលកំណត់ចាប់ពីប្រទេសឥណ្ឌាដល់ប្រទេសចិនខាងត្បូង  រហូតដល់ប្រទេសនូវែលគីនេ ក្នុងមហាសមុទ្រប៉ាស៊ីភិច។ វប្បធមិអូស្រ្តូអាស៊ីអាចហៅម្យ៉ាងទៀតថា វប្បធមិ អរិយធមិខ្យល់មូសុង ឬខ្យល់រដូវ  ពីព្រោះ តំបន់នេះមានខ្យល់រដូវទៀងទាត់ ។ គេអាចសង្កេតឃើញមនុស្សជាតិ ដែលរស់នៅតំបន់នេះមានវប្បធមិដូចគ្នាខ្លះ  ដូចជា

ជំនឿ គេអាចធ្វើស្រែវស្សា គេចេះប្រើគោ ប្រើក្របី ចេះប្រើឧបករណ៍ធ្វើស្រែ ចេះស្លលោហៈធាតុ និងស្ទាត់ជំនាញក្នុងនាវាចរ។

ក្នុងវិស័យសង្គមកិច្ច គេចាត់ទុកស្ត្រីជាធំក្នុងគ្រួសារ និងក្នុងសង្គមគេរាប់ញាតិតាមខ្សែរស្រឡាយខាងម្ដាយ នៅក្នុងប្រទេសខ្មែរសព្វថ្ងៃ ស្ត្រីក៏មានតួនាទីធំក្នុងគ្រួសារដែរ " ចង់បានស្ត្រីជាប្រពន្ធ គេត្រូវចូលស្ដីដណ្ដឹង ហើយពេលខ្លះគេត្រូវទៅបម្រើខាងស្រីពី ២ ទៅ ៣ ខែ ឬលើសពីនេះទៅទៀតពី ៦ ទៅ ១ ឆ្នាំផងក៏សឹងមាន "។ នៅពេលរៀបអាពាហ៍ពិពាហ៍ គេត្រូវទៅធ្វើពិធីនៅផ្ទះខាងស្រី។ ពេលរៀបការរួច កូនប្រុសខ្មែរត្រូវទៅរស់នៅផ្ទះខាងស្រី។

នៅប្រទេសឥណ្ឌា និងប្រទេសចិនវិញ គេមិនលើកស្ត្រីជាធំទេ គេបែរជាបន្ថោកស្ត្រី ដោយចាត់ទុកស្ត្រីជាអ្នកអន់ក្នុងសង្គម។ នៅប្រទេសឥណ្ឌា តាំងពីព្រេងនាយមក ស្ត្រីមេម៉ាយគ្មានសិទ្ធិយកប្ដីទៀតឡើយ កាលណាប្ដីស្លាប់ទៅ ត្រូវនៅបម្រើ គ្រួសារខាងប្ដីបន្តទៅទៀត ឬក៏ត្រូវលោតចូលភ្លើងសម្លាប់ខ្លួនតាមប្ដី។

ចំណែកនៅក្នុងសង្គមចិនវិញ គេឱ្យតម្លៃទៅលើបុរសដែរ ក្នុងគ្រួសារចិននីមួយៗ គឺប្ដីជាអ្នកមានមុខងារសំខាន់ ក្នុងការទទួលខុសត្រូវ។ បើឪពុកស្លាប់ទៅ កូនប្រុសច្បងជាអ្នកគ្រប់គ្រង ឬទទួលតំណែងសំខាន់ជំនួសឪពុក ចំណែកឯកូនស្រី គ្មានតួនាទីវិញ គ្មានតួនាទីអ្វីបន្តិចឡើយ។ ពេលរៀបអាពាហ៍ពិពាហ៍រួច កូនស្រីត្រូវទៅរស់នៅផ្ទះខាងកូនប្រុស បើប្ដីស្លាប់ទៅស្ត្រីចិន ក៏នៅបម្រើគ្រួសារខាងប្ដីតទៅទៀត។

ផ្នែកជំនឿមនុស្សជាន់ដើមថា មនុស្សយើងព្រលឹងមានបីប្រភេទ គឺព្រលឹងធំ ព្រលឹងតូច និងព្រលឹងបន្ទាប់បន្សំទៀត។ ព្រលឹងធំចេញពីក្នុងខ្លួន ៦ ខែ មុនពេលស្លាប់ ព្រលឹងតូចចេញនៅពេលស្លាប់ និង ព្រលឹងបន្ទាប់បន្សំចាកចេញ ពីក្នុងខ្លួន ឥមនុស្សស្លាប់ ៦ ខែ ក្រោយពីស្លាប់មក។ សព្វថ្ងៃនេះ នៅតាមតំបន់ខ្ពង់រាប ក៏នៅមានជំនឿបែបនេះដែរ ខ្មែរយើងនៅមានរហូតដល់សព្វថ្ងៃនៅឡើយ។ នៅពេលស្លាប់ ឬមុនពេលស្លាប់ ញាតិមិត្តរបស់បុគ្គលស្លាប់តែងតែនាំគ្នារៀបចំកន្ទោង ឬ ប្រដាប់ប្រដាររបស់បុគ្គលស្លាប់ ដែលធ្លាប់ប្រើ ហើយបញ្ជូនឱ្យទៅដល់បុគ្គលស្លាប់នោះ។

ព្រះរាជទីនាំង




ព្រះរាជទីនាំងនាវា ក្នុងព្រះរាជពិធីបូជាព្រះសព
ព្រះករុណា នរោត្តម នាខែ មករា ឆ្នាំ ១៩០៦ ។

នៅពេលស្លាប់ ឬមុនពេលស្លាប់ ញាតិមិត្តរបស់បុគ្គលស្លាប់ទាំងអស់ បានរៀបចំធ្វើពិធី

រំលាយសព ដោយ ដាក់សពនៅក្នុងក្រឡឱ្យអង្គុយចោមហោង ដោយបំពាក់គ្រឿងអលង្ការ រួចយកទៅកប់នៅក្រោមថ្មដុល។ ចំពោះសពរបស់អ្នកមានបណ្ដាស័ក្តិ ឬស្តេច គេយកសពទៅដាក់ក្នុងកោដិឱ្យអង្គុយចោមហោង បំពាក់គ្រឿងអលង្ការ។

ជំនឿទាំងអស់ ដូចបានពោលខាងលើ មកពីពួកគេនៅជំនាន់នោះ មានជំនឿថាមនុស្សស្លាប់ទៅ ព្រលឹងឥតស្លាប់ទេ ព្រលឹងពិតជាមិនសាបសូន្យ ហើយបាននាំទៅដល់ការគោរពលើខ្មោច ឬគោរពលើព្រលឹងអ្នកទាំងអស់នោះ ដែលមានលំនាំតាំងពីពួកគេរស់នៅជាក្រុមកុលសម្ព័ន្ធ គោរពព្រលឹងមេក្រុមកុលសម្ព័ន្ធ ពោលគឺព្រលឹងមេដឹកនាំ អ្នកតស៊ូប្រកបដោយវីរភាពទាំងឡាយ ដែលសព្វថ្ងៃនៅមានឈ្មោះថា ជំនឿទៅលើអារក្សអ្នកតា។

*អ្នកតាជាអ្វី ?*

អ្នកតា គឺជាព្រលឹងរបស់វីរជនរបស់ មេកន្ទ្រាញ របស់កុលសម្ព័ន្ធ របស់មេទ័ព ដែលធ្លាប់មានគុណបំណាច់ជួយ ដល់កូនចៅប្រជារាស្ត្រ កាលដែលពួកគាត់នៅរស់។ លុះដល់ពេលពួកគាត់ស្លាប់ទៅ ព្រលឹងរបស់ពួកគាត់ទៅកើតជាអ្នកតា ឬអ្នកដូន អ្នកយាយ គេជឿថា នៅពេលដែលអ្នកដូននៅរស់ ធ្លាប់តែឱ្យសុខសុភមង្គល ដល់សមាជិកក្នុងគ្រួសារ ក្នុងកុលសម្ព័ន្ធ នៅពេលដែល គាត់ស្លាប់ទៅ គាត់នៅតែថែរក្សាឱ្យសុខ ឬឱ្យទុក្ខដល់ពួកគេដដែល។ ជំនឿលើអ្នកតាមានឥទ្ធិពលយ៉ាងខ្លាំងក្លា ទៅលើ ប្រជារាស្ត្រយើង ពិសេសនៅតំបន់ដាច់ស្រយាល ដែលវិទ្យាសាស្ត្រពុំទាន់ជឿនលឿន។ រហូតមកដល់សព្វថ្ងៃនេះ ជំនឿ ទៅលើអ្នកតា ក៏នៅមាននៅឡើយ ហើយគេធ្វើបុណ្យថ្វាយអ្នកតា ឬហៅម្យ៉ាងទៀតថា ធ្វើបុណ្យឡើងអ្នកតា ដើម្បីសម្រេចបានសេចក្ដីសុខ សេចក្ដីចំរើន នៅពេលដែលពួកគេជួបប្រទះ នឹងគ្រោះធម្មជាតិផ្សេងៗដូចជា គ្មានភ្លៀង គេធ្វើបុណ្យ ឡើងអ្នកតា ដើម្បីសុំទឹកភ្លៀង។

នៅតាមតំបន់ខ្លះ គេធ្វើបុណ្យឡើងអ្នកតានៅហាលថ្ងៃ ឬដុតកំដៅដើម្បីឱ្យអ្នកតាផ្តល់ទឹកភ្លៀង។ ទំនៀម



*លោកតា លោកយាយ*



*ខ្ទមអ្នកតា ឬអាសនៈលោកតា លោកយាយ*

ទំលាប់នេះ បានជះឥទ្ធិពលថែមទៀតដូចជានៅពេលគ្មានភ្លៀងធ្លាក់ គេតែងតែនិមន្តព្រះសង្ឃទៅសូត្រមន្តហាលថ្ងៃ ដើម្បីសុំទឹកភ្លៀងដែរ។ ដោយសារជំនឿទៅលើព្រលឹងរបស់មនុស្សជំនាន់ដើមនេះហើយ ទើបព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ដែលមានជំនឿទៅលើព្រលឹងរបស់មនុស្សនោះ បានជ្រៀតចូលមកផ្សព្វផ្សាយក្នុងសង្គមខ្មែរបានដោយងាយ។ ទន្ទឹមនឹងនេះដែរ មនុស្សខ្មែរដើម មានជំនឿគោរពទីកន្លែងដែលខ្ពស់ដូចជា ភ្នំ ដំបូក ដើមឈើធំៗ ពីព្រោះគេយល់ថាជាកន្លែងអារក្ស អ្នកតាស្នាក់នៅ។ ដោយសារតែខ្មែរដើមមានជំនឿលើទីកន្លែង ដែលខ្ពស់នេះហើយ បានជាលោក "**អាម៉ូនីញេ**" ពន្យល់ពីការកសាងប្រាសាទភ្នំថា ក៏មានការទាក់ទងទៅនឹងជំនឿបែបនេះដែរ។

ម្យ៉ាងទៀត អ្នកស្រុកដើមមានជំនឿលើ ទឹក ដី ភ្លើង ខ្យល់ សុទ្ធតែជាអាទិទេពទាំងអស់ ដែលឱ្យសេចក្តីសុខ ឬសេចក្តីទុក្ខដល់គេ ដូច្នេះហើយបានជានៅពេលមានភ្លៀងធ្លាក់ធំ មានខ្យល់បោកបក់ខ្លាំង គេតែងតែអុជធូបសូមអង្វរព្រះអាទិទេពទាំងនោះ ដើម្បីអនុគ្រោះដល់ពួកគេ។ ក្នុងការប្រកបរបរចិញ្ចឹមជីវិត ក៏គេអុជធូប ដើម្បីសុំសេចក្តីសុខចំរើនពីព្រះភូមិដែរ " សែនក្រុងពាលី "។

សរុបសេចក្តីមក ជនជាតិអូស្ត្រូអាស៊ីមានវប្បធម៌ អរិយធម៌របស់ខ្លួនមួយយ៉ាងច្បាស់លាស់ រួចជាស្រេចទៅហើយ មុនពេលទទួលយកវប្បធម៌របស់ជនជាតិមួយទៀត ចំណែកខ្មែរបានទទួលឥទ្ធិពលវប្បធម៌ អរិយធម៌ភាគច្រើនពីឥណ្ឌា នៅក្នុងកំឡុងសតវត្សទី ២ មុនគ.ស ពិសេសគឺ **អសោកមហារាជ** ដែលបានបញ្ជូនសាមណេរសង្ឃពីរអង្គគឺឧត្តរត្ថេរ និង **សោណត្ថេរ** មកផ្សព្វផ្សាយពុទ្ធសាសនានៅភូមិភាគអាស៊ីអាគ្នេយ៍យើង។

*តើព្រះពុទ្ធសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នបានជួយអ្វីខ្លះ ដល់សង្គមខ្មែរយើងទាំងខាងផ្លូវលោក និងខាងផ្លូវធម៌ ?*



✡ *ខាងផ្លូវលោក :* វត្តអារាមតាំងពីបុរាណកាលមក បានជួយទ្រទ្រង់យ៉ាងខ្លាំងក្លា ដល់សង្គមខ្មែរយើង រហូតមកដល់បច្ចុប្បន្ននេះ រួមមាន ÷

- បានជួយថែរក្សា ការពារ កសាងវប្បធម៌ អរិយធម៌ ទំនៀមទំលាប់ ប្រពៃណីខ្មែរ ឱ្យស្ថិតស្ថេរ នៅគង់វង្សពីជំនាន់មួយទៅជំនាន់ មួយ។
- ជាសាលារៀន និងជាឃ្លាំងសំរាប់ផ្ទុកគម្ពីរក្បួនខ្នាត សម្រាប់បណ្តុះពូជធារគ្រប់បែបយ៉ាង តាមរយៈការសិក្សារៀនសូត្រតៗគ្នា ធ្វើបុណ្យទាន រក្សាសីល និងសេចក្តីភាវនា ជាដើម។

• ជាសាលាពហុបច្ចេកទេស ដែលបណ្តុះបណ្តាល នូវវិជ្ជាជីវៈគ្រប់បែបយ៉ាង ពីព្រោះថាវត្តអារាមជំនាន់ដើម គេបានបណ្តុះបណ្តាល ធម្មវិន័យ ធម៌អាថ៌ និងគ្រប់កិច្ចការដែលមានក្នុងសង្គមដូចជា ជាងសាងសង់ផ្ទះសំបែង តោក គ្រឿង កព្រៃ្លង នង្គ័លរនាស់ ល្បី .....។

• ជាមន្ទីរពេទ្យព្យាបាលរោគាព្យាធិ ដោយការស្រោចទឹក (សូត្រមន្តរំដោះគ្រោះ) និងទេសនាអប់រំខាង ផ្លូវចិត្តគំនិតជាដើម។

• ជាមជ្ឈមណ្ឌលផ្សព្វផ្សាយសាមគ្គីធម៌ និងបណ្តុះគំនិតឯកភាពជាតិ រួមចំណែកកសាងសមិទ្ធផលគ្រប់បែប យ៉ាង ដើម្បីបម្រើសង្គមជាតិ។ *ឧទាហរណ៍ៈ* ធ្វើបុណ្យយកបច្ច័យកសាងផ្លូវថ្នល់ ធ្វើស្ពាន ស្រះ អណ្តូង ប្រឡាយ ទំនប់ ទឹក ឬដាំដុះដើមឈើផ្សេងៗ។



• ដឹកនាំមនុស្សឱ្យស្រឡាញ់បរិស្ថាន ធម្មជាតិ ដឹកនាំមនុស្សឱ្យស្រឡាញ់លិទ្ធិប្រជា-ធិបតេយ្យ គោរពសិទ្ធិគ្នាទៅវិញទៅមក ក្នុង គោលបំណងរក្សា ឱ្យបាននូវវប្បធម៌សន្តិភាព ពីព្រោះថា ព្រះពុទ្ធគឺជាមេដឹកនាំនៃលិទ្ធិប្រជា-ធិបតេយ្យមុនគេ តាមរយៈពុទ្ធវចនៈ ៨៤០០០ ធម្មក្ខន្ធនោះឯង។

• ជាកន្លែងរំងាប់អារម្មណ៍ ស្រាយ បញ្ហាទំនាស់វិបត្តិគ្រប់បែបយ៉ាង ដោយឈរ លើគោលជំហរកាយកម្មបី (ដោយកាយ) វចី កម្មបួន (ដោយវាចា) និងមនោកម្មបី (ដោយ ចិត្ត)។

• ជាជម្រកស្នាក់អាស្រ័យរបស់អ្នក ដំណើរជិតឆ្ងាយ សិស្ស និស្សិត និងទុរគតជន គ្រប់ប្រភេទ ដែលគ្មានបងប្អូនពឹងពាក់អាស្រ័យ នៅទីនោះ។

✡ ***ខាងផ្លូវធម៌ ៈ*** តាមពុទ្ធវចនៈទាំង ៨៤០០០ ធម្មក្ខន្ធរបស់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គ

តែងតែអប់រំទូន្មានប្រៀនប្រដៅ ឱ្យប្រព្រឹត្តតែអំពើល្អគ្រប់បែបយ៉ាងតាមរយៈ កាយ វាចា ចិត្ត សមស្របទៅនឹង




តែងតែអប់រំទូន្មានប្រៀនប្រដៅ ឱ្យប្រព្រឹត្តតែអំពើល្អគ្រប់បែបយ៉ាងតាមរយៈ កាយ វាចា ចិត្ត សមស្របទៅនឹង ច្បាប់រស់នៅរបស់មនុស្ស ( ច្បាប់រដ្ឋ ) និងស្របទៅតាមលទ្ធិប្រជាធិបតេយ្យ ដើម្បីកសាងសង្គមមួយមានសច្ចៈធមិ គុណធមិ តម្លាភាព និងភាពរុងរឿង ឆ្ពោះទៅ នីតិរដ្ឋ។

# អំពីសាសនា

សាសនាក្លាយមកពីពាក្យថា : សាសនៈ ដែលមានន័យថា បណ្តាំ ការទូន្មានប្រៀនប្រដៅ ការអប់រំ ។ សាសនា ជាទ្រង់ទ្រាយ នៃមនសិការសង្គម នៃរចនាសម្ព័ន្ធជាន់ខ្ពស់ ដែលឆ្លុះបញ្ចាំងដោយការរវើរវាយស្រមើស្រមៃ ក្នុងខួរក្បាលរបស់មនុស្ស ។ អត្ថន័យ នៃពាក្យសាសនា ឬលទ្ធិសាសនាពុំមែនស្ថិតនៅតែត្រង់ជំនឿ បញ្ញាធម៌ និងការគោរពប្រណិបតន៍ប៉ុណ្ណោះទេ គឺត្រូវមានអង្គការពិសេសមួយ សម្រាប់ទ្រទ្រង់ ថែរក្សាលទ្ធិសាសនានោះ ឱ្យមានស្ថេរភាពតាំងនៅជាស្ថាបពរវែងឆ្ងាយតទៅទៀត ។

នៅលើលោកយើងនេះ មានសាសនាជាច្រើនដូចជា សាសនាព្រាហ្មណ៍ ឬព្រហ្មញ្ញសាសនា ( មានប្រភពដើមមកពីប្រទេសឥណ្ឌា ) ព្រះពុទ្ធសាសនា ( មកពីប្រទេសឥណ្ឌា ) សាសនាគ្រីស្ត ( មានប្រភពមកពីប្រទេសហេព្រឺ ) សាសនាឥស្លាម ( មានប្រភពមកពីប្រទេសអារ៉ាប់) សាសនាតៅ ( មានប្រភពមកពីប្រទេសចិន ) សាសនាស៊ិនតូ ( មានប្រភពមកពីប្រទេសជប៉ុន ) និងសាសនាជេន ( មានប្រភពមកពីប្រទេសឥណ្ឌា ) ។

## I. ប្រភពនៃសាសនា

*តើជនជាតិខ្មែរយើងដំបូងឡើយមានសាសនាដែរឬទេ ?*

ក្នុងសម័យបុព្វកាល ការរស់នៅរបស់មនុស្ស តែងតែជួបប្រទះ នូវការលំបាកនឹងបាតុភូតផ្សេងៗ របស់ធម្មជាតិ ។ រាល់បាតុភូតទាំងអស់តែងតែគំរាមកំហែង ដល់ជីវភាពរស់នៅរបស់មនុស្ស ធ្វើឱ្យមនុស្សខ្លបខ្លាច ចុះញ៉មពីព្រោះមនុស្សមានកម្រិតយល់ដឹងទាប ពុំមានលទ្ធភាពពន្យល់ភាពពិត និងអាចិកំបាំងនៃធម្មជាតិទាំងអស់នោះបានទេ ។ គេជឿថា គ្រប់បាតុភូត នៃការភ័យក្លាចរន្ធត់ញាប់ញ័រ ដែលកើតឡើងជាប្រចាំក្នុងខ្លួនមនុស្ស គឺនៅពេលនោះហើយដែលសាសនាកើតមានឡើង ។ ដូច្នេះ គេក៏ជឿថា គ្រប់បាតុភូតទាំងអស់ សុទ្ធតែកើតឡើងដោយសារនរណាម្នាក់ជាអ្នកបង្កើត ខ្មែតនោះ គឺជាព្រះអាទិទេពនេះឯង ។ មនុស្សជឿថា ទឹក ដី ភ្លើង ខ្យល់ ភ្លៀង សុទ្ធតែជាអាទិទេពនេះឯង ។

សាសនាមានប្រភពមួយទៀត គឺនៅក្នុងរបបបែងចែកវណ្ណៈ ក្រោយពេលដែលរបបទាសភាព " សហគមបុព្វ - កាល" បានបាត់បង់ទៅ របបបែងចែកវណ្ណៈ ក៏កើតមានឡើង ។ ក្នុងសង្គមចែកវណ្ណៈ មានវណ្ណៈជិះជាន់បានកេងប្រវ័ញ្ចជិះជាន់យ៉ាងព្រៃផ្សៃទៅលើវណ្ណៈ ដែលត្រូវគេជិះជាន់យ៉ាងឃោរឃៅជាទីបំផុត ។

បណ្តាកុប្បកម្មរបស់វណ្ណៈ ដែលត្រូវគេជិះជាន់ ត្រូវបានគេវាយរំលំរំលាយពន្លិចទាំងអស់ វណ្ណៈនេះមិនដឹងរកផ្លូវណាមួយ ដើម្បីរំដោះខ្លួនឱ្យផុតពីការរស់នៅយ៉ាងវេទនាជាក់ស្តែងនេះបាន គេក៏រកមធ្យោបាយថ្មី គឺការរំដោះចិត្តរំដោះគំនិត ដើម្បីឱ្យរស់នៅប្រកបដោយសេចក្តីសុខសុភមង្គលទៅជាតិក្រោយ គឺឋានសួគ៌ ឋាននិព្វាន..... ។ នេះ ក៏ជាប្រភពនាំ ឱ្យសាសនាកើតឡើងដែរ ។

## II. ព្រហ្មញ្ញសាសនា

ព្រហ្មញ្ញសាសនា ឬព្រាហ្មណ៍សាសនា ជាសាសនាមួយរបស់ជនជាតិឥណ្ឌា ដែលគេបានគោរពនៅឆ្នាំ ១៥០០ មុន គ.ស (Avent J.C)។ សាសនាព្រាហ្មណ៍ បានចូលមកដល់ប្រទេសកម្ពុជាតាមរយៈឈ្មួញ ដែលបានធ្វើដំណើរតាមសំពៅមកលក់ដូរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ម្យ៉ាងទៀត ការហូរចូល នៃឥទ្ធិពលសាសនាតាមកតាមរយៈព្រះបាទ **ហ៊ុនទៀន** *Hun Tien* ដែលជាកូនស្តេច នៃប្រទេសឥណ្ឌាបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាង **លីវ យី** ក្រោយពីការវាយលុកលុយមកលើកោះគោកធ្លកនៅសតវត្សទី ១។ តាមការសិក្សាស្រាវនៃសាសនា គេចែកជា ៣ ដំណាក់កាលធំៗគឺ ÷

១- សម័យវេទនិយម : *Védisme* " ១៥០០-១៥៥០ មុនគ.ស" Avant J.C

២- សម័យព្រាហ្មណ៍និយម : *Brahmanisme* " ១៥៥០ មុនគ.ស ដល់ សតវត្សទី ១០ នៃគ.ស "

៣- សម័យហិណ្ឌូនិយម : *Hindouisme* "សតវត្សទី ១០ ដល់ បច្ចុប្បន្ន "

### ១. វេទនិយម Védisme

វេទនិយម គឺជាលទ្ធិបុរាណមួយនៅប្រទេសឥណ្ឌា។ ពួកព្រាហ្មណ៍បានចាត់ទុកថា វេទគឺជាពុទ្ធិដ៏ពិសិដ្ឋ ដែលអាទិទេពធ្វើអំណោយឱ្យ ពីព្រោះអាទិទេពបានប្រគល់ឱ្យមនុស្សដើមដំបូងបំផុតនៅក្នុងលោកយើងនេះ មនុស្សបានផ្សាយគម្ពីរវេទដល់ពួកឥសី ។ ពួកឥសីបានបង្រៀនវេទមន្តដល់ពួកព្រាហ្មណ៍ បង្រៀនតាមការយល់ឃើញ ការសូត្រតាម គ្មានសិទ្ធិជជែករកខុសត្រូវ ពីព្រោះគេយល់ថា ព្រះអាទិទេពមានលក្ខណៈសច្ចៈរួចទៅហើយ។ ដូច្នេះ ពួកព្រាហ្មណ៍មានសិទ្ធិផ្តាច់មុខ ក្នុងការផ្សព្វផ្សាយ និងកាន់កាប់គម្ពីរវេទ។ គម្ពីរវេទ បានផ្លាស់ប្តូរទៅតាមការវិវត្តដូចខាងក្រោម ÷

- សម័សំហិតា
- សម័យព្រាហ្មណ៍
- សម័យអារណ្យកៈ
- សម័យឧបនិស័ទ

❖ **គម្ពីរសំហិតា**

គម្ពីរសំហិតា គឺជាកម្រងកំណាព្យ ដែលនិយាយអំពីការកោតសរសើរដល់អាទិទេព និងគុណូបការៈរបស់អាទិទេព ដែលប្រោសសត្វលោក។

❖ **គម្ពីរព្រាហ្មណ៍**

គម្ពីរព្រាហ្មណ៍ គឺជាពាក្យផ្តែផ្តាំរបស់ព្រះព្រហ្មឱ្យដល់ព្រាហ្មណ៍ ស្តីពីការបួងសួងអាទិទេព ធ្វើឱ្យមនុស្សមានជំនឿយ៉ាងក្លាំងក្លា។

❖ **គម្ពីរអារណ្យកៈ**

គម្ពីរអារណ្យកៈ គឺជាគម្ពីរដែលនិយាយអំពីមន្តអាគម សម្រាប់សូត្រក្នុងព្រៃ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ទាំងឡាយ។

❖ **គម្ពីរឧបនិស័ទ**

គម្ពីរឧបនិស័ទ គឺជាគម្ពីរមួយ ស្ថិតនៅក្នុងសម័យវេទ ដែលបានលើកឡើងវិញ នូវគម្ពីរទាំង ៣ ខាងលើ និងបទបញ្ហាផ្សេងៗ ដល់ពួកព្រាហ្មណ៍ដទៃទៀត ។ គម្ពីរនេះ បានអធិប្បាយអំពីការកើត - ស្លាប់របស់មនុស្ស ។

**គ. អាត្ម័ន Ame Uiverselle**

នៅពេលដែលមនុស្សស្លាប់ទៅ អាត្ម័នបានទៅជួបនឹងព្រហ្ម័ន ។ អាត្ម័ន គឺជាសារជាតិដ៏បរិសុទ្ធបែកចេញពីព្រហ្ម័ន ។ ក្រោយពីជួបគ្នានឹងព្រហ្ម័នហើយ ត្រូវសម្រេចទៅតាមកម្មិន " កម្មរបស់ខ្លួន " ។ ការជួយព្រហ្ម័ន ឬមិនជួយ ស្រេចតែទៅលើកម្មិន ។

ព្រហ្ម័ន គឺជាភាវៈទាំងឡាយ ដែលកើតឡើងដោយសារធាតុបរិសុទ្ធរបស់ព្រះព្រហ្ម ដែលជាអាទិទេព Dieu ។ តាមគម្ពីរឧបនិស័ទ ព្រហ្ម័ន " មេព្រលឹង " សម្គាល់ព្រលឹងសកលហៅថា មេព្រលឹង = ព្រលឹងធំ នៅក្នុងព្រលឹងធំមានព្រលឹងតូចហៅថា អាត្ម័ន " *Âme Universelle* " ។ ដូចនេះ ព្រហ្ម័ន និងអាត្ម័នមានធាតុតែមួយឯកភាវៈ ។ គេអាចប្រៀបធៀបព្រហ្ម័ន-អាត្ម័នទៅនឹងទឹកសមុទ្រ ទឹកភ្លៀង ទឹកសន្សើម ដែលជាធាតុតែមួយ ពីព្រោះធាតុទាំងអស់នេះសុទ្ធតែចេញពីមហាសមុទ្រដូចគ្នា ។

នៅពេលដែលមនុស្សស្លាប់ទៅ រូបរាងកាយត្រូវវិនាស តែអាត្ម័នពុំស្លាប់ទេ ។ អាត្ម័ន បានចេញពីរូបរាងកាយ ហើយទៅចូលក្នុងរូបរាងកាយថ្មីទៀត ។ កាលដែលទៅចូលក្នុងរូបរាងកាយថ្មីនេះ ដោយសារកម្លាំងមួយ ហៅថា "កម្មិន" គឺជាការវិលទៅវិលមកក្នុងវាលវដ្តសង្សារ "ការវិលកើត វិលស្លាប់ " ។ កម្មិន ឬកម្ម សម្គាល់ផ្លូវល្អ ឬផ្លូវអាក្រក់ទៅតាមផ្លូវកាយ ផ្លូវចិត្ត ដែលយើងបានប្រព្រឹត្តក្នុងសាសនាព្រាហ្មណ៍ មានន័យថា ÷

- សម្គាល់បុព្វហេតុនៃការកើត-ស្លាប់
- សម្គាល់នូវទំនាក់ទំនងអំពើ និងផល ។ អំពើ ដែលបានធ្វើមិនសាបរលាបនោះទេ វាតែងតែទាក់ទងគ្នាជានិច្ចក្នុងបច្ចុប្បន្នកាល ឬអតីតកាល និងអនាគតកាល ។

**១. ត្រៃវេទ** : គម្ពីរវេទមាន ៣ ដែលគេហៅថាត្រៃវេទនោះ ÷

*១- ឫកវេទ* Regveda

*២- សាមវេទ* Samveda

*៣- យជុរវេទ* Yajurveda

ក្រោយមកគេបន្ថែមគម្ពីរមួយទៀត គឺគម្ពីរទី ៤ អថិវវេទ

❖ *គម្ពីរឫកវេទ*

គម្ពីរឫកវេទ គឺជាគម្ពីរដែលសរសេរអំពីអាទិទេព និងទេវៈផ្សេងៗ សម្រាប់បួងសួងអង្វរអាទិទេព ទេវៈឱ្យបានសំរេច ។

❖ *គម្ពីរសាមវេទ*

សាមវេទគម្ពីរ គឺជាគម្ពីរ សំរាប់ឱ្យទន់ចិត្ត " បន្ទន់ " ទេវៈផ្សេងៗ ក្នុងពេលមានពិធីបូជា។

❖ *គម្ពីរយជុរវេទ*

គម្ពីរយជុរវេទ គឺជាគម្ពីរ សំរាប់បួងសួងអាទិទេពឱ្យមានអំណាច សិរីសួស្តី។

❖ *គម្ពីរអថិរវេទ*

គម្ពីរអថិរវេទ គឺជាគម្ពីរមន្តអាគមគាថា សូត្របណ្តេញព្រាយបីសាច អារក្សអ្នកតា និងមន្តអាគមផ្សេងៗ ដទៃទៀត។

**២. ពុទ្ធិចំពោះអាទិទេព**

ព្រាហ្មណ៍សាសនា ក៏ត្រូវយល់ថា អាទិទេព គឺជាទេវៈធំបង្អស់ ដែលកើតមុនគេបំផុតក្នុងលោកស្វ័យម្ភូ "ដោយឯកឯង " មានតួនាទីជាអ្នកបង្កើតលោក ថែរក្សាលោក និងបំផ្លាញលោក។ ដូច្នេះហើយ បានជាដើម្បីឱ្យរស់នៅក្នុងលោក បានជួបនឹងសេចក្តីសុខក្សេមក្សាន្ត ចៀសផុតពីទុក្ខសោកជាយថាហេតុ ព្រាហ្មណ៍សាសនិក ត្រូវតែគោរពអាទិទេព ដើរតាម ឱវាទអាទិទេព " គម្ពីរវេទ " និងមានភក្តីភាពចំពោះអាទិទេព។

អាទិទេពមានគុណសម្បត្តិ ១០ ប្រការ ដែលព្រាហ្មណ៍សាសនិកគួរគោរពប្រណិប័តន៍តាម។ គុណសម្បត្តិទាំង ១០ ប្រការនោះ រួមមាន ៖

- *ស្វយម្ភូ* : កើតឯង
- *អមតៈ* : មិនចេះស្លាប់ មិនបាត់បង់ មិនសាបសូន្យ
- *មហត្តៈ* : សម្បើម អស្ចារ្យ
- *មហិទ្ធិ* : គ្មានគូរប្រជែង គ្មានគូរប្រដូច
- *តេជៈ* : ឫទ្ធិបារមីដ៏ខ្លាំងក្លា
- *សព្វបញ្ញា* : ចេះដឹង យល់សព្វគ្រប់សេចក្តី
- *ញាណ* : ភ្នែកទិព្វ ត្រចៀកទិព្វ
- *ព្រហ្មចារ្យ* : ប្រកបទៅដោយព្រហ្មវិហារធម៌
- *និមល* : គ្មានមន្ទិលសៅហ្មង ស្អាតបរិសុទ្ធ
- *សច្ចៈ* : ទៀងទាត់ គ្មានលំអៀង

**៣. ពុទ្ធិចំពោះភាវៈលោកៈ ក្នុងវដ្តសង្សារ**

ព្រាហ្មណ៍សាសនិក ត្រូវយល់ថាភាវលោកក្នុងចក្រវាឡនេះ មានទាំងកម្មៈ (កម្ម) អាត្មន ព្រហ្មន

មនុស្ស សត្វ ទឹកដី រុក្ខជាតិ ភ្លើង ខ្យល់។ ធម្មជាតិទាំងអស់នេះ សុទ្ធតែបានកើតឡើង រីកដុះដាលឡើង និងពេល រលត់ទៅវិញ ដោយសារអំណាចមហិទ្ធិឫទ្ធរបស់អាទិទេព ។ ពោលគឺ អាទិទេពជាម្ចាស់ភាវលោកៈ ក្នុងចក្រវាឡ ដែល បង្កឱ្យភាវលោក មានការប្រែប្រួល ផ្លាស់ប្តូរសភាពពុំទៀងទាត់ស្ថិតស្ថេរ។

*វដ្តសង្សារ* : គឺជាដំណើរអន្ទោលទៅមក វិលកើត វិលស្លាប់ ឬជាដំណើរកើតស្លាប់ ស្លាប់កើត វិលចុះវិល ឡើង ដូចកង់ចក្រវាឡ។

*សង្សារវដ្ត* : គឺជាប្រភពទុក្ខសោករបស់មនុស្ស ភាវលោក " ជីវិត " ដែលកើតឡើងដោយសារកម្មៈ និង អាត្ម័នផ្តាច់ខ្លួនចេញពីព្រហ្ម័ន។ ព្រហ្ម័នជាបឋមវិញ្ញាណ ដែលដូចជាផ្កាភ្លើងខ្ទាតចេញពីរងើកភ្លើង ឬប្រៀបដូចជាដំណក់ ទឹកភ្លៀង ដែលកើតចេញពីទឹកសមុទ្រ ។ អាត្ម័នរបស់ភាវលោក ដែលដឹកនាំដោយកម្មៈ កម្រនឹងមានឱកាសចាកចេញ ផុតពីសង្សារវដ្តទៅជួបនឹងព្រហ្ម័នវិញឡើយ ជូនអន្ទោលយោនកកើតជាមនុស្ស សត្វ ធម្មជាតិ មិនទៀងសោះឡើយ។

*មនុស្ស* : ជាភាវៈលោក ដែលមានជីវិត មានចលនា " កម្មៈ" និងមានគំនិតបញ្ញា "អាត្ម័ន " ។ មនុស្ស កើត ឡើងដោយសារព្រះព្រហ្ម "ព្រហ្ម័ន" បញ្ជូនអាត្ម័នឱ្យមកយោនកំណើតក្នុងភាវលោកៈ។ ដូច្នេះ ហើយបានជាមនុស្ស ត្រូវរស់នៅជាភាវលោកមានជាន់ថ្នាក់ ខ្ពស់ ទាប ខុស១គ្នាទៅតាមកម្មៈជាអ្នកកំណត់ " មនុ " ក្នុងម្ពីរវេទបានថែងថា ÷

- ត្រកូលព្រាហ្មណ៍ កើតពីមាត់ព្រាហ្មណ៍
- ត្រកូលក្សត្រ កើតពីទ្រូងព្រះព្រហ្ម
- ត្រកូលវៃស្សៈ កើតចេញពីភ្លៅព្រះព្រហ្ម
- ត្រកូលសូទ្រៈ កើតចេញពីជើងព្រះព្រហ្ម

ដោយកំណើតមនុស្សកើតឡើងពីកាលរបស់ព្រះព្រហ្មខុសគ្នាដូចនេះហើយ ទើប " ច្បាប់មនុ "កំណត់មនុស្ស ឱ្យមានវណ្ណៈផ្សេង១ពីគ្នា ទៅតាមកាយព្រះព្រហ្មគឺ ÷

- វណ្ណៈព្រាហ្មណ៍ ស្លៀកពាក់ស ជាអ្នកផ្សាយសាសនា
- វណ្ណៈក្សត្រ ស្លៀកពាក់ក្រហមជាអ្នកធ្វើសឹក
- វណ្ណៈវេស្សៈ ស្លៀកពាក់លឿងជាអ្នកធ្វើជំនួញ
- វណ្ណៈសូទ្រៈ ស្លៀកពាក់ខ្មៅ ជាទាសករ កម្មករ

លុះក្រោយមកដោយសារ ពួកព្រាហ្មណ៍មិនចង់ឱ្យវណ្ណៈទាំងបួនចងសម្ព័ន្ធវង្សនឹងគ្នា ពិសេសបើវណ្ណៈ ព្រាហ្មណ៍ វណ្ណៈក្សត្រ និងវណ្ណៈវេស្សៈចងសម្ព័ន្ធនឹងវណ្ណៈសូទ្រៈ ដែលជាវណ្ណៈថោកទាប ក្នុងសង្គម ទើបពួកព្រាហ្មណ៍ ដាក់បញ្ញត្តិ នូវវណ្ណៈទាំងនេះ កើតឡើងដោយសារបាទជើងព្រះព្រហ្ម។

ដោយមធ្យោបាយនេះហើយ ទើបសាសនាហិណ្ឌូនិយមថែរក្សាវណ្ណៈភាពក្នុងសង្គមបាន។ ប៉ុន្តែទោះបីជា យ៉ាងណាក៏ដោយ ក៏ច្បាប់មនុ នៅបានលើកតម្កើងមនុស្សជាងគេ ក្នុងចំណោមភាវៈលោកនេះ ដូចយ៉ាងទស្សនៈថែងថា

" ប្រពៃបំផុត នៃភាវលោក គឺភាវៈមានជីវិត ប្រពៃបំផុត នៃភាវៈមានជីវិត គឺភាវៈសត្វមានចលនា ប្រពៃបំផុត នៃភាវៈសត្វមានចលនា គឺសត្វមានបញ្ញា ប្រពៃបំផុតនៃសត្វមានគំនិតបញ្ញា គឺមនុស្ស ប្រពៃបំផុតក្នុងចំណោមមនុស្ស គឺវណ្ណៈព្រាហ្មណ៍។

តាមរយៈទស្សនៈ " ច្បាប់មនុ " គឺជាពុទ្ធិពិសិដ្ឋរបស់គម្ពីរវេទនេះ ដែលស្តែងឱ្យឃើញថាវណ្ណៈព្រាហ្មណ៍ជាស្រទាប់មនុស្សឧត្តុងឧត្តមប្រសើរ បរិសុទ្ធ នៅក្នុងសង្គម។

*កម៍: ឬ កម៌ន* ជាកម្លាំងរុញច្រានអាត្ម័នឱ្យដាច់ពីព្រហ្ម័ន និងជាកម្លាំងរុញច្រានអាត្ម័នឱ្យវិលវល់ក្នុងវដ្តសង្សារជួប សុខទុក្ខ គ្រប់បែបយ៉ាង។ ដូច្នេះ កម៌នហាក់បីដូចជាសម្គាល់នូវភាវអាក្រក់ពីរយ៉ាងគឺ ÷

- ម្យ៉ាងសម្គាល់ បុព្វហេតុនៃអំពើបន្តគ្នា ក្នុងការបង្កើតភាវលោកក្នុងវដ្តសង្សារ
- និងម្យ៉ាងទៀត សម្គាល់នូវទំនាក់ទំនងបីជាប់គ្នាជិតស្និទ្ធជានិច្ចកាលរវាងអំពើ និងផល

ដូច្នេះកម៌ន អាចកំណត់ដល់ភាវៈជារង្វាន់ និងភាវៈជាទោសរបស់អាត្ម័ន ពុំអាចហាមឃាត់បានឡើយ ដូចយ៉ាង អំពើខ្លះធ្វើហើយហុចផលភ្លាមៗ រីឯអំពើខ្លះទៀតធ្វើហើយ តែពុំបានហុចផលភ្លាមក្តី ក៏ទៅអនាគតនឹងតាមរុញច្រានអាត្ម័ន ឱ្យទទួលផលធ្ងន់ ឬស្រាលទៅតាមកម៌នមិនលែងឡើយ។

អាត្ម័នជាឯកធាតុមួយពិសេស ដែលបែកចេញមកអំពីព្រហ្ម័នចូលមកសណ្ឋិតក្នុងរូបរាងកាយមនុស្ស សត្វគ្រប់រូបក្នុងលោក។ អាត្ម័ន និងព្រហ្ម័ន គឺជាធាតុតែមួយ ដែលប្រៀបបីដូចជាទឹកសមុទ្រ និងទឹកភ្លៀងជាធាតុទឹកតែមួយ ដូចគ្នា គ្មាននរណាបង្កើតនរណាឡើយ។

អាត្ម័នកាលបើឃ្លាតឆ្ងាយពីព្រហ្ម័នហើយ ពុំងាយនឹងបានត្រឡប់ទៅជួបព្រហ្ម័នវិញបានដោយងាយឡើយ ព្រោះ កម៌នជាបាបកម្មរាំងស្ទាក់ដំណើរអាត្ម័ន។ កម៌ន បានបណ្តាលឱ្យអាត្ម័នទទួលរងនូវផលផ្សេងៗ ទៅតាមរូបកាយដែលអាត្ម័នសណ្ឋិតនៅ ហើយវិលវល់ក្នុងសង្សារវដ្តរកទីបំផុតគ្មានឡើយ។ អាត្ម័នប្រៀបបីដូចជាទឹកភ្លៀង ដែលកើតពីចំហាយទឹកសមុទ្រ នៅពេលធ្លាក់មកផែនដីវិញមិនងាយនឹងបានហូរចូលសមុទ្រវិញណាស់។ ប៉ុន្តែអាត្ម័ន បើបានទៅជួបព្រហ្ម័នហើយឈ្មោះថារួចផុតពីសង្សារវដ្ត គឺមោក្សៈ ប្រកបដោយបរិបណ្ណសុខដ៏បរិសុទ្ធ ពោលគឺ អាត្ម័នលែងវិលមកចូលរូបរាងកាយមនុស្សសត្វទៀតហើយ។

ព្រហ្ម័ន ជាភាវៈដើមនៃលោក និងជាព្រលឹងសកល សំរាប់បង្កើតអាត្ម័ននៃលោក។ ជារួមព្រហ្ម័ន គឺជាភាវៈដែលកើតឡើងដោយសារភាគល្អិតៗ និងភាពបរិសុទ្ធរបស់ព្រះព្រហ្ម ហើយក៏ជាទេវបង្កើតចក្រវាឡ។

សរុបសេចក្តីមក នៅក្នុងវដ្តសង្សារ មនុស្ស សត្វ រងទុក្ខទោសកើតស្លាប់ ស្លាប់កើតដោយសារអាត្ម័នជាប់ជំពាក់នឹងកម៌ន។ ដូចនេះ ដើម្បីរំដោះអាត្ម័នឱ្យទៅជួបនឹងព្រហ្ម័ន ដែលជាទីបរមសុខនោះ មនុស្សត្រូវតែខិតខំប្រឹងសាងអំពើជាកុសលកម្ម និងសំអាតកាយវាចាចិត្ត ឱ្យបានស្អាតបរិសុទ្ធ ប្រាសចាកគ្រឿងមន្ទិលសៅហ្មង ដោយប្រព្រឹត្តប្រតិបត្តិតាមដំបូលន្មាន នៃគម្ពីរវេទ។

### ៤. ពុទ្ធិចំពោះការប្រតិបត្តិក្នុងសាសនា

ដោយគម្ពីរវេទចែងថា " ភាវលោក សុទ្ធតែកើតឡើងដោយអាទិទេព " ដូច្នេះ អាទិទេពអាចឱ្យសុខ ទុក្ខ ល្អ អាក្រក់ ចំរើន វិនាស ដល់មនុស្ស សត្វប្រគប់រូបទាំងអស់។ ពោលគឺ ដើម្បីបានសេចក្ដីសុខសប្បាយក្សេមក្សាន្តចាកទុក្ខទោស ក្នុងវដ្ដសង្សារ និងដើម្បីរំដោះអាត្ម័នឱ្យទៅជួបនឹងព្រហ្ម័នវិញ ព្រាហ្មសាសនិកត្រូវប្រតិបត្តិតាមបទបញ្ញត្តិរបស់វេទ ÷

❖ *ប្រតិបត្តិវិធីព្រហ្មចារ្យ* : ជាពិធីអប់រំចិត្តកាយ អត្តបុគ្គលម្នាក់ៗឱ្យប្រព្រឹត្តតែកុសលកម្មបរិសុទ្ធដូចព្រះព្រហ្ម ពោលគឺ លះបង់ឱ្យអស់នូវចំណង់តណ្ហា ក្នុងវដ្តសង្សារមានទាំងកូន ប្រពន្ធ ទ្រព្យសម្បត្តិ កិត្តិយស.... ហើយទៅស្វែងរកពុទ្ធិសាកល្យ " ធម៌ប្រកបដោយព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា ឧបេក្ខា " ផ្សព្វផ្សាយដល់សត្វសព្វលោក។ វិធីព្រហ្មចារ្យ បានដល់ការតម្កល់ចិត្តកាយនៅក្នុងព្រហ្មវិហារធម៌ ដើម្បីរំដោះអាត្ម័នឱ្យចេញពីកម៌ន។

❖ *ប្រតិបត្តិវិធីយោគៈ* : ជាវិធីអប់រំចិត្តឱ្យនឹងហ្នរ បរិសុទ្ធឥតមន្ទិលសៅហ្មង ពោលគឺតម្កល់ចិត្តឱ្យស្ថិតនៅក្នុងសភាពស្ងប់ កុំឱ្យរំជើបរំជួល កក្រើករំពើកទៅតាមកម៌នដែលជាអកុសលកម្ម។ វិធីយោគៈ បានដល់ការហាត់ដកដង្ហើមតាំងស្មារតីឱ្យស្ថិតនៅក្រោមសតិសម្បជញ្ញៈ ដឹងខុសត្រូវ គុណទោស ល្អអាក្រក់ ពោលគឺទូន្មានអប់រំចិត្ត ត្រិះរិះពិចារណាតម្រង់ស្មារតីទៅរកភាពបរិសុទ្ធរបស់អាទិទេពទាំង ១០ ប្រការ ដើម្បីរំដោះអាត្ម័នឱ្យទៅជួបនឹងព្រហ្ម័នវិញ។

❖ *ប្រតិបត្តិវិធីតបៈ* : ជាវិធីអប់រំកាយឱ្យប្រព្រឹត្តតែកុសលកម្មបរិសុទ្ធ ប្រាសចាកគ្រឿងសៅហ្មង ដោយតម្រង់ទៅរកអាទិទេពធ្វើជាសាក្សី និងឱ្យអាទិទេពចុះមកប្រទានពរឱ្យសម្រេចតាមបំណងប្រាថ្នា។ វិធីតបៈ មានន័យបីយ៉ាងក្នុងការប្រតិបត្តិ ពោលគឺ ÷

- ម្យ៉ាង គឺការព្យាយាមគោរពអាទិទេព ដោយភក្តីភាព ដើម្បីឱ្យអាទិទេពពេញព្រះទ័យ។
- ម្យ៉ាងទៀត គឺការដុតខ្លួនឯង ដើម្បីឱ្យអាទិទេពក្តៅក្រហល់ក្រហាយ រំជើបរំជួល ហើយចុះមកប្រទានពរជ័យ។
- ម្យ៉ាងវិញទៀត បានដល់ការធ្វើទុក្ខកិរិយា ដើម្បីឱ្យរំលត់នូវចំណង់កិលេសតណ្ហា ដែលជាកម៌ននៃវដ្តសង្សារឱ្យចេញផុតពីរូបកាយ ដើម្បីរំដោះអាត្ម័នឱ្យទៅជួបនឹងព្រហ្ម័នវិញ។ ការប្រព្រឹត្តទុក្ខកិរិយានេះ មិនទាក់ទងនឹងអាទិទេពទេ គឺគេធ្វើយ៉ាងណាឱ្យអាត្ម័នស្អប់ខ្ពើមរូបកាយ ហើយផ្តាច់ខ្លួនចេញពីកម៌នប៉ណ្ណោះ ដូចយ៉ាងអត់អាហារ សំរាកហាលថ្ងៃ សំរាកក្នុងទីងងឹតស្អុះស្អាប់ពិបាកទ្រាំ សំរាកត្រាំទឹក ព្យាយាមិននិយាយស្តី ព្យាយាមមិនដកដង្ហើមតាមកាលកំណត់ជាដើម.....។

❖ *ប្រតិបត្តិវិធីអគ្គិហោត្រ ឬហោមវិធី* : ជាវិធីបូជាភ្លើង ដោយដុតភ្លើងទាំងយប់ទាំងថ្ងៃថ្វាយអាទិទេព ឱ្យប្រទានពរជ័យ។ វិធីអគ្គិហោត្រនៅក្នុងគម្ពីរវេទ ចាត់ទុកជាកំពូលនៃការបូជា ពោលគឺបើបូជាដោយមិនប្រារព្ធធ្វើពិធីហោមនេះទេ អាទិទេពមិនទទួលនូវដង្វាយទាំងនោះឡើយ ដូច្នេះ អ្នកដែលប្រតិបត្តិតាមនោះ ក៏មិនបានសម្រេចតាមបំណងរបស់ខ្លួនដែរ ពីព្រោះអាទិទេពមិនសប្បាយព្រះទ័យនឹងការបូជានោះទេ។ ដូច្នេះហើយ បានជារាល់ការបូជា

អាទិទេពនានា បើមិនមានធ្វើពិធីអគ្គីហោត្រនោះទេ គេតែតែអុជទៀន ធូប ប្រទីបជ្វាលា ជាជំនួយ ពីព្រោះគម្ពីរវេទ ចែងថា "អគ្គិហោត្រសុខាបញ្ញ ប្រែសេចក្តីថា គ្រឿងបូជាទាំងឡាយមានការបូជាភ្លើងជាប្រធាន។

❖ *ប្រតិបត្តិវិធីបូជាយញ្ញ* : ជាវិធីបូជាម្យ៉ាង ដោយយកមនុស្ស សត្វទាំងរស់ទៅដុតក្នុងគំនរភ្លើងឆេះសន្ធោរ សន្ធៅ ដើម្បីថ្វាយអាទិទេពឱ្យសប្បាយចិត្ត បំណងសុំឱ្យអាទិទេពប្រសិទ្ធិពរជ័យឱ្យសម្រេចតាមបំណង។

❖ *ប្រតិបត្តិវិធីលាងបាប ឬពិធីសិវរាត្រី* : ជាពិធីមួយ ដែលគេធ្វើរំលឹកដល់រាត្រីដែលព្រះឥសូរឱ្យកំណើតលោក។ ពិធី នេះ គេរៀបធ្វើតែក្នុងវេលាយប់ ហើយក្នុងមួយឆ្នាំប្រារព្ធបានតែម្តងប៉ុណ្ណោះ។ នៅពេលយប់នៃពិធីនេះ គេនាំគ្នា



*ព្រះព្រហ្មអាទិទេពចំបង ក្នុង សាសនា ព្រាហ្មណ៍*

ទៅមុជទឹកក្នុងទន្លេគង្គា ដើម្បីលាងបាបចង្រៃឧបទ្រពគ្រប់បែបយ៉ាង ដោយបរិកម្មថា " គង្គា ! គង្គា ! " ។ ចំណែករីឯ អ្នកដែលរស់នៅឆ្ងាយពីទីស្ថានទន្លេគង្គា គេអាចទៅមុជទឹកលាងបាបនៅតាមស្ទឹង ឬទន្លេណាដែលនៅជិត ហើយសន្និដ្ឋាន ឬសន្មត់ថា ជាទន្លេគង្គា ដោយពេលងូតលាងបាប ត្រូវធ្វើបរិកម្មថា " គង្គា ! គង្គា ! "។ នៅពេលងូតទឹកលាងបាបហើយ គេត្រូវយកទឹកទៅកាន់ទេវស្ថាន ដើម្បីយកទៅស្រោចស្រពសិវលិង្គ ហើយត្រង់ទឹកដែលហូរតាមយោនីនាងឧមា ដែលជា ទម្ររបល្ល័ង្គតម្កល់លិង្គព្រះឥសូរនោះ មកស្រោចស្រពក្បាល ស្រឡាបខ្លួន និងបរិភោគទៅតាមបំណងប្រាថ្នា ចំណែកឯ

អ្នកដែលមិនបានមកចូលរួមពិធីនេះ អាចទទួលបញ្ញើពីអ្នកដែលបានចូលរួម ហើយយកទៅស្រោចស្របកាយជំរះនូវឧបទ្រពចង្រៃ បានដូចបំណងប្រាថ្នាដែរ។

សរុបសេចក្តីមក ពុទ្ធិទាំងបីនេះហើយ ដែលបានចងភ្ជាប់មនុស្សឱ្យមានជំនឿយ៉ាងមុតមាំទៅលើអាទិទេពនៃ ព្រហ្មញ្ញសាសនា។ ដោយគម្ពីរវេទ ដែលជាពុទ្ធិសិដ្ឋ ដែលមានចែងនៅបញ្ញាទាំងឡាយ ក៏ជាទម្រង់គ្រឹះ នៃព្រហ្មញ្ញសាសនានេះហើយ ទើបទោះបីសាសនាព្រាហ្មណ៍ប្រែប្រួលយ៉ាងណា ក៏នៅតែផ្តេកផ្តួលលើពុទ្ធិនៃគម្ពីរវេទនេះដែរ។







*អាទិទេពធំៗ ៣ អង្គ (ព្រះព្រហ្ម ព្រះសីវៈ ព្រះវិស្ណុ ) ជាអាទិទេពត្រីមូ៌តិ ដែលស្ថិតនៅក្នុងសាសនាព្រាហ្មណ៍*

**ខ_ទម្រង់វិវត្តនៃសាសនាព្រាហ្មណ៍**

គឺជាទម្រង់ប្រែប្រួល នៃសាសនាព្រាហ្មណ៍ទៅតាមសម័យកាលនីមួយៗរបស់ព្រាហ្មណ៍សាសនិកក្នុងការគោរព ទេវៈ និងប្រតិបត្តិទៅតាមពុទ្ធិគម្ពីរវេទ។ បើពិនិត្យជារួម ឃើញថា ព្រាហ្មណ៍សាសនាវិវត្តបីដំណាក់កាលធំៗ គួរឱ្យកត់សម្គាល់ គឺ ÷

- សម័យវេទ ឬវេទនិយម

• សម័យព្រាហ្មណ៍ ឬព្រាហ្មណ៍និយម

• សម័យហិណ្ឌូ ឬហិណ្ឌូនិយម

ក្នុងការប្រែប្រួល នៃសាសនាព្រាហ្មណ៍តាំងពីសម័យកាលខាងលើនេះ នាំឱ្យមានកើតឡើងនូវគម្ពីរអដ្ឋកថាបួនទៀត សម្រាប់ជាជំនួយពុទ្ធិក្នុងគម្ពីរវេទ ដែលរួមមាន ÷

✡ គម្ពីរសំហិតា

✡ គម្ពីរព្រាហ្មណ៍

✡ គម្ពីរអរណ្យកៈ

✡ គម្ពីរឧបនិស័ទ

**១‐ សម័យវេទ ឬវេទនិយម**

ជាសម័យកាលដំបូង នៃសាសនាហិណ្ឌូ។ សម័យវេទរាប់ចាប់តាំងពីឆ្នាំ ១៥០០ មុនគ.ស ពោលគឺចាប់តាំងពីពួកអារ្យ៉ននាំនាំលទ្ធិវេទនិយមមកផ្សព្វផ្សាយនៅលើទឹកដីឥណ្ឌាមកម្លេះ។ សម័យវេទ បុព្វជិតព្រាហ្មណ៍គោរពទៅតាមបទបញ្ញតិ នៃគម្ពីរវេទទាំងស្រុង រួមនឹងគម្ពីរសំហិតាផង។

នៅសម័យវេទនេះ គម្ពីរសំហិតាក៏ជាគោល នៃបទនមស្សការ និងស្តុតីអាទិទេព ត្រូវបានពង្វក់ចិត្តបុព្វជិតព្រាហ្មណ៍ ឱ្យជឿស៊ប់តែទៅលើអាទិទេព បដិសេធនូវរាល់អំពើរផ្ទាល់របស់អត្តៈ។ ដូច្នេះហើយ ដើម្បីឱ្យខ្លួនបានជួបសេចក្តីសុខក្សេមក្សាន្តក្នុងលោកីយ៍ និងដើម្បីទៅកើតនៅឋានព្រហ្មលោក ព្រាហ្មណ៍សាសនិក ត្រូវធ្វើវិធីតបៈ ដើម្បីបន្ទន់ចិត្តអាទិទេព ដោយមានធ្វើហោមពិធី និងពិធីបូជាយញ្ញជាដើម។

នៅសម័យវេទ គេនិយមជឿថាអាទិទេពធំចំបងជាងគេ គឺព្រះឥន្ទ្រ ព្រះឥន្ទ្រជាអាទិទេពបង្កើតលោក ដូចក្នុងគម្ពីរសំហិតាចែងថា " ព្រះឥន្ទ្របង្កើតលោក ដោយយកសរសរមកដាំ ហើយផ្ទៃខាងលើយកមេឃធ្វើជាដំបូល រួចបង្កើតបុរិសៈឡើង ដែលជាមនុស្សដំបូងនៅលើពិភពលោកនេះ " ។

នៅសម័យវេទ ព្រាហ្មណ៍សាសនិកយកទៅតាមគម្ពីរវេទទាំងស្រុង ដោយឥតលម្អៀងគឺ លោកកើតដោយអាទិទេព។ ក្រៅពីព្រះឥន្ទ្រដែលជាអាទិទេពចំបង នៅមានអាទិទេពបន្ទាប់បន្សំជាច្រើនទៀត ដែលជាទេវតំណាងឱ្យធម្មជាតិ ទឹកដី នៃប្រទេសឥណ្ឌា ដែលរួមមានដូចជា ព្រះអាទិត្យ ព្រះច័ន្ទ ព្រះគង្គា ព្រះពាយ ព្រះធរណី ព្រះភិរុណ ព្រះអគ្គី និងព្រះយមជាដើម។

លុះមកដល់សម័យចុងវេទ ព្រះឥន្ទ្រត្រូវចុះថយឥទ្ធិពល។ ព្រាហ្មណ៍សាសនិកងាករេទៅរកទេវមួយអង្គទៀត ដែលមានលក្ខណៈបរិសុទ្ធឥតមន្ទិលសៅហ្មង ព្រោះព្រះឥន្ទ្រមានគុណវិបត្តិជាច្រើន ដូចជាចូលចិត្តក្រេបសុរា ល្មោភកាមគុណ និងចាញ់សឹកសង្គ្រាមជាច្រើនលើកច្រើនសារ។ ទេវថ្មីនេះ ត្រូវបានតាក់តែងឡើងដោយមនោគមរបស់បុព្វជិតព្រាហ្មណ៍ គឺព្រះព្រហ្ម មានន័យថាបរិសុទ្ធឥតមន្ទិលសៅហ្មង។

## ២. សម័យព្រាហ្មណ៍ ឬព្រាហ្មណ៍និយម

ជាសម័យ ដែលព្រាហ្មណ៍សាសនិកនិយម ទៅតាមទ្រឹស្តី ដែលបុព្វជិតព្រាហ្មណ៍ប្រតិបត្តិ។ សម័យព្រាហ្មណ៍និយមមានការជឿនលឿនច្រើនជាងសម័យវេទនិយមដែលទ្រឹស្តីខ្លះនៅជារបស់អារ្យ៉ននៅឡើយ។ បុព្វជិតព្រាហ្មណ៍ ក្រៅពីគោរពប្រតិបត្តិតាមគម្ពីរវេទ គេនៅមានសំអាងទៅតាមគម្ពីរព្រាហ្មណ៍ និងគម្ពីរអរណ្យកៈទៀត។




តាមរយៈគម្ពីរព្រាហ្មណៈ គេយល់ថា ព្រះព្រហ្ម ជាទេវចំបងបំផុតដែលបានបង្កើតលោក និងទេវទាំងឡាយ។ ពោលគឺ កាលដើមឡើយ ព្រះព្រហ្មជាសភាវធមិមានលក្ខណៈបរិសុទ្ធ ជាម្ចាស់សួគិស្ថិតនៅខ្លួនឯង គ្មាននរណាស្គាល់។ ព្រះព្រហ្មក៏បង្កើតទឹក ហើយដាក់គ្រាប់ពូជជាមួយ ក្នុងនោះគ្រប់ពូជ " ព្រហ្ម័ន " បានកើតឡើងជាស៊ុតមាសមួយមានពន្លឺដូចព្រះអាទិទេព ទឹកដែលព្រះព្រហ្មបង្កើតនោះ មានឈ្មោះថា "នរណៈ" ដែលជាធាតុបង្កើតនរៈដំបូង ក្នុងវដ្តសង្សារ។ ស៊ុតមាសនេះ កកើតឡើងក្នុងន័យអាថិកំបាំងជាភាវៈ និងជាសភាវៈផង។ ព្រហ្ម័ន រស់នៅក្នុងស៊ុតមាសអស់រយៈពេល ១០០ ឆ្នាំ ក៏បែកស៊ុតនោះ ហើយបង្កើតបានជាពិភពលោក និងបុរុសៈ។ បុរុសៈជាបឋមនុស្សនៅលើលោកនេះ ហើយបានបង្កើតមនុស្ស និងទទួលគម្ពីរវេទពីព្រះព្រហ្មមកប្រគល់ឱ្យមនុស្ស។ តាមទស្សនៈនេះ យើងឃើញថា ព្រះព្រហ្មជាម្ចាស់សួគិផង ជាម្ចាស់លោកផង និង ជាម្ចាស់វេទផង។




ក្នុងសម័យព្រាហ្មណ៍និយម ព្រាហ្មណ៍សាសនិកគោរពបូជាព្រះព្រហ្មជាអាទិទេពចំបង រីឯអាទិទេព ក្នុងសម័យវេទនិយមបានក្លាយទៅជាទេវ

បន្ទាប់បន្សំវិញ ។ ដូច្នេះ ដើម្បីសុំពរពីព្រះព្រហ្ម ព្រាហ្មណ៍សាសនិក តែងតែប្រតិបត្តិពិធីបូជាយញ្ញ ពិធីបូជាភ្លើង "អគ្គិហោត្រ" និងធ្វើតបៈធម៌ឱ្យក្ដៅរំជើប រំជួលដល់ព្រះព្រហ្ម។

លុះមកដល់ចុងសម័យព្រាហ្មណ៍ ក៏កើត មានទេវពីរទៀត គឺ ÷

- *ព្រះវិស្ណុ* ជាទេវថែរក្សាលោក
- *ព្រះសិវៈ* ជាទេវបង្កើតលោក និងបំផ្លាញ លោក។

ដោយមានកើតឡើង នូវទេវពីរទៀតយ៉ាងនេះហើយ ទើបព្រាហ្មណ៍សាសនិកមានការបែកបាក់និកាយគោរពបូជាទេវ គឺខ្លះគោរពបូជាព្រះព្រហ្ម ខ្លះនិយមគោរពបូជាព្រះវិស្ណុ និងខ្លះទៀតនិយមគោរពបូជាព្រះសិវៈ។ បញ្ហាបែកបាក់ផ្ទៃក្នុងមិនឯកភាពគ្នានេះហើយ ទើបបុព្វជិតព្រាហ្មណ៍ក៏បង្រួមទេវទាំងបីឱ្យមកនៅជាទេវតែមួយវិញ ហៅថា អាទិទេពត្រីមូតិ ដូចក្នុងគម្ពីរឧបនិស័ទមានចែងស្រាប់។

## ៣~ ទម្រង់អត្ថិភាពនៃសាសនាព្រាហ្មណ៍ " ឥណ្ឌូនិយម " (សម័យហិណ្ឌូនិយម)

ជាសម័យចុងក្រោយបង្អស់ នៃការវិវត្តរបស់សាសនាព្រាហ្មណ៍។ សម័យហិណ្ឌូ អាចចាតទុកថាជាចំណុចកំពូល នៃមនសិការរបស់ប្រជាជនឥណ្ឌា ក្នុងការគោរពសាសនាព្រាហ្មណ៍។ សម័យហិណ្ឌូនិយមស្ដែងឱ្យឃើញនូវស្មារតីជាតិនិយម របស់ប្រជាជនឥណ្ឌា ក្នុងការដោះស្រាយទំនាស់វិបត្តិមនសិការសង្គមតាមរយៈសាសនា និងពង្រឹងទស្សនាទានរបស់សាសនាព្រាហ្មណ៍ ឱ្យមានលំនឹង ពោលគឺមានអត្ថិភាពជានិរន្តន៍ នៅលើទឹកដីឥណ្ឌា។



ដោយនៅចុងសម័យព្រាហ្មណ៍និយមមានការបែកបាក់ផ្ទៃក្នុង ទើបបុព្វជិតព្រាហ្មណ៍បានចែងនូវគម្ពីរឧបនិស័ទឡើង ដើម្បីជាជំនួយដល់គម្ពីរវេទ ក្នុងការប្រតិបត្តិធម៌ និងចៀសវាងនូវសង្គ្រាមសាសនា។ គម្ពីរឧបនិស័ទបានចែងថា " ព្រះឥស្វរៈ ជាកំពូលនៃព្រះអាទិទេព ដែលជាម្ចាស់សួគ៌ ម្ចាស់លោក និង ជាម្ចាស់វេទ ព្រះអង្គបានបែងចែកជាអវតាបីអង្គ គឺព្រះព្រហ្ម ព្រះវិស្ណុ និងព្រះសិវៈ "។ ដោយសារទស្សនៈត្រីមូតនៃគម្ពីរឧបនិស័ទនេះហើយ ដែលធ្វើឱ្យព្រាហ្មណ៍សាសនិកនិយមរាប់អាន រួមនឹងការព្យាយាមបូកសរុប

នូវជំនឿដទៃផ្សេងៗទៀត នៅលើទឹកដីរបស់ប្រទេសឥណ្ឌាផង ទើបសាសនាព្រាហ្មណ៍ ក្លាយមកជាការនិយមរបស់ប្រជាជាតិហិណ្ឌូ រហូតមកទល់នឹងសព្វថ្ងៃនេះ។

ដូចនេះ លក្ខណៈពិសេសនៃសាសនាហិណ្ឌូនិយម គឺជាការសំយោគទេវ ហៅថាទស្សនៈត្រីមូតិ និងការសំយោគជំនឿ ទំនៀមទំលាប់ប្រពៃណី ការគោរពបូជាវត្ថុស័ក្តិសិទ្ធិលើទឹកដីហិណ្ឌូ។

នៅសម័យហិណ្ឌូនិយម ដើម្បីរំដោះអាត្មันពីកមិនឱ្យទៅជួបនឹងព្រហ្មន៍វិញ ព្រាហ្មណ៍សាសនិកប្រតិបត្តិតាមនូវពិធីតបៈ ពិធីយោគៈ ពិធីអគ្គីហោត្រ ពិធីបូជាយញ្ញ ពិធីសិវៈរាត្រី និងពិធីព្រហ្មចារ្យជាដើម។ ការប្រតិបត្តិ ក្នុងសម័យហិណ្ឌូមានលក្ខណៈសុក្រឹត ដោយពួកបុព្វជិតព្រាហ្មណ៍ បានប្រមូលទស្សនៈ នៃគម្ពីរអដ្ឋក ថាសម័យវេទ និងសម័យព្រាហ្មណ៍និយម បញ្ចូលជាគម្ពីរឧបនិស័ទ ដើម្បីជំនួយដល់ភាគីវេទ។ ដូច្នេះហើយ បានជានៅសម័យហិណ្ឌូអាទិទេពក៏សំបូរបែប ហើយមានមុខងារច្បាស់លាស់ទៀត។



**ខ. ទម្រង់អាទិទេពនៃព្រាហ្មណ៍សាសនា**

ដូចបានរៀបរាប់ខាងលើមកហើយថា អាទិទេព គឺស្ថិតនៅក្នុងទម្រង់គ្រឹះ នៃសាសនាព្រាហ្មណ៍។ សាសនាព្រាហ្មណ៍ មានការវិវត្តឥតឈប់ឈរ ដោយសារបញ្ហាជំនឿរបស់ព្រាហ្មណ៍សាសនិក ក្នុងការគោរពបូជាអាទិទេព។ ជាទូទៅនៅក្នុងសាសនាព្រាហ្មណ៍ ទោះបីកើតឡើងដោយមធ្យោបាយបែបណាក្តី ក៏ត្រូវមានលក្ខណៈសម្បត្តិប្រកបដោយគុណធមិដប់ប្រការខាងលើនេះដែរ ។



**◎ ទេវធំៗ នៃទស្សនៈត្រីមូតិ**

១. ព្រះព្រហ្ម :

មានឈ្មោះហៅច្រើនយ៉ាង ដូចជា ÷

- *អាត្មាភូ* មានន័យថា អ្នករស់នៅដោយខ្លួន

ឯង គ្មានពឹងអ្នកដទៃ

- *លោកេស* មានន័យថា អាទិទេពនៃពិភព លោក
- *ហិរណ្យគត៌* មានន័យថាអ្នក ដែលចេញផុតពីស៊ុតមាស

ព្រះព្រហ្ម ជាអាទិទេពចំបងបំផុត ព្រោះជាទេវមាននាទីបង្កើតលោក ( *Dieu Créateur Du* Monde ) ភាវៈ ធម្មជាតិ និងគម្ពីរវេទ។ ព្រហ្មសាសនិក កសាងបដិមាព្រះព្រហ្មជាព្រាហ្មណ៍មានកាយសម្បុរក្រហម មានហង្ស ជាយានជំនិះ។ ព្រះព្រហ្មមានមុខបួន តំណាងព្រហ្មវិហារធម៌ ដែលផ្សព្វផ្សាយដល់សព្វសត្វ មានព្រហស្ថបួនកាន់វេទ ថូផ្កា ចាស និងស្លាបព្រា។ ព្រះអង្គមានមហេសីតែមួយនាម **សរស្វតី** ហើយប្រសូត្របានបុត្រីបីអង្គគឺ **ព្រះទក្សៈ ព្រះភតិ** និងព្រះនាង **សន្ធិយា**។

២. ព្រះសីវៈ មានន័យថា " ក្សេមក្សាន្ត ករុណា "។ ទស្សនៈខ្លះយល់ថា ព្រះសីវៈកើតឡើងពីការបែងភាគ របស់ព្រះឥស្វរៈ និងខ្លះទៀតយល់ថា ព្រះអង្គកើតឡើងពីតំណក់លោហិត ដែលស្រក់ចេញពីចិញ្ចើមព្រះព្រហ្ម។ ព្រះសីវៈ មានតួនាទីជាអាទិទេពសាងលោក និងបំផ្លាញលោក។ ព្រះអង្គមាននាមឈ្មោះច្រើនយ៉ាងទៅតាមការនិយមហៅ ដែល រួមមាន ÷

ព្រះឥស្វរៈ ព្រះឥសូរ ព្រះរុទ្រៈ ព្រះហរៈ ព្រះឧគ្រៈ ព្រះអឃោរៈ ព្រះភៃរវៈ និង ព្រះមហេស្វរៈ ជាដើម។

ព្រះសីវៈ មានមហេសីចំនួន ៩ នាក់គឺ ÷

- នាងទុគ៌ា ស្រីចេះធ្វើមិនដឹង មិនឮ
- នាងឧមា ស្រីជាទីពេញចិត្ត
- នាងគោរី ស្រីសម្បុរទង់ដែង
- នាងកាលី ស្រសីសម្បុរខ្មៅ
- នាងចន្ទី ស្រីកំណាច
- នាងបវ៌តី ស្រីបុរទីម្ចាស់ភ្នំ
- នាងកុមារី ស្រីក្រមុំព្រហ្មចារី
- នាងទេវី ស្រីទេពកញ្ញា
- នាងមហាទេវី ស្រីទេពអប្សរ



***លិង្គរបស់ព្រះឥស្វរ***

ព្រះសីវៈមានបុត្រីពីរអង្គគឺ ព្រះគនេស និងព្រះស្កន្ធៈ ដែលខ្លះយល់ថាជាកូននាងទុគ៌ា ខ្លះយល់ថាជាបុត្ររបស់ នាង **ឧមា**។ ព្រះសីវៈ មានលំនៅស្ថាននៅលើកំពូលភ្នំកៃឡាស។

ព្រាហ្មណ៍សាសនិក កសាងបដិមាព្រះសីវៈជាព្រាហ្មណ៍មានកាយសម្បុរ ស មានមុខមួយ ប៉ុន្តែអាចបែងបាន មុខ ៥ មានកពណិខៀវ មានភ្នែកបី គឺភ្នែកពីរដូចមនុស្សធម្មតា និងភ្នែកមួយទៀតនៅលើថ្ងា ស ហៅថា "អគ្គិនេត្រ "។ អគ្គិនេត្រនេះ កាលណាបើកឆេះ និងមានដៃ ២ ឬ ១០។ ព្រះអង្គគ្រង ÷

• សម្លៀកបំពាក់ស្បៀកខ្លា ឬស្បែកដំរី

• មាននាគពាក់ជាសង្វារ ជាគ្រឿងសម្គាល់រាប់ឆ្នាំ

• កម្រងឆ្អឹងលលាដ៏ក្បាល ពាក់គ្រឿងសម្គាល់រាប់កប្បឬយុគ្គ

• ពាក់មួក មានព្រះច័ន្ទមួយចំណិត ជាគ្រឿងសម្គាល់រាប់ខែ

• មានកាន់ត្រីសូល៍ ខ្សែផ្តាំ ឬគទា " ដំបង " ជាគ្រឿងសម្គាល់កេតនភ័ណ្ឌ និងមានគោនិទ្ទជាយានជំនិះ ។



៣. ព្រះវិស្ណុ

ព្រះអង្គ ជាអាទិទេពដែលស្រោចស្រង់លោក ទ្រទ្រង់លោក និងចំរើនលោក ។ គេនិយមហៅព្រះវិស្ណុថា ព្រះនារាយណ៍ ព្រះភគវន្ត ព្រះអនន្ត ព្រះហរិ ។ ព្រះអង្គគង់នៅលើវិមានទិព្វជាមួយមហេសីពីរអង្គ គឺនាងលក្ស្មី និងព្រះនាងស្រី ដែលមានបុត្រម្នាក់ព្រះនាម គាម ។

ព្រាហ្មណ៍សាសនិក កសាងរូបបដិមាព្រះវិស្ណុជាព្រាហ្មណ៍ មានដៃពីរ ឬបួន ឬប្រាំបី គ្រងសម្លៀកបំពាក់ពណ៌លឿង កាន់កងចក្រ ដំបង ផ្កាឈូក ខ្យងស័ង្ខ ដាវធ្នូ កំសៀវទឹក ជាគ្រឿងសម្គាល់កេតនភ័ណ្ឌ ។ ព្រះវិស្ណុគេកសាងឱ្យគង់នៅលើផ្កាឈូក ឬជិះគ្រុឌ ពីព្រោះព្រះអង្គមានគ្រុឌជាយានជំនិះ ។

ដោយសារព្រះវិស្ណុជាអាទិទេពថែរក្សាលោក ទើបព្រះអង្គតែងតែជួយយិតយោងស្រោចស្រង់លោកមនុស្សលោកឱ្យចំរើន សុខក្សេមក្សាន្ត ចាកផុតទុក្ខលំបាក ដោយសារភាវៈអាក្រក់មកយាយី ។ អវតាព្រះវិស្ណុ " ការបែងភាគ " ទាំង ១០ របស់ព្រះអង្គជាសាក្សីរួមមាន ÷

*មត្ស្យ: Matsya* ជាត្រីជួយស្រោចស្រង់ជីវិតមនុស្ស ឱ្យរួចផុតពីទឹកជំនន់ ដែលបង្កើតឡើងដោយឈ្មោះហយគ្រាវៈ ។

*កុម៌: Kurma* ជាអណ្តើកជួយធ្វើកំណល់ភ្នំមន្ទរៈ ដើម្បីឱ្យទេវតា និងយក្សយកនាគវាសុកៈចងបង្វិលភ្នំកូរសមុទ្រទឹកដោះឱ្យរឹងស្ងួត និងយកទឹកអម្រឹត " អមតៈ " មកផឹកកុំឱ្យស្លាប់ ។

*វារាហៈ: Varaha* ជាជ្រូកព្រៃបានបំផ្លាញយក្សហិរណ្យ ដែលបានប៉ុនប៉ងរំលាយលោកឱ្យទៅជាទឹកសមុទ្រ ។

*នរសិង្ហ* Narasinha ជាមនុស្សសិង្ហ ក្បាលមនុស្ស ខ្លួនសិង្ហ បានបំផ្លាញយក្សហិរណ្យៈ ដើម្បីកុំឱ្យវារុកគួនទេវស្ថាន និងមនុស្សកាន់សាសនា។

*វាមនៈ* Vamuna ជាមនុស្សតឿ ដែលបានប្រើល្បិចកលសំដីយក្សបីជំហានទុកឱ្យមនុស្សរស់នៅ។

*បរសុរាម* Paracurama ជាមនុស្សកាន់ពូថៅ ដែលបានបង្ក្រាបយក្សត្រអរជុន។

*រាម* Rama ជាព្រះរាមក្នុងរឿងរាមាយណៈ ដែលបានបង្ក្រាបក្រុងរាវណៈ "រាពណ៍"។

*ក្រឹស្ណ* Krusma ជាព្រះគ្រឹស្ណៈ ក្នុងរឿងមហាភា រតយុទ្ធ ដែលបានជួយមនុស្សឱ្យរួចផុតពីគ្រោះថ្នាក់នៃវន្ទះបាញ់ ដោយលីភ្នំបារ័តនៈបាំងការពារ។

*ពុទ្ធ* Buddha ជាព្រះពុទ្ធសាមណគោត្តម ដែលបានជួយស្រោចស្រង់ដាស់តឿនមនុស្សលោក ឱ្យស្គាល់បុណ្យបាបអាក្រក់ល្អ វៀរចាកបាបកម្មទាំងឡាយ។ តាមពិតព្រះពុទ្ធមិនមែនជាអវតាទេ តែដោយឃើញព្រះអង្គមានអនុភាពខ្លាំងក្លានៅក្នុងសង្គមឥណ្ឌា ពួកព្រាហ្មណ៍ក៏រាប់ព្រះពុទ្ធបញ្ចូល ដើម្បីប្រមូលព្រាហ្មណ៍សាសនិកឱ្យបានច្រើន។

*កល្កិន* Kalkin ជាមនុស្សសេះ គឺមានដងខ្លួនជាមនុស្ស ក្បាលជាសេះ ហើយជាអវតាចុងក្រោយបង្អស់។ កល្កិនទៅអនាគត នឹងចុះមកជួយកាត់ទោសមនុស្សប្រព្រឹត្តអំពើអាក្រក់ ហើយផ្តល់រង្វាន់ឱ្យមនុស្សប្រព្រឹត្តល្អ និងរៀបចំយុគ្គថ្មីមួយឱ្យបានរុងរឿង។



***រូបបដិមារបស់ព្រះកល្កិន***

អាទិទេព ព្រះព្រហ្ម ព្រះសីវៈ និងព្រះវិស្ណុ ក្នុងទស្សនៈត្រូម៉ូតិតាមគម្ពីរឧបនិស័ទថា កើតឡើងពីការបែងភាគរបស់ព្រះឥស្វរៈទុកជាទីសក្ការៈបូជា ហើយបានប្រសិទ្ធិនាមថា : ព្រះហរិហរៈ គឺមួយចំហៀងខាងឆ្វេងព្រះហរិ និងមួយចំហៀងខាងស្តាំជាព្រះហរៈ។

**ទេវបន្ទាប់បន្សំដែលកើតឡើងដោយមនោគតិ**

១. ព្រះឥន្ទ្រ : កាលនៅសម័យវេទ គេបានចាត់ទុកជា អាទិទេពចំបងបង្កើតលោកភាវៈ ប៉ុន្តែមកដល់សម័យព្រាហ្មណ៍ និងសម័យហិណ្ឌូ ត្រូវចុះមកជាទេវបន្ទាប់បន្សំវិញ។ ពីព្រោះព្រះឥន្ទ្រជាស្តេច នៃពួកទេវតា មាននាមឈ្មោះហៅច្រើនយ៉ាង ÷ ព្រះសក្កទេវរាជ ព្រះទេវិន្ទ្រ និងព្រះសហស្សនយន៏ ទ្រង់គង់នៅស្ថានត្រៃត្រឹង្ស។ ព្រះឥន្ទ្រជាអាទិទេពតំណាងឱ្យ ផ្គរ រន្ទះ។ ព្រាហណ៏សាសនិក កសាងរូបបដិមារបស់ព្រះឥន្ទ្រ ជាក្សត្រមានសម្បុរកាយខៀវ ទ្រង់កាន់ដំបង

ពេជ្រ ដែលជានិមិត្តរូបរន្ទះ ព្រះខ័ណ្ឌត្រីសូល៍ និង ជួនកាលកាន់ថាស ពូថៅ និងកង្វេរ ហើយគង់នៅលើដំរីព្វរ៉ាវ៉ន ជួនគង់នៅលើរថមាសទឹមសេះ មានមាតុសីទេវបុត្រជាសារថី។

**២. ព្រះស្កន្ទៈ** : ព្រះអង្គជាបុត្រព្រះសិវៈ មាននាទីជាមេទ័ពនៃពួកទេវតា។ គេកសាងបដិមាព្រះស្កន្ទៈ ជាព្រាហ្មណ៍ព្រះកេសមួយ ឬប្រាំមួយ មានព្រហស្តពីរ ឬដប់ពីរ ទ្រង់កាន់ធ្នូ ដាវ ពូថៅ និងរន្ទះ ជាកេតនភ័ណ្ឌ ហើយគង់នៅលើក្ងោកជាយានជំនិះ។

**៣. ព្រះគនេស** : ព្រះអង្គជាបុត្ររបស់ព្រះសិវៈ មានតួនាទីជាតុលាការ នៃពួកទេវតា និងមនុស្ស។ គេកសាងរូបបដិមាព្រះគនេស ជាមនុស្សក្បាលដំរី មានដៃបួនកាន់ចាន គង់នៅលើសត្វកណ្តុរជាជំនិះ។

**៤. ព្រះយមៈ** : មាននាមហៅថា ព្រះយមរាជា និង ព្រះធម្មរាជា ព្រះអង្គជាអាទិទេព នៃសេចក្តីស្លាប់។ គេកសាងរូបបដិមាព្រះអង្គ មានខ្លួនខៀវស្រងាត់ ព្រះនេត្រឆេះជាភ្លើងស្បៀកសម្លៀកបំពាក់ក្រហមដូចឈាម ទ្រង់កាន់ដំបងយមភ័ណ្ឌជាអាវុធ និងខ្សែរមួយចង្វាយ សម្រាប់ទាក់ទាញវិញ្ញាណក្ខន្ធសត្វលោក ឬជួនកាលកាន់ពូថៅ ព្រះខ័ន ដាវ ហើយគង់នៅលើសត្វក្របីជាយានជំនិះ។

**៥. ព្រះកាម** : ព្រះអង្គ ជាបុត្រារបស់ព្រះវិស្ណុ មានតួនាទីជាទេវស្នេហា និងសេចក្តីត្រេកត្រអាល។

**៦. ព្រះពលទេព** : មាននាមហៅថា ព្រះសីរិន និង ព្រះសីរបាណី ជាអាទិទេពតំណាងឱ្យពូជធញ្ញាហារ និង ព្រះរាជពិធីច្រត់ព្រះនង្គ័ល។ ព្រះពលទេព ជាព្រះអានុជរបស់ព្រះក្រឹស្ណៈ គេកសាងរូបបដិមាព្រះអង្គ ជារូបព្រាហ្មណ៍ មានកាន់នង្គ័លធ្វើជាអាវុធ។

**៧. ព្រះអគ្រស់** : ជាអាទិទេពមួយ " យមបាល " មានតួនាទីកាន់បញ្ជីមរណៈសត្វលោក ព្រះអង្គជាសេនាដៃស្តាំរបស់ព្រះយម។






ព្រះគនេស ជាបុត្ររបស់ព្រះសីវៈ




៨. **ព្រះចិត្តកុម្ភ** : ជាអាទិទេព " យមបាល " ជាសេនាដៃឆ្វេងរបស់ព្រះយម មានតួនាទីជាស្មៀន និង ជាអវិតាសូត្រវិនាការទូលស្នើព្រះយម ពីមរណភាពរបស់សត្វលោក ។

៩. **ព្រះនាងលក្សី** : ជាមហេសីរបស់ព្រះវិស្ណុ ព្រះនាងជាទេវ ដែលបានកើតឡើងពីការកូរសមុទ្រទឹកដោះដូច្នេះហើយ ទើបព្រះនាងមានតួនាទីជាទេវតំណាងឱ្យទ្រព្យសម្បត្តិ និងភាពបរិសុទ្ធ ។

១០. **ព្រះនាងស្រី** : ជាមហេសីរបស់ព្រះវិស្ណុ ព្រះនាងជាទេវតំណាងឱ្យសោភ័ណភាព និងជាទេវតំណាងឱ្យសិរីសួស្តី នៃស្ថានវៃកុណ្ឋ ។

១១. **ព្រះនាងសរស្វតី** : ជាមហេសីរបស់ព្រះព្រហ្ម ព្រះនាងជាទេវតំណាងឱ្យភាពបរិសុទ្ធ និងប្រាជ្ញាស្មារតី ។

១២. **ព្រះនាងឧមាវតី** : ជាមហេសីរបស់ព្រះព្រហ្ម ព្រះនាងជាទេវតំណាងឱ្យការបង្កើតសត្វលោក និងជាសាក្សីនៃពាក្យសម្បថ ។

ក្រៅពីនេះ នៅមានអាទិទេពដទៃជាច្រើនទៀត ដែលគ្មានតួនាទីច្បាស់លាស់ ប៉ុន្តែស្ថិតនៅស្ថានសួគ៌ដែរ ដូចជា ព្រះទក្សៈ និងព្រះភគិបុត្ររបស់ព្រះព្រហ្ម ។ ព្រះនាងទុគ៌ា នាងគោរី នាងកាលី នាងចន្ទី នាងបរិតី នាងទេវី នាងកុមារី និងនាងមហាទេវី ដែលជាមហេសីព្រះសីវៈជាដើម ។

◎ **អាទិទេពតំណាងឱ្យឫក្សរាសី**

ជាអាទិទេពតំណាងឱ្យដំណើរគោលនៃតារាជុំវិញចក្រវាឡ ។

១. **ព្រះអាទិត្យ** : មាននាមច្រើនដូចជា ព្រះសុរិយ ព្រះសូរ្យ ព្រះទិវាករ និងព្រះវិសវ័ត ។ ព្រះអង្គជាទេវៈតំណាងឱ្យពន្លឺ និងកំដៅ ហើយមានភារកិច្ចកាត់ក្តី និងរកយុត្តិធម៌ឱ្យមនុស្សលោក ។ ព្រះអាទិត្យជាបុត្ររបស់ព្រះនាងអទិតិ ទ្រង់មានមហេសីនាមនាងសរន្យ និងមានបុត្រមួយអង្គគឺ ព្រះយម ។ នៅក្នុងរឿងរាមាយណៈថា ពាលី និង សុគ្រីព ក៏ជាបុត្ររបស់ព្រះអាទិត្យដែរ ។ ព្រះអាទិត្យគង់នៅស្ថានអាទិត្យលោក គឺស្ថិតនៅចន្លោះរវាងទេវលោក និងមនុស្សលោក ។ ព្រះអាទិត្យ គង់នៅលើផ្កាឈូក ឬជួនកាលគង់នៅលើរថ ទឹមដោយសេះបញ្ចិះបំភ្លឺលោកនៅពេលទិវាកាលតាមនប្បក្សចក្ររាសី ។

២. **ព្រះច័ន្ទ** :

ជាទេវតំណាងឱ្យសោភ័ណភាព និងជាទេវថែរក្សានូវរុក្ខជាតិក្នុងធម្មជាតិ ។ ព្រះច័ន្ទគង់នៅលើវិមានអណ្តែតឯស្ថានច័ន្ទលោកតែងតែគង់នៅលើរថទឹមដោយសេះ មានពន្លឺរស្មីស្រទន់បញ្ចិះយាងតាមចក្ររាសី ដើម្បីបំភ្លឺលោក

ក្នុងវេលារាត្រីកាល ។ បើតាមរឿងរាមាយណៈ និងរឿងមហាភារតយុទ្ធថា ព្រះច័ន្ទកើតពីការកូរសមុទ្រទឹកដោះ ។ នៅក្នុង នព្វក្សចក្ររាសី របស់ព្រះច័ន្ទតែងតែមានទេវ ១២ អង្គទៀតយាងដង្ហែរគឺ ÷ " ខែទាំង ១២ "

- ព្រះនព្វក្ស មករៈ ( មករា ) ផ្កាយរូបមករ
- ព្រះនព្វក្ស កុម្ភៈ ( កុម្ភៈ ) ផ្កាយរូបឆ្នាំង
- ព្រះនព្វក្ស មិនៈ ( មីនា ) ផ្កាយរូបត្រី
- ព្រះនព្វក្ស មេសៈ ( មេសា ) ផ្កាយរូបចៀម
- ព្រះនព្វក្ស ឧសភៈ ( ឧសភា ) ផ្កាយរូបក្បាលគោ
- ព្រះនព្វក្ស មិថុនៈ ( មិថុនា ) ផ្កាយរូបមនុស្សពីរនាក់
- ព្រះនព្វក្ស កក្កដៈ ( កក្កដា ) ផ្កាយរូបក្តាម
- ព្រះនព្វក្ស សិង្ហៈ ( សីហា ) ផ្កាយរូបសិង្ហ
- ព្រះនព្វក្ស កន្យៈ ( កញ្ញា ) ផ្កាយរូបស្រីក្រមុំ
- ព្រះនព្វក្ស តុលៈ ( តុលា ) ផ្កាយរូបជញ្ជីង
- ព្រះនព្វក្ស វិច្ឆិកៈ ( វិច្ឆិកា ) ផ្កាយរូបខ្ទួយ
- ព្រះនព្វក្ស ធនុ ( ធ្នូ ) ផ្កាយរូបធ្នូ

៣. ព្រះអង្គារ

ព្រះអង្គារ ជាអាទិទេពតំណាងឱ្យគ្រោះកាចចង្រៃ និងចោរកម្ម ។ ព្រះអង្គារ ជាសេនាជំនិតរបស់ព្រះស្កន្ទៈ ។ " ដែលជាទេវទ្រទ្រង់តម្រាចោរវិទ្យា " របស់ព្រះស្កន្ទៈ ។

៤. ព្រះពុធ

ព្រះពុធ ជាអាទិទេពតំណាងឱ្យប្រាជ្ញា ស្មារតី និងតំណាងឱ្យញាណនិមលទេវៈ ក្នុងការប្រមើលមើលនូវសត្វលោក ។

៥. ព្រះព្រហស្បតិ៍

ព្រះព្រហស្បតិ៍ ជាអាទិទេព ដែលជាប្រធានរបស់ទេវៈក្នុងស្ថានសួគ៌ ព្រះអង្គមាននាទីជាព្រះគ្រូនៃសព្វវិជ្ជាការ និងអក្សរសាស្ត្រ ។

៦. ព្រះសុក្រ

ព្រះសុក្រ ជាអាទិទេពតំណាងឱ្យសេចក្តីស្នេហាបរិសុទ្ធ ក្នុងពេលរួមសង្វាស " សុក្ក មានន័យថាទឹកកាម ឬ ទឹកបរិសុទ្ធ "។ ព្រះអង្គ ជាសេនាដ៏ជំនិតរបស់ព្រះកាម ។

៧. ព្រះសៅរ៍

ព្រះសៅរ៍ ជាអាទិទេពតំណាងឱ្យសិរីសួស្តីជ័យមង្គល ។ ព្រះអង្គមានតួនាទីជាអ្នកសូត្រសរវនាការ ក្នុងពិធីសន្និបាត ។

៨. ព្រះរាហុ

ព្រះរាហុ ជាអាទិទេពតំណាងឱ្យសេចក្តីបំផ្លិចបំផ្លាញ និងការប្រែប្រួល។ ព្រះរាហុ តែងតែព្យាបាទព្រះអាទិត្យ និងព្រះច័ន្ទជានិច្ច ក្នុងមួយឆ្នាំ២ ពីព្រោះព្រះច័ន្ទ និងព្រះអាទិត្យបានទូលព្រះវិស្ណុឱ្យគ្រវែងកងចក្រកាត់លើខ្លួនព្រះរាហុ នៅពេលកំពុងលួចក្រេបទឹកអម្រិត។

៩. ព្រះកេតុ

ព្រះកេតុ ជាអាទិទេពតំណាងឱ្យពន្លឺរស្មីពណ្ណរាយនៅក្នុងស្ថានសួគ៌។ ព្រះកេតុ ជាអាទិទេពធំចំបងជាងគេក្នុងចំណោមអាទិទេពទាំង ៩ អង្គនេះ ដែលតែងតែបំភ្លឺចក្រវាឡ។ ព្រះអាទិទេពទាំង ៩ អង្គនេះ គឺជាផ្កាយនព្វគ្រោះដែលបំភ្លឺ ចក្រវាឡនេះឯង។ រីឯព្រះអាទិទេពទាំង ១២ ដែលតាមដង្ហែរព្រះច័ន្ទ គឺផ្កាយទាំង ១២ ដួង ដែលរះបំភ្លឺលោកប្រចាំខែទាំង ១២ ក្នុងចន្ទគតិ។

**◎ អាទិទេពតំណាងឱ្យធម្មជាតិក្នុងចក្រវាឡ**

១. ព្រះអគ្និ

ព្រះអាគ្និ ជាអាទិទេពតំណាងឱ្យកំដៅភ្លើង ព្រះអង្គមាននាទីជាសាក្សីនៃកម្មជាអំពើល្អនានារបស់មនុស្សក្នុងពិធីបូជាសព្វយ៉ាង។ គេកសាងរូបបដិមាព្រះអាគ្និមានខ្លួនក្រហម ក្បាល ២ អណ្តាត ៧ និងដៃ ៤ មានកាន់ពូថៅ ភ្លើងគប់ ផ្លិត និងខ្សែរផ្គាំ ២ ជាស្លាបព្រា " ហើយគង់នៅលើចៀមឈ្មោល ឬគង់នៅលើរថទឹមដោយសេះក្រហម ៧ មានដោតរាជរថ " ទង់ " សាងពីផ្សែង និងគង់រាជរថជាខ្យល់។ ព្រះអាគ្និតែងសោយវត្ថុស្អាត និងវត្ថុមិនស្អាតឱ្យទៅជាបរិសុទ្ធ។

២. ព្រះវរុណ

ជាអាទិទេពតំណាងឱ្យភ្លៀង និងទឹក ព្រះអង្គមាននាទីចាំឃ្លាំមើលអំពើរល្អ អាក្រក់របស់មនុស្សលោក។ ព្រះវិរុណគង់នៅលើស្ថានភុជង្គ ហើយជាស្តេច នៃពួកនាគទាំងឡាយ។ គេកសាងបដិមាព្រះអង្គវិរុណរូបក្សត្រគង់នៅលើនាគជាសញ្ញាមាន : នៅព្រះហស្ថមានកាន់ខ្សែរ និងត្រែ។

៣.ព្រះវាយុ

ជាអាទិទេពតំណាងឱ្យខ្យល់ ព្រះអង្គមាននាទីបង្កើតល្បឿន និងថាមពល។

៤.ព្រះនាងគង្ហីងធរណី

ជាអាទិទេពតំណាងឱ្យដី "ប្រថពី" ធរណី និងសិរីសួស្តី។ ព្រះនាងមាននាទីរំលាយធាតុទាំង ៤ " ធាតុទឹក ធាតុដី ធាតុភ្លើង និងធាតុខ្យល់ " ដែលផ្សំផ្គុំភាវលោកឱ្យបរិសុទ្ធ។ គេកសាងរូបបដិមាព្រះនាងគង្ហីងធរណី ជារូបទេពធីតា គង់នៅលើសត្វក្រពើ ឬសត្វអណ្តើក ហើយមានយកព្រហស្ថច្បូតព្រះកេសារដ៏វែង។

៥.ព្រះនាងសន្ធិយា

ជាអាទិទេពតំណាងឱ្យរាត្រីកាល និងភាពងងឹតសូន្យសុង។ ព្រះនាងជាបុត្រីរបស់ព្រះព្រហ្ម ហើយមាននាទីជាអ្នកបង្កើតថាមពល និងភាពងោកងុយ។

## ៦.ព្រះនាងអរុណោទ័យ

ជាអារអទិទេពតំណាងឱ្យពន្លឺដ៏ត្រចះត្រចង់នៅពេលព្រឹកព្រហាម។ ព្រះនាង មានតួនាទីដាស់តឿន ក្រើនរំលឹកមនុស្ស និងទេវឱ្យឈប់និទ្រាលង់លក់ ដោយអំណាចរបស់ព្រះនាងសន្និយាបន្តទៅទៀត។ ព្រះនាងអរុណោទ័យ ជាបុត្រីរបស់ព្រះនាងគង្ហីងធរណី និងព្រះច័ន្ទ។ ព្រះនាងរស់នៅយ៉ាង ជិស្និទ្ធជាមួយព្រះមាតា " នៅលើផែនដី " ដើម្បីជួយបំភ្លឺភពផែនដី មុនពេលព្រះបិតាយាងទៅពិភពច័ន្ទលោក " ស្ថានចន្លោះទេវលោក និងមនុស្ស " វិញ មុនពេលព្រះសុរិយាយាងមកទទួលនាទីបំភ្លឺលោក។




## ៧.ព្រះនាងមណីមេខល្លា

ព្រះនាង ជាអាទិទេពតំណាងឱ្យសមុទ្រ និងភាពបរិសុទ្ធ។ ព្រះនាងជួនកាលគេហៅថា ព្រះសមុទ្រ។ ព្រះនាង មណីមេខល្លា ជាព្រះមាតារបស់ព្រះវរុណ ព្រះនាង មានតួនាទីថែរក្សាស្ថានភុជង្គនាគ និងជាអ្នកបង្កើតភ្លៀង ផ្គរ រន្ទះ។ គេបានកសាងរូបបដិមារបស់ព្រះនាង មណីមេខល្លា ជារូបទេពមច្ឆា មានព្រះកាយជាមករ ឯព្រះកេសជាទេពធីតារបៀបកែវ មណីរតនៈ។







*រូបភាពទាំងនេះបង្ហាញពីតួខ្លះនៅក្នុងរឿងរាមកេរ្តិ៍*

# លទ្ធិព្រាហ្មណ៍ក្នុងសង្គមខ្មែរ

សាសនាព្រាហ្មណ៍ បានចូលមកចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមខ្មែរ តាំងពីយូរយាណាស់មកហើយ ហើយមានឥទ្ធិពលយ៉ាងខ្លាំងក្លា ចូលយ៉ាងជ្រៅទៅក្នុងសតិអារម្មណ៍របស់ប្រជាជនកម្ពុជា ដោយបន្សល់ទុកនូវទំនៀមទំលាប់ និងប្រពៃណីផ្សេងៗ នៅក្នុងសង្គមខ្មែរ។ ការរីកចំរើននៃវិទ្យាសាស្ត្រ ដែលជាផលរួម នៃពលកម្មខាងខួរក្បាល និងពលកម្មខាងរូបរាងកាយរបស់មនុស្ស មានសន្ទុះជឿនលឿនយ៉ាងខ្លាំងក្លានៅលើពិភពលោក ក៏ដោយសារឥទ្ធិពលនៃព្រហ្មញ្ញសាសនា ដែលបានដក់ជាប់នៅក្នុងសតិអារម្មណ៍ ព្រមទាំងជំនឿ ទំនៀមទំលាប់មួយចំនួនដែរ។

### ក_ផ្នែកជំនឿ

សាសនាព្រាហ្មណ៍បានធ្វើឱ្យប្រជារាស្ត្រយើងនាសម័យបុរាណកាល មានជំនឿលើអាទិទេព ខ្មោចព្រាយបីសាច អាបធ្មប់។ល។ ដើម្បីទប់ទល់នូវអ្វីដែលជាភាពអស្ចារ្យ គេស្វែងយល់មិនដល់ គេត្រូវតែសិក្សាមន្តអាគម សែនព្រេន បន់ស្រន់ ក្នុងគោលបំណងសុំឱ្យសម្រេចនូវបំណងអ្វីមួយ។

*ឧទាហរណ៍ :* មុនពេលសង់ផ្ទះ គេរៀបចំបាយសី ស្លាធមិ...។ នៅពេលគេមានជម្ងឺ គេនាំឡើងអារក្ស ឬបញ្ជាន់អារក្សសាកសួរខ្មោចព្រាយបីសាច ឬរៀបចំពិធីផ្សេងៗ ដើម្បីអង្វរកដល់អាទិទេព។

### ខ_ទំនៀមទំលាប់ប្រពៃណី

- នៅក្នុងពេលបុណ្យទានផ្សេងៗ គេតែងតែនាំគ្នាធ្វើនំអន្សម នំគម ។ល។ ទាំងអស់នេះ ក៏មានជាប់ឥទ្ធិពលព្រាហ្មណ៍សាសនាដែរ ពោលគឺរំលឹកដល់លឹង្គព្រះឥសូរ និងយោនីនាងឧបមា។ ក្រៅពីនេះ គេឃើញមានរៀបចំស្លាធមិដូង " លឹង្គព្រះឥសូរ ".....។
- នៅពេលរៀបអាពាហ៍ពិពាហ៍ មានការទស្សន៍ទាយមើលវេលា ធ្វើរានទេព្ដា សែនក្រុងពាលី.........។
- នៅក្នុងពិធីបូជាសព រំកិល ហែរ និងបញ្ចុះសព សុទ្ធតែតាមក្បួនខ្នាតទាំងអស់។
- ការព្យាបាលដោយស្តោះ ផ្លុំ ប្រើមន្តអាគម។
- ពិធីកោរជុក ក៏ដូចជាពិធីហៅព្រលឹង " ជញ្ជាត់ព្រលឹង "។

### គ_សិល្បៈ

ប្រាសាទមួយចំនួន គេកសាងដើម្បីឧទ្ទិសដល់អាទិទេព ក្នុងព្រាហ្មណ៍សាសនា។ *ឧទាហរណ៍ :* កសាងប្រាសាទ ភ្នំ កសាងគូរទឹក.....។

- ចម្លាក់នៅតាមប្រាសាទ ជាចម្លាក់តាមលំនាំរឿងរាមាយណៈ មហាភារតៈ

ឬកសាងលឹង្គព្រះឥសូរតែម្តង។



***ការកសាងប្រាសាទភ្នំ និងគូរទឹកតាមបែបព្រហ្មញ្ញសាសនា***

*តើអក្សរសិល្ប៍បែបព្រាហ្មណ៍និយមមានលក្ខណៈសម្គាល់ដូចម្ដេចខ្លះ ?*

**ឃ. អក្សរសិល្ប៍** (មើលអក្សរសិល្ប៍ក្នុងព្រាហ្មណ៍សាសនា)

មានអត្ថបទអក្សរសិល្ប៍ជាច្រើនដែលមានទំនាក់ទំនងនឹងព្រហ្មញ្ញសាសនា ពោលគឺបានដកស្រង់យកជំនឿផ្សេងៗ ក្នុងលទ្ធិព្រាហ្មណ៍មករៀបរាប់ពន្យល់ បង្ហាញហេតុផល និងម្យ៉ាងវិញទៀតមានលើកយកតួអង្គអច្ឆរិយ និងហេតុការណ៍អច្ឆរិយមកបង្ហាញទៀត។ ប្រភេទអក្សរសិល្ប៍បែបនេះ យើងហៅថា "ចលនាអក្សរសិល្ប៍ព្រាហ្មនិយម " ជាអាទិ៍ រឿងរាមកេរ្តិ៍ រឿងព្រះជិនវង្ស រឿងវរវង្សសូរ្យវង្ស រឿងរតនាវង្ស រឿងទិព្វសង្វារ និងរឿងស័ង្ខសិល្ប៍ជ័យជាដើម។

ក្នុងចលនាអក្សរសិល្ប៍បែបព្រាហ្មណ៍និយម មានលក្ខណៈពិសេសគួរកត់សម្គាល់គឺ ÷

**១.ផ្ដើមរឿង**

ក្នុងការផ្ដើមរឿង មានបទស្តុតីសរសើរគុណបុណ្យបារមីឫទ្ធិអំណាចអាទិទេពព្រះមុនីឥសី ឬមានការរៀបរាប់ពីទេសភាពធម្មជាតិ ព្រៃភ្នំ ព្រៃពឹក្សា ដែលនៅជុំវិញអាស្រមព្រះមុនីឥសី ឬក៏ការប្រតិបត្តិពិធីហោម ពិធីបូជាយញ្ញដើម្បីសុំពរស័ព្ទសាធុការពីព្រះអាទិទេពជាដើម.....។

**២.ដំណើររឿង**

នៅក្នុងសាច់រឿងតែងតែបង្ហាញពី ÷

❖ **តួអង្គ**

- *តួអង្គឯកបុរស :* គឺជាកំពូលបុរស ឬអវតារព្រះនារាយណ៍
- *តួអង្គឯកនារី* : គឺជាកំពូលនារី ដែលជាស្រីល្អឯក
- *តួអង្គរងមាន :* អាចជាមនុស្ស យក្ស គ្រុឌ នាគ ទេវតា គន្ធណ ឥសី ជាដើម

❖ **ទីកន្លែង**

- មានទាក់ទងនឹងគ្រប់ស្ថានទាំងបី ក្នុងចក្រវាឡដូចជា ស្ថានសួគ៌ ស្ថានមនុស្ស ស្ថានបាដាល ។

❖ **បញ្ហាចោទ** ទំនាស់វិបត្តិកើតឡើងដោយសារ ៖

- សភាវល្អប្រឆាំងនឹងភាវអាក្រក់
- ការប្រឡងប្រជែងគ្នាខាងយុទ្ធសិល្ប៍
- ការដណ្តើមអំណាច ទ្រព្យសម្បត្តិ

❖ **ការដណ្តើមស្នេហាគ្នា**

- ការសងសឹក ព្យាបាទគ្នា

❖ **បញ្ហាស្រាយ :**

ដោះស្រាយទំនាស់វិបត្តិដោយប្រើហឹង្សា ប្រើយុទ្ធវិធី សង្គ្រាមប្រយុទ្ធ សងសឹកគ្នាមិនចេះចប់ រហូតតកូនតចៅ ។

❖ **ឧត្តមគតិរឿង :** ច្រើនអប់រំមនុស្ស ៖

- មានជំនឿចំពោះអាទិទេព ថាជាអ្នកមានឫទ្ធិអំណាចជួយឱ្យបានសុខចំរើនក្សេមក្សាន្ត ។
- មានចិត្តគំនិតអាត្មានិយម ប្រកាន់បក្សពួក ក្រុមញាតិ ក្រុមគ្រួសារ ។
- មានចិត្តព្យាបាទចង់គំនុំគំគួន ចងអាឃាតសងសឹកគ្នារកទីបញ្ចប់គ្មាន ។

**៣_ការបញ្ចប់រឿង**

គេបញ្ចប់រឿង ក្នុងខណៈ ដែលតួអង្គតំណាងសភាវៈល្អ បានទទួលជោគជ័យជាស្ថាបពរលើតួអង្គតំណាងសភាវៈអាក្រក់ ។

ក្រៅពីអក្សរសិល្ប៍ ក្នុងគោលចលនាព្រាហ្មណ៍និយមខាងលើ នៅមានចំរៀង បទភ្លេង អក្សរទៀត ដែលពោរពេញទៅដោយលក្ខណៈអក្សរសិល្ប៍ ។ យើងដឹងហើយថា ក្រោយពេលព្រហ្មញ្ញសាសនា ត្រូវថយចុះឥទ្ធិពលពីក្នុងសង្គមខ្មែរដោយសារឥទ្ធិពលព្រះពុទ្ធសាសនា អង្គអាទិទេព ដែលខ្មែរធ្លាប់គោរពបូជា បានក្លាយមកជាអ្នកតា អារក្សបង់បត់វិញ ។ ដូច្នេះហើយ ទើបមានបទចម្រៀងច្រៀងសរសើរស្តុតិ គុណអាទិទេព ឬអង្វរករអាទិទេព ឱ្យសប្បាយហឫទ័យ ដែលមានចែងនៅក្នុងគម្ពីរវេទ ។

*តើសាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនា បានអប់រំមនុស្សខ្មែរឱ្យជឿលើអ្វីខ្លះ ? មានទំនៀមទំលាប់ប្រពៃណីបែបណា ?*

ក. សាសនាព្រាហ្មណ៍

*ការអប់រំ :* អប់រំមនុស្សខ្មែរ ឱ្យជឿលើអាទិទេព ខ្លាចព្រាយបីសាច អាបធ្មប់ មន្ត អាគមគាថា អច្ឆរិយហេតុផ្សេងៗ.....។

អប់រំមនុស្សខ្មែរ ឱ្យមានពិធីសែនព្រេនបន់ស្រន់ ដើម្បីទប់ទល់នឹងភាពអស្វារ្យណាមួយ ឬមានគោលបំណងសុំសេចក្តីសុខ និងបានសម្រេច តាមបំណងប្រាថ្នា។




*ទំនៀមទំលាប់ប្រពៃណី :* ក្នុងពិធីបុណ្យទានផ្សេងៗ គេតែងតែនាំគ្នារៀបចំសែនព្រេន សែនក្រុងពាលី រៀបចំស្លាធមិដូងបាយសី ធ្វើនំគម នំអន្សមជាដើម។ មុនពេលរៀបចំពិធីនីមួយៗ គេតែងតែគន់គូរមើលខែថ្ងៃរកថ្ងៃជាពេលាល្អតាមក្បួនខ្នាតរបស់អាចារ្យ ឬហោរាទស្សន៍ទាយ។ ការព្យាបាលជម្ងឺ ដោយវិធីស្រោចទឹក ស្តោះផ្លុំ ប្រើមន្តអាគម ឬរៀបចំធ្វើពិធីប្រមូលព្រលឹង ឬអន្ទងហៅព្រលឹង។ ការកសាងប្រាសាទភ្នំ កសាងគូរទឹកព័ទ្ធជុំវិញ មានចម្លាក់ក្នុងរឿងរាមាយណៈ ឬរឿងមហាភារតៈ ក្នុងនោះសំខាន់គឺ កសាងលិង្គព្រះឥសូរ ដែលតម្កល់លើយោនីព្រះនាងឧមា។



ខ.-ព្រះពុទ្ធសាសនា

*ការអប់រំ* : បានអប់រំមនុស្សខ្មែរ ឱ្យជឿលើបុណ្យបាប កម្មផល ពៀរវេរា របស់មនុស្ស ដែលបានប្រព្រឹត្តពីអតីតជាតិ ឱ្យមនុស្សយល់ថា ធ្វើល្អតែងតែទទួលផលល្អ ធ្វើអាក្រក់តែងតែទទួលផលអាក្រក់ ក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិ។ ដូចនេះ ពុទ្ធសាសនិកជនត្រូវតែគោរពប្រណិបត្តិនី តាមពុទ្ធឱវាទ គឺ ពុទ្ធវចនៈទាំង ៨៤000 ធម្មក្ខ័ន្ធ ដែលមានចែងនៅក្នុងគម្ពីរព្រះត្រៃបិដក។

*ទំនៀមទំលាប់ប្រពៃណី :* ក្នុងពិធី បុណ្យផ្សេងៗ គេតែងតែនាំគ្នាគោរពព្រះពុទ្ធរូប ជាធំ គោរពព្រះសង្ឃ គ្មានសែនព្រេន គ្មានរៀបចំសែនក្រុងពាលី គ្មានស្លាធមិដូង សូត្រតែធមិព្រះពុទ្ធ ស្ដាប់តែពុទ្ធឱវាទ ខំតម្កល់ចិត្តឱ្យបរិសុទ្ធ ប្រកាន់នូវសីលជានិច្ច មានសីល ៥ សីល ៨ សីល ១០ ខំសន្សំកុសលផលបុណ្យ មានសទ្ធាជ្រះថ្លា បរិច្ចាកទានជាដើម ។

ដោយមានជំនឿថា មនុស្សស្លាប់ទៅព្រលឹងឥតស្លាប់ ហើយព្រលឹងគឺជាសារធាតុ ដែលមិនចេះបាត់បង់ ហើយមនុស្សតែងតែវិលកើត វិលស្លាប់ក្នុងវដ្ដសង្សារ នៅពេលណាដែលមិនទាន់ផុតកម្ម ។ ចំហាយនៃកម្មចាស់ ឬចំហាយនៃក្ខ័ន្ធ ( ព្រលឹង ) តែងតែជួបនឹងធាតុផ្សំ បង្កើតបាននូវរូបរាងកាយសារជាថ្មី ពោលគឺជីវិតថ្មី រួចតែងតែទទួលនូវចំហាយនៃកម្មចាស់ហៅថា អំពើនៃកម្មចាស់ ។ ជីវិតចាស់ និងជីវិតថ្មី ដូចគ្នាផង ខុសគ្នាផង ដូចគ្នាត្រង់ជីវិតថ្មី ត្រូវរង នៃអំពើចាស់ ផលចាស់ ខុសគ្នាត្រង់ជីវិតថ្មីមានសកម្មភាពថ្មី មានការអប់រំថ្មី មានផលកម្មថ្មី ។ ផលកម្ម ពៀរវេរា ដែលមនុស្សកំពុងទទួលហៅថា វាសនា ។

*តើសព្វថ្ងៃមានពិធីបុណ្យណាខ្លះ ដែលជាពិធីបុណ្យមានលក្ខណ:ចម្រុះ ? ពិធីណាខ្លះទៀត ដែលមានលក្ខណ:ព្រះពុទ្ធសាសនាសុទ្ធសាធ ?*

***ពិធីបុណតាមបែបព្រះពុទ្ធសាសនាសុទ្ធសាធ*** ÷ បុណ្យចូលវស្សា ចេញវស្សា បុណ្យពិសាខបូជា មាឃបូជា កឋិនទាន បុណ្យផ្កា បុណ្យបច្ច័យបួន បុណ្យឆាកមហាបង្សុកូល បុណ្យទេសនាមហាជាតក បុណ្យបំបួសនាគ..... ។

***ពិធីបុណ្យ ដែលមានលក្ខណ:ចម្រុះ*** ÷ មានដូចជា បុណ្យចម្រើនព្រះបរិត្ត ពិធីច្រត់ព្រះនង្គ័ល ពិធីបង្សុកូល ពិធីសូត្រមន្តរំដោះគ្រោះ សូត្រមន្តរំដោះកម្មផល បុណ្យភ្ជុំបិណ្ឌ ពិធីបូជាសព ពិធីដង្ហែរសព បុណ្យចូលឆ្នាំខ្មែរ.... ។

**តើការកសាងធនធានមនុស្ស ដែលជាមនុស្សពេញលេញ ជាពលរដ្ឋល្អ ត្រូវមានលក្ខណ:សម្បត្តិយ៉ាងដូចម្ដេចខ្លះ?**

ដើម្បីកសាងមនុស្សពេញលេញ ជាពលរដ្ឋល្អ ត្រូវមានការរីកចម្រើនលូតលាស់ លើគ្រប់ផ្នែកព្រមៗគ្នា ប្រកបដោយតុល្យភាពរវាងប្រាជ្ញាស្មារតីសញ្ចេតនា និងរូបរាងកាយ ដើម្បីក្លាយជាមនុស្ស



ថ្លៃថ្នូរ ក្នុងសង្គមមួយសំបូររុងរឿង លុះត្រាតែមាន ចំណេះដឹង បំណិន ពិសោធន៍ សីលធម៌ គុណធម៌ល្អ ចេះសហការ អធ្យាស្រ័យ មានស្មារតីវាងវៃ មាន សាមគ្គីជាតិ អន្តរជាតិ និងឯកភាពជាតិល្អ ព្រមទាំង មានមនសិការស្នេហាជាតិ មានតម្លាភាព ស្រឡាញ់ យុត្តិធម៌ មានការគោរពច្បាប់ និងការគោរពសិទ្ធិ មនុស្ស ។ ផ្អែកលើស្មារតីទទួលខុសត្រូវខ្ពស់ ចេះស្រាយ បញ្ហាដោយសន្តិវិធី មានចំណេះដឹងផ្នែកសុខមាលភាព ផ្ទាល់ខ្លួន និងគ្រួសារ ជាហេតុនាំឱ្យបានចូលរួមយ៉ាង សកម្មក្នុងការស្តារ និងការអភិវឌ្ឍមាតុភូមិជាទីស្នេហា របស់យើង ដូចជា ៖



- មានចំណេះដឹង និងបំណិនលើចំណេះដឹងទូទៅខ្ពស់ មានសមត្ថភាពអនុវត្តន៍ចំណេះដឹងនោះ ដោយជោគជ័យទៅតាម ស្ថានភាពជាក់ស្តែងនៃសង្គម ។
- មានសមត្ថភាពជួយកែលម្អ ដោយពង្រឹងសុខភាពផ្ទាល់ខ្លួន គ្រួសារ និងសង្គម ។
- មានការទទួលខុសត្រូវខ្ពស់ មានទំនុកចិត្តលើខ្លួនឯង ចេះស្រាយបញ្ហា ចេះសម្រេចចិត្តនិងចេះលើកគម្រោងផែនការដោយជោគជ័យ ក្នុងជីវិត ។
- មានការយោគយល់គ្នា អធ្យាស្រ័យគ្នា ទទួលស្គាល់ផលប្រយោជន៍អ្នកដទៃ ស្គាល់ទុក្ខលំបាកអ្នកដទៃ ដូចជាទុក្ខលំបាកផ្ទាល់ខ្លួន ដោយយកស្មារតី ជួយគ្នាទៅវិញទៅមក តាមបែបសមភាព និងភាតរភាព ។
- លើកកម្ពស់សមត្ថភាព និងលទ្ធភាពរបស់ខ្លួនពេញមួយជីវិត ដោយធ្វើការសិក្សាស្រាវជ្រាវ ដកពិសោធន៍ ។
- ចូលចិត្តសិក្សាស្វែងយល់ពីបច្ចេកវិទ្យាទំនើប តាមបែបប្រព័ន្ធតិចណូឡូស៊ី និងគ្រឿងអេឡិចត្រូនិច តាមបែបវិទ្យាសាស្ត្រទំនើប ។
- មានចំណេះចេះរស់នៅក្នុងសង្គម ចេះធ្វើការជាមួយអ្នកដទៃ យល់ដឹងពីរបៀបធ្វើការងារ របៀបគ្រប់គ្រងការងារ ដោយត្រៀមខ្លួនបម្រើមុខវិជ្ជាជីវៈណាមួយសមស្របតាមលទ្ធភាព សមត្ថភាព និងចំណង់ចំណូលចិត្តរៀងៗខ្លួន ។
- ចេះរស់នៅ ដោយចេះសម្របខ្លួនទៅតាមការវិវត្តរបស់សង្គម ដើម្បីអភិវឌ្ឍខ្លួន និងសង្គមជាតិរបស់ខ្លួនឱ្យបានជោគជ័យ ។
- មានមនសិការស្មារតីទទួលខុសត្រូវ និងមោទភាពជាតិ ស្រឡាញ់ជាតិ សាសនា ព្រះមហាក្សត្រ ដោយពង្រឹងស្មារតី ថែរក្សាការពារបរិស្ថាន សម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ សិល្បៈ ដែលជាស្នាដៃដ៏ពិសិដ្ឋ និងយូរលង់

របស់ដូនតាយើងបន្សល់ទុកឱ្យ។

- បង្កើតស្នាដៃ ជាទេពកោសល្យរបស់មនុស្សឱ្យក្លាយជាកោសិការរបស់សង្គម។ ម្នាក់ៗ ត្រូវធ្វើអ្វីៗ ដែលជាគុណប្រយោជន៍ដល់ជាតិ និងមាតុភូមិរបស់ខ្លួន (រស់មិនទទម្ងន់ផែនដី) ក្នុងបំណងកសាងខ្លួន ឱ្យក្លាយជាស្ថាបនិកដ៏សកម្ម ក្នុងការកសាងប្រវត្តិសាស្ត្ររបស់សង្គមជាតិ។

សរុបមក មនុស្សយើងម្នាក់ៗ តែងតែមានតម្រូវការក្នុងមុខជំនាញរបស់ខ្លួនជានិច្ច ហើយមុខជំនាញនោះតែងតែត្រូវបានកែប្រែឱ្យសុក្រឹតឡើងៗ និងមានភាពល្អប្រសើរគ្រប់ពេលវេលា ពីព្រោះវាជាជីវភាពរស់នៅក្នុងសង្គម តម្លៃការងារ មានសារៈសំខាន់ណាស់ ពីព្រោះ ÷

- ការងារជាប្រភពនៃលក្ខខ័ណ្ឌសេដ្ឋកិច្ច សម្រាប់មនុស្សមួយរូបៗ ក៏ដូចជាក្នុងគ្រួសារ ឬសង្គមជាតិ
- ការងារប្រកបដោយសុច្ចរិត យុត្តិធម៌ មានតម្លាភាពពិតជានាំមកនូវសេចក្តីថ្លៃថ្នូររុងរឿង
- ការងារជាប្រភពនៃការយោគយល់គ្នា និងមានសាមគ្គីធម៌ដ៏យូរលង់
- ការងារជាចំណងសម្រាប់ចង់មនុស្សឱ្យចេះរួមរស់ដោយសុខសាន្ត និងមានសុខដុមរមនា ជាមួយគ្រួសារ និងសង្គមជាតិ
- ការងារដែលត្រឹមត្រូវ ពិតជានាំមកនូវមនោសញ្ចេតនា សប្បាយរីករាយ ដែលជាកម្មវត្ថុ នៃសុភមង្គលនៃជីវិត
- ការងារជាសកម្មភាព ដ៏ប្រពៃ ជាហេតុនាំឱ្យទឹកឃើញអនុស្សាវរីយដ៏ល្អ និងតម្លៃផ្ទាល់ខ្លួន ដែលលេចចេញជាលទ្ធផល ផ្លែផ្កា ដែលមហាជនគេអាចទទួលយកបាន
- ការងារនាំមនុស្សទៅកាន់ភាពម្ចាស់ការ និងភាពជាម្ចាស់នៃធម្មជាតិ
- ការងារនាំមនុស្ស ឱ្យចេះដឹកនាំអារម្មណ៍ យ៉ាងសប្បាយរីករាយរបស់ខ្លួន ឱ្យប្រសើរឡើង។

*តើចំណេះដឹងផ្នែកវប្បធម៌ អរិយធម៌ខ្មែរ បានបណ្តុះនូវគំនិតឧត្តមគតិ និងអត្តសញ្ញាណជាតិដល់កុលបុត្រ កុលធីតាខ្មែរយ៉ាងណាខ្លះ ?*

✡ *គំនិតឧត្តមគតិជាតិ*

- បើកទូលាយនូវចំណេះដឹងទូទៅ ងាយស្វែងយល់អំពីមូលដ្ឋានគ្រឹះរបស់សង្គមជាតិ និងព្រលឹងរបស់ជាតិ
- បណ្តុះមនោសញ្ចេតនាលើការងារគ្រប់ផ្នែក ដោយស្រឡាញ់ ថែរក្សាការពារអ្វីៗ ដែលជារបស់ជាតិ
- ស្វែងយល់នូវអ្វីៗ ដែលល្អ មានតម្លៃតាំងពីយូរលង់ណាស់មកហើយ តាំងពីឥរិយាបថ ដេក ដើរ ឈរ អង្គុយ ទំនៀមទំលាប់ប្រពៃណី ជំនឿសាសនា សិល្បៈ........ ដើម្បីអនុវត្ត និងគោរព។
- ចេះរកវិធានការទប់ស្កាត់ នូវឥទ្ធិពលបរទេស ជាវប្បធម៌ទាំងឡាយណា ដែលមានបំណងបំផ្លិចបំផ្លាញវប្បធម៌ អរិយធម៌ជាតិខ្លួន។
- ចេះកែច្នៃ ក្រឡៃ ប្រឌិតឥទ្ធិពលបរទេស ឱ្យមកជារបស់ជាតិខ្មែរ បម្រើផលប្រយោជន៍ខ្មែរ ស្របតាម ចំណង់ចំណូលចិត្តរបស់ខ្មែរ។

✡ *អត្តសញ្ញាណជាតិ* (អត្ត = ខ្លួន) + (សញ្ញាណ = គ្រឿងសម្គាល់) សំដៅទៅលើអ្វីៗ ដែលមានលក្ខណៈសម្គាល់ ជារបស់ជាតិខ្មែរ ដូចជា ÷

- ជនជាតិមានដើមកំណើតលើទឹកដីជាមួយគ្នា
- ភាសានិយាយដូចគ្នា
- ភូមិសាស្ត្រ ប្រវត្តិសាស្ត្រតែមួយជាមួយគ្នា
- សម្លៀកបំពាក់ ប្រដាប់ប្រើប្រាស់ ការរស់នៅប្រហាក់ប្រហែលគ្នា ឬដូចគ្នា
- ធម្មជាតិមាន (ដើមត្នោត ទន្លេសាប ត្បូងរ៉ែ)
- សិល្បៈមានលក្ខណៈពិសេសរបស់ជាតិ (ភ្លេងពិណពាទ្យ ភ្លេងមហោរី ភ្លេងខ្មែរ....)
- ល្បែងប្រជាប្រិយ៍ (ចោលឈូង បោះអង្គុញ លាក់កន្សែង.....)
- របាំ ( បូរាណ ប្រពៃណី ប្រជាប្រិយ...)

សរុបមក ការសិក្សាវប្បធម៌ អរិយធម៌ គឺជាការបណ្តុះនូវគំនិតឧត្តមគតិ និងអត្តសញ្ញាណជាតិខ្មែរដល់កុលបុត្រ កុលធីតាខ្មែរ ពិតប្រាកដមែន។

*តើសីលធម៌ និងគុណធម៌ប្រាំប្រការរបស់ខ្មែរយើងដូចម្តេចខ្លះ ?*

*សីលធម៌ :* ជាធម៌ ដែលនាំមនុស្សឆ្ពោះទៅរកអំពើ ដែលជាគុណកុសល ឬជាគន្លង នៃចរិយារបស់មនុស្ស ដែលរស់នៅប្រកបទៅដោយគុណធម៌ ដើម្បីរស់នៅសមរម្យក្នុងសង្គម។ ឬជាទ្រឹស្តី ពាក្យទូន្មានទាំងឡាយណា ដែលដឹកនាំមនុស្សឆ្ពោះទៅរកផ្លូវល្អ។

*គុណធម៌ :* ជាតម្លៃល្អ ដែលស្តែងចេញតាមរយៈកាយ វាចា ចិត្ត និងសកម្មភាពរបស់មនុស្ស។

✡ *មនុស្សត្រូវមានសីលធម៌ ៥ យ៉ាង គឺ :*

- *សីលធម៌ផ្ទាល់ខ្លួន* : ដឹងខុសត្រូវ ល្អអាក្រក់ ក្លាហានហ៊ានទទួលខុសត្រូវលើអំពើរបស់ខ្លួន តាំងជាម្ចាស់ នៃចិត្តរបស់ខ្លួនបាន។
- *សីលធម៌ក្នុងគ្រួសារ* : ស្គាល់នូវកាតព្វកិច្ចរបស់ខ្លួនជាឪពុក - ម្តាយ ចិញ្ចឹមកូនមិនគិតពីការតបគុណវិញ ធ្វើឱ្យមានភាពសុខដុមរមនា។
- *សីលធម៌ក្នុងវិជ្ជាជីវៈ* : មានមនសិការក្នុងការងារ រកស៊ីតាមសមត្ថភាព និងតាមសម្មាជីវោ មិនរំលោភលើអ្នកតូចជាងខ្លួន មិនលោភធ្វើការហួសកម្លាំងនាំឱ្យខូចសុខភាព។
- *សីលធម៌ក្នុងសង្គម* : មានសាមគ្គីភាពល្អ មិនបង្កទំនាស់ គោរពសិទ្ធិមនុស្ស ស្រឡាញ់យុត្តិធម៌ ស្រឡាញ់មនុស្សទូទៅ ទទួលស្គាល់ទុក្ខវេទនាអ្នកដទៃ។
- *សីលធម៌ពិភពលោក* : មានទំនាក់ទំនងល្អជាមួយបរទេស និងមិនប្រកាន់ជាតិសាសន៍ ជំនឿសាសនា .....។

✡ *មនុស្សត្រូវមានគុណធម៌ ៥ ប្រការគឺ :*

- *គោរពមាតាបិតា ចាស់ទុំ* : ស្គាល់នូវអំពើល្អ និងអំពើអាក្រក់ សុចរិត ទៀងត្រង់ សមធម៌ យុត្តិធម៌។

• *គោរពសិទ្ធិមនុស្ស* : គ្មានការរំលោភសិទ្ធិមនុស្ស មិនរើសអើង ( ភេទ ពូជសាសន៍....) ចេះអត់ឱន និងអធ្យាស្រ័យ សណ្ដោសប្រោសប្រណី ។

• *ព្រហ្មវិហារធម៌ទាំង ៤* : មេត្តា ករុណា មុទិតា ឧបេក្ខា ។

• *សីលប្រាំ* : មិនកាប់សម្លាប់ មិនលួចទ្រព្យសម្បត្តិអ្នកដទៃ មិនលួចប្រពន្ធកូនគេ មិនភូតកុហក់ មិនសេពគ្រឿងស្រវឹងគ្រប់ប្រភេទ ។

• *ទសពិធរាជធម៌ទាំងដប់ប្រការ* (ទាន សីល បរិច្ចាគ អាជ្ជវៈ មទ្ទវៈ តបៈ អក្កោធនៈ អវិហឹង្សា ខន្តី អវិរោធនៈ )

*ហេតុអ្វីបានជាទំនៀមទំលាប់ខ្មែរតាំងពីបូរាណកាល រហូតដល់បច្ចុប្បន្នគេតែងតែនិយាយថា " មេ - បា"?*

*✡ ប្រភពនៃពាក្យ " មេ - បា "*

• ការកំណត់យកភេទស្រីធំជាងប្រុស " សង្គមមតេយ្យការ ឬមាតាធិបតេយ្យ " មានតាំងពីសម័យបុរេប្រវត្តិរហូតដល់សតវត្សទី ១ នៃគ.ស ។ ទំនៀមទំលាប់នេះ មានរហូតដល់ពេលបច្ចុប្បន្ន គឺពីសម័យព្រះនាង លីវយី "ព្រះនាងសោមា " និងព្រះបាទកោណ្ឌញ្ញ " ប្រពះបាទ ហ៊ុន ទៀន " បានសោយរាជ្យនៅលើទឹកដីកម្ពុជា ។

• ចំណែកបា សំដៅទៅលើមនុស្ស បា = ឥណ្ឌារាជា = ប្រុស ។ តាមទំនៀមទំលាប់ឥណ្ឌា បានគោរពប្រុសជាធំនៅក្នុងសង្គម និងនៅក្នុងគ្រួសារ ។

• តាមទំនៀមទំលាប់ខ្មែរ គោរពមេជាធំ តាំងពីសម័យព្រះនាង លីវ យី សោយរាជ្យនៅលើកោះគោកធ្លក ។ នៅពេល ដែលស្ដេចឥណ្ឌាឈ្មោះព្រះបាទ កោណ្ឌញ្ញ មកធ្វើជាព្រះស្វាមីរបស់ព្រះនាង លីវ យី ក៏ស្ដេចឥណ្ឌារូបនេះ នៅតែគោរពមេជាធំ គោរពតាមទំនៀមទំលាប់ប្រពៃណីខ្មែររហូតមក មិនប្រកាន់តាមឥណ្ឌាឡើយ ។

*ឧទាហរណ៍ :* មេទ័ព មេដំបូល មេក្លោង មេស្រុក មេឃុំ......... ។

• មេ-បា = រាជា មានន័យថា ព្រះរាជា មានតួនាទីជាមេផង ជាបាផង ។ តាមពិតប្រពៃណីខ្មែរ យកស្រីធំជាងប្រុស " មេធំជាងបា " ។

• មេ-បា មិនដាច់ពីគ្នាទេ ជានិមិត្តរូបទឹកដី

• អ្នកស្រុកខ្មែរដើម គេគោរពព្រលឹងអ្នកតា ជាមេ - បា ជាម្ចាស់ទឹកម្ចាស់ដី ដូចនេះហើយបានជាពាក្យ មេ - បា តែងតែនៅជាប់គ្នាជានិច្ច ។

• នាគ = មេ នាគជាសត្វដើមសន្តវង្ស ជាសត្វដែលមិនចេះស្លាប់ ជាសត្វដែលមានសំណាក មានភាពអមតៈ ។ ដូចនេះ យើងសង្ឃឹមថា " ពូជខ្មែរ មិនដែលសាបសូន្យ " ។

*ការកសាងខ្លួនឱ្យល្អ គេត្រូវអភិវឌ្ឍចិត្ត ដើម្បីអភិវឌ្ឍន៍ចិត្ត ត្រូវឈរលើកត្តាសំខាន់ៗ ដូចខាងក្រោម :*

ការអភិវឌ្ឍចិត្ត គឺត្រូវធ្វើចិត្តឱ្យល្អ ឬជាកុសល្យ ។ សំដៅលើចិត្ត ដែលល្អជាកុសលបាន គឺចិត្ត ដែលមានសុខភាព គុណធម៌ និងគុណភាព ។

✡ **ចិត្តមានសុខភាព** គឺចិត្តដែលមានសុខភាពល្អ ហើយចិត្តដែលមានសុខភាពល្អ គឺចិត្តដែលមិនចេះកើតទុក្ខ

មិនសោកសៅ មិនខឹងច្រឡោត មិនរវើរវាយ រហូតដល់ថានៅពេលនិទ្រាលង់លក់ មិនយល់សប្តិ មមើមមាយ រវើរវាយទៀតផង។

ដូចនេះ មនុស្ស ដែលអាចមានសុខភាពល្អមាំមួន ក៏អាស្រ័យទៅលើចិត្តមានសុខភាពល្អដែរ។

✡ **ចិត្តមានគុណភាព** គឺសំដៅទៅលើចិត្តដែលមានការអត់ធន់ អត់ធ្មត់ រឹងប៉ឹង ក្លាហាន មោះមុត ពូកែគិត ចាំបានច្រើន បានយូរ ពូកែដឹង មិនងាយតក់ស្លុត ភ័យរន្ធត់។ល។ ពោលគឺ ធ្វើចិត្តឱ្យរឹងមាំ ពីព្រោះបើមិនរឹងមាំ ខ្វះការតស៊ូ វិលវល់ ចាប់នេះចាប់នោះមិនប្រាកដ ក្នុងការងារ វានឹងទទួលបរាជ័យ ក្នុងឆាកជីវិតជាក់ជាមិនខាន។

✡ **ចិត្តមានគុណធម៌** គឺចិត្តដែលឈរលើព្រហ្មវិហារធម៌បួនយ៉ាងគឺ÷

- *មេត្តា :* មានចិត្តមេត្តាចំពោះសព្វសត្វ។
- *ករុណា :* មានចិត្តសង្គ្រោះគេឱ្យបានសេចក្តីសុខ មិនយកសុខតែឯង។
- *មុទិតា :* ត្រេកអរ សប្បាយរីករាយ នៅពេលឃើញគេមានសេចក្តីសុខសុភមង្គល មិនច្រណែននិន្ទាឈ្នានីស ឬផ្តន្ទាគេ....។
- *ឧបេក្ខា :* មានចិត្តជាកណ្តាល មានយុត្តិធម៌ មិនលុះទៅក្នុងអគតិធម៌។

ម្យ៉ាទៀត ត្រូវជៀសវាងនូវចិត្ត គ្មានគុណធម៌ទាំង ១៦ យ៉ាង ដែលបង្រួបបង្រួមមកត្រឹមតែ ៣ ប្រការសំខាន់ គឺ : ចិត្ត ដែលមានសេចក្តីលោភ (លោភៈ) សេចក្តីក្រោធខឹង (ទោសៈ) និងដែលមានសេចក្តីវង្វេង មិនដឹងខុសត្រូវ (មោហៈ)។

**ចំណុចសំខាន់ៗ របស់ស្វាមី-ភរិយាថ្មី ដើម្បីកសាងសុភមង្គល ក្នុងគ្រួសារ**

✡ ***ភារកិច្ចរបស់ប្តីត្រូវ*** ÷

- ស្រលាញ់ស្មោះត្រង់ ជាមួយភរិយាអស់មួយជីវិត ដោយប្រើសំដីផ្អែមល្ហែមទៅរកភរិយា គ្រប់ពេលវេលា
- មិនបៀតបៀនដោយប្រការណាមួយទៅលើភរិយា និងមិនមើលងាយភរិយាប្រៀបដូចជាទាសីរបស់ខ្លួន
- មិនក្បត់ចិត្តភរិយា ដោយប្រការណាមួយឡើយ
- ប្រគល់តំណែងដ៏ពិសិដ្ឋដល់ភរិយា ជាស្ត្រីមេផ្ទះពេញលក្ខណៈ
- ផ្តល់គ្រឿងអលង្ការផ្សេងៗ ដល់ភរិយា តាមលទ្ធភាព និងសមត្ថភាពរបស់ខ្លួន

✡ ***ភារកិច្ចរបស់ប្រពន្ធត្រូវ*** ÷

- ចំអិនអាហារយ៉ាងឆ្ងិតឆ្ងន់ តម្រូវតាមពេលវេលាទុកជូនប្តី
- រាប់អានញាតិខាងស្វាមី និងញាតិរបស់ខ្លួនយ៉ាងស្មោះស្មើគ្នា
- រក្សាទុកដាក់ទ្រព្យសម្បត្តិ ដែលប្តីរកបានឱ្យគង់វង្ស
- មិនក្បត់ចិត្តប្តី ដោយប្រការណាមួយឡើយ
- ត្រូវមានទេពកោសល្យ និងការប៉ិនប្រសប់ ចាត់ចែងលើគ្រប់ការងារ ដោយឧស្សាហ៍ព្យាយាម និងធ្វើការទាំងនោះឱ្យបានសម្រេចជោគជ័យ។

# ព្រះពុទ្ធសាសនា

យើងសង្កេតឃើញថា ពុទ្ធសាសនាបានរីកដុះដាល និងអន់ថយចាប់តាំងពីព្រះពុទ្ធបានត្រាស់ដឹង រហូតមកដល់សព្វថ្ងៃនេះ។ តាមឯកសាររបស់លោក ***តូម៉ា*** បានសរសេរថា ៖

នៅឆ្នាំ ៥២៨ ព្រះពុទ្ធបានត្រាស់ដឹង "សតវត្សទី ៦ មុនគ.ស "។ នៅឆ្នាំ ៤៨៣ ព្រះពុទ្ធទ្រង់បានចូលយាងបរិនិព្វាន រួចហើយ ***ព្រះអរហន្ត*** ជាសាវ័ក បានចាប់ផ្តើមធ្វើសង្គាយនាលើកទី ១ នៅក្រុងរាជគ្រឹមគធរដ្ឋ។ នៅឆ្នាំ ៣៨៣ មុនគ.ស ព្រះអរហន្តបានធ្វើសង្គាយនាលើកទី ២ នៅក្រុងវេសាលី។ នៅឆ្នាំ ២៦៩ មុនគ.ស ព្រះបាទ ***អសោកមហារាជា*** ទ្រង់បានឡើងសោយរាជ្យ រួចហើយ ***ព្រះអរហន្ត*** បានធ្វើសង្គាយនាលើកទី ៣ ក្រោមព្រះរាជជួយឧបត្ថម្ភ របស់ព្រះអង្គ។ បន្ទាប់មកទៀត ទ្រង់បានបញ្ជូនសាមណទូតទាំងឡាយ ឱ្យទៅផ្សព្វផ្សាយអំពីពុទ្ធសាសនា នៅគ្រប់ទី កន្លែងទាំងអស់ នៅទូទាំងប្រទេសឥណ្ឌា និងក្រៅប្រទេស។ នៅឆ្នាំ ២៤៦ មុនគ.ស បេសកកម្មរបស់ព្រះ **មហិន្ទត្ថេរ** ទៅកាន់កោះស្រីលង្កា *Crylanca* បានធ្វើឱ្យពុទ្ធសាសនាបែកចេញជានិកាយធំៗពីរ គឺ ៖ ហីនយាន និងមហាយាន។ និកាយហីនយាន បានបែកជា ១៨ និកាយទៀត ។ ព្រះរាជាទាំងឡាយនៃកុសាណវង្ស បានស្ថាបនាទីក្រុងមួយនៅ ប្រទេសឥណ្ឌាប៉ែកនិរតី។ នៅឆ្នាំ ២៩ ដល់ ១៧ មុនគ.ស ជារជ្ជកាលរបស់ព្រះបាទ "***វេដ្ឋ គាមិនី*** "។ នៅសតវត្សទី ១ នៃគ.ស ព្រះបាទ***កនិស្កៈ*** នៃកុសាណវង្សទ្រង់បានបង្គាប់ឱ្យសរសេរព្រះត្រៃបិដក ជាភាសាសំស្រ្កឹត សង្គាយនាលើកទី ១ នៃនិកាយ "សរិស្តិវាទិន " ជានិកាយមហាយាន ក្រោមព្រះរាជជួយឧបត្ថម្ភ របស់ព្រះបាទ ***កនិស្ករាជ*** ។

នៅសតវត្សទី ២ នៃគ.សមាននិកាយមហាយានមួយទៀត បានកកើតឡើងឈ្មោះថា "***យោគាចារ***" ក្រោមឱវាទ និងការដឹកនាំរបស់ទស្សនវិទូពីររូប គឺលោក "***វសុពន្ធអាណង្គ*** " នៅសតវត្សទី ៦ នៃគ.ស តក្កវិជ្ជានិកាយ ក្រោមឱវាទ និងការដឹកនាំរបស់លោក " ***ឌិគ្នាគៈ***" បានកើតឡើងទៀត។ នៅសតវត្សទី ៧ នៃគ.ស មានទស្សនវិទូពីររូប គឺលោក "***សន្តិទេវៈ***" និង "***ធម្មកិត្តិ*** " ក៏បានមានកំណើតដែរ។ នៅក្នុងឆ្នាំនោះដែរ ក៏មានទស្សនវិទូពីររូប គឺ " ***សង្ករាចារ្យ***" និង "***កុមារហរិឡ***" ជាពួកព្រាហ្មណ៍បានបន្លំសិក្សាទ្រឹស្តីពុទ្ធសាសនាយ៉ាងជំនាញ ហើយបានកែទម្រង់លទ្ធិព្រាហ្មណ៍ ដោយបានរួមបញ្ចូល នូវទ្រឹស្តីទាំងឡាយបង្កើតជាគម្ពីរព្រាហ្មណ៍មួយឈ្មោះថា " វេទាន្ត " ទីបំផុតនៃវេទ។ នៅក្នុងអារម្ភបទនៃគម្ពីរនេះ ***សង្ករាចារ្យ*** បានប្រារព្ធធ្វើនមស្សការដល់ព្រះពុទ្ធអស់ពីដួងចិត្ត តែជាគំនិតកែទម្រង់ក្នុងលទ្ធិព្រាហ្មណ៍ ដោយយកពុទ្ធសាសនាធ្វើជាយាន និងជាមូលដ្ឋាន ក្នុងនោះ គេអាចសន្និដ្ឋានបានថា ការគោរពព្រះពុទ្ធជាថ្នាំពិសទៅវិញ។ នៅក្នុងផ្ទៃគម្ពីរ " វេទាន្ត " ទាំងមូល គេឃើញមានទ្រឹស្តីព្រះពុទ្ធភាគច្រើនបំផុត ហើយគំនិតទូទៅរបស់ឥណ្ឌាសព្វថ្ងៃនេះ ទាំងផ្នែកសំភារៈ និងចិត្ត គឺមានគម្ពីរ "វេទាន្ត " នេះជាមូលដ្ឋាន។ ដូចនេះហើយ បានជាសម័យ ដែលព្រាហ្មណ៍សាសនា

ប្រែប្រួល គេសង្កេតឃើញនៅទីបំផុត នៃលទ្ធិព្រាហ្មណ៍ក៏ត្រូវស្រុតចុះ ហើយពុទ្ធសាសនា ក៏បានរីករាលដាលជាបន្តបន្ទាប់ រហូតមកដល់ពេលបច្ចុប្បន្ននេះ ។

## ពុទ្ធប្រវត្តិ

### ១-អំពីកំណើត

ព្រះពុទ្ធមាននាមពីកំណើតគឺ "**សិទ្ធាថ** " ឬ "**សិទ្ធត្ថ** " កើតនៅក្នុងវង្សគោត្តម ។ ព្រះបិតានាម " **សុទ្ធោទន៏** " ជា ព្រះរាជា នៃបក្សសម្ព័ន្ធសាក្យ សោយរាជ្យនៅនគរកបិលភស្តុ នៅប្រទេសឥណ្ឌាប៉ែកខាងជើង សព្វថ្ងៃនេះ នៅក្នុងតំបន់ នៃប្រទេសនេប៉ាល់ ។

ព្រះមាតានាម " **សិរិមហាមាយា** " ជាបុត្រីរបស់ស្តេចបក្សសម្ព័ន្ធកោឡ្យ សោយរាជ្យនៅនគរទេវទហៈ មានព្រំប្រទល់ជាប់គ្នា ។

ព្រះអគ្គមហេសីនាម " **ពុម្ពាយសោធរា** " ជាបុត្រីរបស់សេ ╲ច " សុប្បពុទ្ធ " ។ ព្រះរាជបុត្រ មាននាមថា "***រាហុលកុមារ*** " ។

### ក-បុព្វហេតុនៃកំណើត

ព្រះនាង **សិរិមហាមាយា** បានសុបិននិមិត្ត ក្នុងពេលរាត្រីឃើញដំរីភ្លុកប្រាំមួយ ចុះពីឋានលើមក ហើយចូលក្នុងផ្ទៃព្រះនាងផ្នែកខាងស្តាំ ។ តាមទំនាយ ព្រះនាងនឹងបានបុត្រាមួយព្រះអង្គប្រកបដោយបុណ្យបារមីយ៉ាងលើសលប់ ។ តាមរឿងនិទានខ្លះៗថា ទេវបុត្រសន្តុសិតយាងចុះពីឋានតុសិតមកចាប់កំណើត ក្នុងផ្ទៃរបស់ព្រះនាង ។

### ខ-កំណើត

ព្រះពុទ្ធប្រសូត្រនៅថ្ងៃសុក្រ ១៥ កើតពេញបូរមី នៃខែពិសាខ ឆ្នាំ ច នៅក្រោមដើមសាលព្រឹក្ស ក្នុងព្រៃលុម្ពិនី ដែលស្ថិតនៅចំព្រំប្រទល់ នៃនគរកបិលភស្តុ និងនគរទេវទហៈ ។ នៅពេលប្រសូត្រ គេសង្កេតឃើញមានកើតភេទអស្ចារ្យណាស់ ។

ប្រសូត្របានប្រាំថ្ងៃ ពួកព្រាហ្មណ៍ ៨ នាក់ បានថ្វាយនាមព្រះឱរសថា "**សិទ្ធាថ** " ឬ "**សិទ្ធត្ថ** " ដែលមានន័យថា "អ្នក ដែលសម្រេចប្រយោជន៏គ្រប់បែបយ៉ាង " ។ ក្នុងពេលថ្វាយព្រះនាមកុមារ ព្រាហ្មណ៍ ៧ នាក់ បានលើកម្រាមដៃពីរ ហើយពោលថា " បើព្រះកុមារស្ថិតនៅជាក្សត្រ នឹងបានជាស្តេចចក្រពត្តិ បើព្រះអង្គសាងផ្នួស នឹងបានសម្រេចជាព្រះពុទ្ធ "។ ប៉ុន្តែ មានព្រាហ្មណ៍ម្នាក់ឈ្មោះ "**កោណ្ឌញ្ញៈ** " បានលើកម្រាមដៃមួយទាយថា " ទៅថ្ងៃក្រោយព្រះឱរស នឹងបានសម្រេចជា **ព្រះពុទ្ធ** "។

ប្រសូត្របាន ៧ ថ្ងៃ ព្រះមាតាព្រះនាម **សិរិមហាមាយា** បានយាងចូលទិវង្គតចោលព្រះអង្គទៅ។ ព្រះ**សិទ្ធត្ថ** ត្រូវព្រះមាតុច្ឆា ( ម្តាយមីង ) ព្រះនាម " **មហាបជាបតិគោតមី** " យកមកចិញ្ចឹមបីបាច់ ។

**គ_រាជាភិសេក**

លុះព្រះជន្មបាន ១៦ ឆ្នាំ ទ្រង់បានរៀបអភិសេកជាមួយនឹងព្រះនាង " **ពិម្ពាយសោធរា** "។ ដោយអផ្សុកខ្លាំងពេក ព្រះអង្គបានចេញទៅក្រសាលសួនឧទ្យាន ដែលស្ថិតនៅក្នុងព្រះបរមរាជាវាំង។ ក្នុងពេលចេញទៅក្រសាលទាំង ៤ លើក ព្រះអង្គទ្រង់បានទតឃើញទេពនិមិត្ត ៤ យ៉ាងដែរ។

- *លើកទី ១* ទតឃើញមនុស្សចាស់ជរា
- *លើកទី ២* ទតឃើញមនុស្សឈឺ
- *លើកទី ៣* ទតឃើញមនុស្សស្លាប់
- *លើកទី ៤* ទតឃើញមនុស្សអ្នកបួស

មនុស្សទាំង ៤ ប្រភេទនេះ បានធ្វើឱ្យព្រះអង្គកើតក្ដីសង្វេគ ហើយគិតឃើញច្បាស់ពីបញ្ហាជីវិតរបស់សត្វលោក។ មនុស្សប្រភេទទី ៤ បានធ្វើឱ្យព្រះអង្គមានសេចក្ដីសោមនស្សរីករាយចង់សាងផ្នួស។

**គ_ការសាងផ្នួស**

លុះដល់ព្រះជន្មបាន ២៩ ឆ្នាំ ព្រះ **សិទ្ធត្ថ** ទ្រង់នឿយណាយនឹងរាជសម្បត្តិ ហើយមានសេចក្ដីខ្ពើមរអើម លោកសន្និវាសកាន់តែខ្លាំងឡើងៗ។ ព្រះអង្គសព្វព្រះរាជហឫទ័យចង់ដោះស្រាយបញ្ហាជីវិត ហើយចង់ជ្រើសរើសយក ការសាងផ្នួសជាមធ្យោបាយ ដើម្បីសម្រេចនូវសម្មាសម្ពោធិញ្ញាណ។ នៅទីបំផុត ព្រះអង្គបានលះបង់ព្រះរាជវង្ស ហើយលួចរត់ទៅសាងផ្នួសទាំងរាត្រីស្ងាត់។

ក្រោយពេលដឹងថា **ព្រះសិទ្ធត្ថ** យាងទៅសាងផ្នួស **កោណ្ឌញ្ញ** ព្រាហ្មណ៍ និងបុត្រាព្រាហ្មណ៍ ៤ នាក់ទៀតក៏បានចេញទៅសាងផ្នួសដែរ។ អ្នកបួសទាំង ៥ ខាងក្រោមនេះ ហៅថា " **បញ្ចវគ្គិយ៍** " តាមបម្រើព្រះ **សិទ្ធត្ថ**។

ក្រោយពីបានសាកល្បងតបៈធមិតាមសាសនាព្រាហ្មណ៍ ជាមួយតាបសព្រាហ្មណ៍ពីរនាក់គឺ " **អាឡារតាបស** និង **ឧទកតាបស** " ពុំបានសម្រេចលទ្ធផលល្អ ព្រះអង្គក៏ខំប្រឹងតស៊ូស្វែងរកសច្ចធមិដោយខ្លួនឯងផ្ទាល់។

**២_ការត្រាស់ដឹង**

ក្រោយពីធ្វើទុក្ករកិច្ច " កិច្ច ដែលប្រតិបត្តិដោយពិបាក " អស់រយៈពេល ៦ វស្សាមក ព្រះអង្គបានយាងចេញពីរាជគ្រឹះ ធ្វើដំណើរទៅដល់ស្រុកពោធិគយា ក្នុងរដ្ឋមគធៈ។ ព្រះអង្គទ្រង់ បានធ្វើសម្មាធិនៅក្រោមដើមពោធិព្រឹក្ស កៀ្បរស្ទឹងនេរញ្ជរៈ ហើយព្រះអង្គទ្រង់បានផ្ចាញ់មារ។ ព្រះអង្គទ្រង់ត្រាស់ដឹងជាព្រះពុទ្ធនៅថ្ងៃពុធ ១៥ កើត ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្មាយុ ៣៥ ឆ្នាំ។

**៣_អំពីធម្មទេសនា**

លុះបានត្រាស់ដឹង នូវសម្មាសម្ពោធិញាណហើយ ព្រះពុទ្ធទ្រង់សម្ដែងធមិទេសនាទូទ្នានសត្វលោក ដោយពុំប្រកាន់វណ្ណៈឡើយ។ នៅពេលនោះ មានមនុស្សម្នាជាច្រើនបានសុំសិក្សារៀនសូត្រនៅក្នុងសំណាក់របស់ព្រះអង្គ។

ព្រះអង្គទ្រង់បានបំពេញពុទ្ធកិច្ចទាំង ៥ ប្រការ គឺជាកិច្ច ដែលព្រះអង្គត្រូវបំពេញអស់រយៈកាល ៤៥ ឆ្នាំ។

- *នៅពេលព្រឹក* ទ្រង់និមន្តបិណ្ឌបាត

- *ពេលរសៀល* ទ្រង់សម្តែងធម៌ទេសនាដល់មហាជន
- *ពេលព្រលប់* ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ
- *ពេលកណ្តាលអាធ្រាត* ទ្រង់ដោះស្រាយប្រស្នាធំៗរបស់ពួកទេវតា
- *ពេលទៀបភ្លឺ* ទ្រង់ប្រមើលមើល នូវទុក្ខវេទនារបស់សត្វលោក

**៤. អំពីបរិនិព្វាន្ត**

នៅពេលចេញវស្សាគំរប់ ៤៥ ឆ្នាំ ថ្ងៃ ១៥ កើតពេញបរមី ខែ មាឃ ឆ្នាំ ម្សាញ់ ព្រះពុទ្ធទ្រង់បានដាក់អាយុសង្ខាររបស់ព្រះអង្គ ដោយប្រាប់ពួកមារថា "ព្រះអង្គនឹងចូលនិព្វាន្តហើយ"។ ព្រះអង្គយាងទៅដល់នគរកុសិនារា ហើយទ្រង់យាងចូលសាលវ័ន្ត " **ព្រៃ** "។ ព្រះអង្គត្រាស់ឱ្យ **អានន្ទ** រៀបចំគ្រែថ្វាយព្រះអង្គផ្ទំ " ផ្ទំផ្អៀងទៅខាងស្តាំ ព្រះបាតឆ្វេងត្រួតលើព្រះបាទស្តាំ "។ នៅបច្ឆិមរាត្រី ព្រះអង្គទ្រង់ត្រាស់ទៅភក្ខុសង្ឃទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ***តថាគត*** ប្រាប់ថា " អ្វីៗដែលកើតឡើង ដែលមានហើយ ដែលផ្គុំផ្សំហើយ តែងតែមានសកម្មភាព និងរលត់ទៅជាធម្មតា ។ អ្នកទាំងឡាយចូលញ៉ាំងប្រយោជន៍ដោយកិរិយាមិនធ្វេសប្រហែសចុះ "។ ព្រះអង្គមានពុទ្ធដិកាតែប៉ុណ្ណោះ ទ្រង់ក៏រលត់សង្ខារពេលនោះទៅ។

ព្រះពុទ្ធបានចូលបរិនិព្វាន្តនៅថ្ងៃ ១៥ កើត ខែ ពិសាខ ឆ្នាំ ម្សាញ់ " ៥៤៣ មុនគ.ស " នៅក្នុងព្រះជន្មាយុ ៨០ ព្រះវស្សា។

## ទ្រឹស្ដីសំខាន់ៗ របស់ព្រះពុទ្ធ

*អរិយសច្ចៈ* គឺជាការពិតដ៏ប្រសើរ ។ ព្រះពុទ្ធបានរកឃើញអរិយសច្ចៈ ៤ ប្រការហៅថា អរិយសច្ចៈទាំង ៤ ឬ ចតុរារិយសច្ចៈ ដែលមានដូចខាងក្រោមនេះ ÷

**១-ទុក្ខអរិយសច្ចៈ**

គឺជាទុក្ខ នៃសេចក្ដីពិត ដែលកើតមានឡើងដល់មនុស្សសត្វគ្រប់រូប និងពុំអាចចៀសផុតបានឡើយ គ្រាន់តែអ្នកខ្លះមានទុក្ខតិច អ្នកខ្លះទៀតមានទុក្ខច្រើន ។ ទុក្ខធំៗ រួមមាន ÷

- *ជាតិទុក្ខ* : ទុក្ខព្រោះមានកំណើត
- *ព្យាធិទុក្ខ* : ទុក្ខព្រោះមានជំងឺបៀតបៀន
- *ជរាទុក្ខ* : ទុកព្រោះចាស់ជរា
- *មរណៈទុក្ខ* : ទុកព្រោះសេចក្ដីស្លាប់

ក្រៅពីទុក្ខធំទាំង ៤ នេះ នៅមានទុក្ខជាច្រើនទៀត ដូចជាទុក្ខកើតឡើងដោយសារការព្រាត់ប្រាស់ មិនបានដូចបំណងប្រាថ្នា ។

**២-សមុទយអរិយសច្ចៈ**

គឺជាសេចក្ដីពិត ដែលទទួលកើតឡើងមកពីហេតុ ។ ហេតុដែលនាំឱ្យមានទុក្ខមាន ២ យ៉ាងធំៗ គឺ ÷

✡ *អវិជ្ជា តណ្ហា*

*អវិជ្ជា* គឺជាសេចក្ដីល្ងង់ខ្លៅ ឬមិនដឹង មិនយល់នូវហេតុ ដែលនាំឱ្យមានទុក្ខ ។ អវិជ្ជានេះ នាំឱ្យកើតមានឡើងនូវតណ្ហា ។ តណ្ហានេះ ជាឫសគល់ដ៏ចំបង ដែលនាំឱ្យមានទុក្ខគ្រប់ប្រការ ហើយនិងនាំឱ្យមានកំណើតជាបន្តបន្ទាប់មិនដាច់ដូចក្នុងទ្រឹស្ដីបដិច្ចសមុប្បាទ ។

**៣-និរោធអរិយសច្ចៈ**

គឺជាការរួចស្រឡះ ឬរលត់ទុក្ខជាសេចក្ដីពិត ។ កន្លែងរលត់ទុក្ខ គឺនិព្វាន្ទ ។ ដើម្បីបំបាត់ទុក្ខឱ្យអស់រលីងត្រូវបំបាត់ ឬរំលាយតណ្ហា និងអវិជ្ជា ។

**៤-មគ្គអរិយសច្ចៈ**

គឺជាមធ្យោបាយ ដែលនាំឱ្យផុតទុក្ខ ជាសេចក្ដីពិត ។ ដើម្បីរំលត់ទុក្ខ ហើយទៅដល់និព្វាន្ទ ព្រះពុទ្ធបានបញ្ជាក់ថា ត្រូវប្រកាន់យកផ្លូវកណ្ដាល ហើយប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវមគ្គៈ ៨ យ៉ាង " អដ្ឋង្គិកមគ្គ " គឺ ÷

❖ **សម្មាទិដ្ឋិ :** គឺការយល់ឃើញតាមផ្លូវត្រូវ ឬការយល់ឃើញពិតនូវសភាវធម៌ទាំងឡាយ ។

❖ **សម្មាសង្កប្ប :** គឺការត្រិះរិះត្រឹមត្រូវ មិនព្យាបាទ មិនបៀតបៀនចំពោះមនុស្សសត្វទូទៅ ការត្រិះរិះត្រឹមត្រូវនាំឱ្យជួបប្រទះ នូវផលល្អ សេចក្តីសុខចំរើន ។

❖ **សម្មាវាចា :** គឺវាចារត្រឹមត្រូវ វាចាកនូវវិចីរទុច្ចរិត ៤ យ៉ាង គឺ ÷

- *មុសាវាទ* " ពាក្យមិនពិត ភូតភរ កុហក់ "
- *បិសុនាវាទ* " ពាក្យសៀតសឹក ញោះញង់ បំបែកបំបាក់ "
- *សម្ផប្បលាវាទ* " ពាក្យឡេះឡោះ កំប្លែង សើចលេងឥតប្រយោជន៍ "
- *ផរុសវាទ* " ពាក្យឌឺដង បញ្ចិតបញ្ចៀង ជេរប្រទេច "

❖ **សម្មាកម្មន្ត :** គឺការប្រព្រឹត្តល្អ វៀរចាកនូវកាយទុច្ចរិត ៣ យ៉ាង គឺ ÷

- *អទិន្នា* " ការមិនលួចប្រពន្ធអ្នកដទៃ "
- *បាណា* " ការមិនសម្លាប់សត្វមានជីវិត "
- *កាមេ* "ការមិនប្រតិបត្តិខុសច្បាប់ លួចប្រពន្ធកូនគេ "

❖ **សម្មាអាជីវៈ :** ការប្រកបរបចិញ្ចឹមជីវិតតាមផ្លូវត្រូវ គឺព្យាយាមខាងផ្លូវចិត្ត មិនលួចប្លន់ទ្រព្យសម្បត្តិរបស់អ្នកដទៃ "

❖ **សម្មាវាយាម :** គឺការព្យាយាមត្រឹមត្រូវ គឺព្យាយាមខាងផ្លូវចិត្ត ផ្លូវគំនិត ដូចជាការការពារមិនឱ្យមានបាបអកុសល ឬសៅហ្មង ដែលកើតមានឡើងនៅខ័ណ្ឌសណ្តាន និងព្យាយាមខាងផ្លូវកាយ ដូចជាព្យាយាមធ្វើអំពើល្អៗ គ្រប់បែបយ៉ាង ឬព្យាយាមរក្សាអំពើល្អ ដែលកើតមានឡើង ។

❖ **សម្មាសតិ :** គឺការរំលឹកនឹកឃើញ និងដឹងខ្លួនជានិច្ច ក្នុងសតិត្រឹមត្រូវ ។

❖ **សម្មាសមាធិ :** គឺការចំរើនឈានទៅរកការភាវនា ដើម្បីតម្កល់ចិត្តឱ្យល្អត្រឹមត្រូវ មិនឱ្យរវើរវាយអណ្តែតអណ្តូង ពោលគឺតាំងចិត្តស៊ុបជានិច្ច ក្នុងអារម្មណ៍តែមួយ ។

មគ្គទាំង ៨ យ៉ាងនេះ អាចសង្ខេបមកនៅត្រឹម ៣ យ៉ាងគឺ ÷

| | | | | | |
|---|---|---|---|---|---|
| *សីល* | - សម្មាវាចា<br>- សម្មាកម្មន្ត<br>- សម្មអាជីវៈ | សម្មាធិ | - សម្មាវាយាម<br>- សម្មាសតិ<br>- សម្មាសមាធិ | បញ្ញា | - សម្មាសង្កប្ប<br>- សម្មាទិដ្ឋិ |

*ដើម្បីបញ្ចប់សង្គ្រាមរវាងជាតិ និងជាតិ និងដើម្បីផ្សះផ្សារជាតិ តាមទស្សនៈពុទ្ធសាសនាមនុស្សម្នាក់ៗ ត្រូវអប់រំចិត្តក្នុងគុណធម៌អ្វីខ្លះ ?*

✡ គោរពគ្នាទៅវិញទៅមក ចេះលើកស្ទួយ និងចេះការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស ដោយប្រតិបត្តិតាមសីលធម៌ ជានិច្ច ដូចដែលព្រះបរមគ្រូ នៃយើងបានហាមប្រព្រឹត្តអំពើ ១០ ប្រការ ដែលផ្ទុយនឹងសិទ្ធិមនុស្ស ÷

- កាយកម្មបី ដោយអំពើ មិនត្រូវសម្លាប់ មិនត្រូវលួច មិនត្រូវរំលោភភេទនានា
- វិចីកម្មបួន ដោយវាចា មិនត្រូវភូតកុហក់ មិនត្រូវនិយាយញុះញង់ មិនត្រូវនិយាយត្រគោះបោះបោក មិនតូវនិយាយពាក្យមិនបានការ ។
- មនោកម្មបី ដោយចិត្ត មិនត្រូវចង់បានរបស់គេ មិនត្រូវគុំគួនព្យាបាទគេ មិនត្រូវប្រែក្លាយការពិត

✡ ***ព្រហ្មវិហារធម៌ទាំង ៤*** ÷

- មេត្តា ស្រឡាញ់រាប់អានគ្នាដោយភាពស្មោះត្រង់
- ករុណា អាណិតអាសូរគ្នាទៅវិញទៅមក
- មុទិតា មិនត្រូវច្រណែននឹងអ្នកដទៃបានសុខ
- ឧបេក្ខា ធ្វើចិត្តឱ្យនៅកណ្តាល មិនលម្អៀង

*មនុស្សគ្រប់រូបសុទ្ធតែចង់បានសេចក្តីសុខ។ ដើម្បីសម្រេចបាននូវសេចក្តីសុខ តើត្រូវធ្វើអ្វីខ្លះ ? សុខមានប៉ុន្មានយ៉ាង ?*

សេចក្តីសុខទាំង ៥ ប្រការ ដែលមនុស្សគ្រប់រូបចង់បានគឺ ÷

- *សេចក្តីសុខ* ព្រោះតែមានមាស-ប្រាក់ និងទ្រព្យសម្បត្តិ
- *សេចក្តីសុខ* ព្រោះតែបានប្រើប្រាស់ទ្រព្យធន
- *សេចក្តីសុខ* ព្រោះតែគ្មានជំពាក់បំណុលគេ
- *សេចក្តីសុខ* ព្រោះតែពុំដែលមានទោស និងជម្ងឺឈឺថ្កាត់
- *សេចក្តីសុខ* ព្រោះតែមានសន្តិសុខ និងគ្មានសង្គ្រាម

ដើម្បីសម្រេចបាននូវសេចក្តីសុខទាំងអស់ខាងលើនេះ ម្នាក់ៗ ត្រូវតែកសាងអំពើល្អគ្រប់បែបយ៉ាងទាំងកាយ វាចា និងចិត្ត ។

## អំពីពុទ្ធលទ្ធិ

ទស្សនៈទ្រឹស្តីរបស់ព្រះពុទ្ធទាំងប៉ុន្មាន គឺស្ថិតនៅក្នុងគម្ពីរត្រៃបិដក ក្នុងលទ្ធិពុទ្ធសាសនា។ គម្ពីរត្រៃបិដក គឺជាឃ្លាំងសំរាប់ផ្ទុកនូវពុទ្ធវចនៈ។ " ពាក្យសំដីរបស់ព្រះពុទ្ធ " ពោលគឺ ឱវាទរបស់ព្រះអង្គ ដែលបានសម្តែងធម្មទេសនា ក្នុងរយៈពេល ៤៥ វស្សា ចាប់តាំងពីពេលដែលទ្រង់បានត្រាស់ដឹង រហូតដល់ទ្រង់ចូលបានចូលនិព្វាន។ ពុទ្ធវចនៈទាំងនេះ ហៅថា **ធម្មវិន័យ** ។ ធម្មវិន័យនេះមាន ៣ ចំណែកគឺ ៖

- ✡ សុត្តន្ត
- ✡ វិន័យ
- ✡ អភិធម្ម

ធម្មវិន័យទាំងបីចំណែកនេះ ព្រះថេរទាំងឡាយបានសង្គាយនា "ចេញដោយផ្ទៀងផ្ទាត់"។ *ឧទាហរណ៍ :* ទេសនាសង្គាយនាត្រៃបី។ ក្រោយមក បានចងក្រងទុកជាក្រុមហៅថា " **បិដក** "។ គម្ពីរព្រះត្រៃបិដក មានចំនួនច្រើនជាង គម្ពីរវេទ ច្រើនជាងគម្ពីរប៊ីប ១១ ដង។ គម្ពីរត្រៃបិដក ជាគម្ពីរសាសនាពេញបរិបូណ៌ ពីព្រោះវាមិនមែនជាវចនៈរបស់អាទិទេព ដូចក្នុងលទ្ធិព្រាហ្មណ៍ឡើយ។ ក្រោយពេល ដែលព្រះពុទ្ធចូលបរិនិព្វានភ្លាម ត្រូវបានធ្វើសង្គាយនាយ៉ាងផ្ទៀងផ្ទាត់ នាំឱ្យរក្សាទុកនូវភាពដើមមិនលម្អៀង។ គម្ពីរព្រះត្រៃបិដកមាន ៣ ចំណែកគឺ ៖

- *វិន័យបិដក* មាន ១១ ភាគ
- *សុត្តន្តបិដក* មាន ៦៤ ភាគ
- *អភិធម្មបិដក* មាន ៣៣ ភាគ

### ក. វិន័យបិដក

វិន័យបិដក គឺជាគម្ពីរដែលស្តីអំពីក្រឹតក្រម ដែលព្រះសម្មាសម្ពុទ្ធបានបញ្ញត្តិទុកជាផ្លូវ សម្រាប់ប្រតិបត្តិរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាទាំងឡាយ។ គម្ពីរនេះ ជាកញ្ចក់ សម្រាប់ឆ្លុះបញ្ចាំងកាល ដែលព្រះអង្គទ្រង់គង់នៅជាធរមាននៅឡើយ។

វិន័យបិដកនេះ មាន ៥ គម្ពីរគឺ ៖

- *អាទិកម្ម* " ទោសធ្ងន់ "

- *បាចិត្តិយ* " ទោសស្រាល "
- *មហាវគ្គ* " វគ្គធំ "
- *ចុល្លវគ្គ* " វគ្គតូច "
- *បរិវារ* " បន្ទាប់បន្សំ រាយរង "

**ខ-សុត្តន្តបិដក**

សុត្តន្តបិដក គឺជាគម្ពីរសូត្រ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម្មទេសនា។ មានសូត្រខ្លះ ត្រូវសម្តែងដោយព្រះអរិយសាវ័ក ដូចជាព្រះ **សារីបុត្តត្ថេរ** ព្រះ **មោគ្គល្លានត្ថេរ** ព្រះ **អានន្ទត្ថេរ** ជាដើម។ គម្ពីរសុត្តន្ត ឬព្រះសូត្រមាន ៥ គម្ពីរ គឺ ÷

១-ទិឃនិកាយ : សូត្រមានខ្លឹមសារពិស្តារ

២-មជ្ឈិមនិកាយ : សូត្រមានខ្លឹមសារជាមធ្យម

៣-សំយុត្តនិកាយ : សូត្រមានសេចក្តីប្រហែលគ្នា

៤-អង្គុត្តរនិកាយ : សូត្រមានសេចក្តីជាក្រុម ជាពួក

៥-ខុទ្ទកនិកាយ : សូត្រដោយខ្លីៗ

ក្រៅពីនេះ មានចែកចេញជានិកាយតូចៗចំនួន ១៥ និកាយទៀត គឺ ÷

១- ខុទ្ទកបាឋ : អត្ថបទខ្លីៗ

២- ធម្មបទ : ផ្លូវនៃសច្ចះធម៌

៣- ឧទាន : គាថាធ្វើឱ្យរីករាយ

៤- ឥតិវុត្តក : សូត្រថាមានដូច្នេះ

៥- វិមានវត្ថុ : សូត្រពីវិមាននៅវេហ៊ុរ៍

៦- បេតវត្ថុ : និទានពីប្រេត

៧- ថេរគាថា : គាថាព្រះថេរទេសនា

៨- ថេរីគាថា : គាថាព្រះថេរីទេសនា

៩- ជាតក : និទានជាតក

១០- និទ្ទេស : ការសម្តែងពន្យល់

១១- បដិសម្ភិទា : វិជ្ជាវិភាគ

១២- អបទាន : ជីវភាពព្រះអរហន្ត

១៣- ពុទ្ធវង្ស : ប្រវត្តិព្រះសម្មាសម្ពុទ្ធ

១៤- ចរិយបិដក : វិធីប្រតិបត្តិតាមពុទ្ធចរិយា

**គ-អភិធម្មបិដក**

អភិធម្មបិដក គឺជាគម្ពីរ ដែលនិយាយរៀបរាប់អំពីធម៌អាថិយ៉ាងជ្រាលជ្រៅបំផុត។ វាជាអត្ថបទ ដែលផ្ទុយពីសុត្តន្តបិដក។ អភិធម្មបិដកជាបរមត្ថទេសនាស្តីពីចិត្ត ចេតសិក រូបនិព្វាន្ត។ គម្ពីរនេះ ទុកឱ្យសត្វលោកធ្វើការរែកញែកយ៉ាងល្អិតល្អន់បំផុត។ គម្ពីរនេះ ចែកចេញជា ៧ គម្ពីរ គឺ ÷

**១. ធម្មសង្គណី** : ការចាត់របៀបធម៌

**២. វិភង្គ** : ការបែងចែកធម៌

**៣. កថាវត្ថុ** : ចំណុចធម៌ដែលមានសេចក្តីផ្ទុយគ្នា

**៤. បុគ្គបញ្ញត្តិ** : បញ្ញត្តិថាជាបុគ្គល

**៥. ធាតុកថា** : ការរែកញែកធាតុ

**៦. យមក** : ធម៌គូរៗគ្នា

**៧. បដ្ឋាន** : ធម៌បច្ច័យទាក់ទងគ្នា

បិដកទាំងបីនេះ មានឈ្មោះថា តិបិដក ឬត្រៃបិដក។

**អំពីសង្គាយនា**

*ទី ១ :* ដើម្បីរក្សា នូវភាពដើម នៃពុទ្ធវចនៈ ក្រោយពេលដែលព្រះពុទ្ធបរិនិព្វាន្តភ្លាម មហាថេរទាំងឡាយបានចាត់ចែងធ្វើសង្គាយនា មានព្រះ **មហាកស្សបត្ថេរ** ជាប្រធាន ជាអ្នកសួរ ព្រះ **ឧបាលិត្ថេរ** ជាអ្នកឆ្លើយ។ តមកសួរធម៌ព្រះ **អានន្ទត្ថេរ** ជាអ្នកឆ្លើយ។ កាលនោះ មិនមានចារឹកជាលាយល័ក្ខណ៍អក្សរទេ ការសួរឆ្លើយត្រឹមត្រូវ ហើយព្រះ **អារហន្ត** ទាំង ៥០០ អង្គស្វាធ្យាយ គឺសូត្រព្រមៗគ្នាទាំង ៥០០ អង្គ ទាល់តែមានការចងចាំស្ទាត់។ ការចងចាំបែបនេះ ហៅថា " **មុខបាឋ** " សង្គាយនានេះ បានធ្វើឡើងក្រោយពេល ដែលព្រះពុទ្ធបរិនិព្វាន្តបាន ៣ ខែ មុនគ.ស ២៧៦ ឆ្នាំ ហើយបានធ្វើឡើងនៅក្នុងក្រុងរាជគ្រឹះ លើភ្នំវេភារៈ ឈ្មោះសត្តបណ្ណគុហារ ក្រោមការជួយឧត្ថម្ភរបស់ព្រះបាទ **អជាតសត្រូវ** ដែនមគធៈ សព្វថ្ងៃជារដ្ឋពិហាររបស់ប្រទេសឥណ្ឌា។

*ទី ២ :* អស់រយៈពេលមួយរយឆ្នាំក្រោយមក មានការប្រតិបត្តិខុសគន្លងពុទ្ធបញ្ញត្តិ ធ្វើឱ្យមានសង្គាយនាជាលើកទីពីរ។ សង្គាយនានេះ ធ្វើឡើងនៅក្រោមអធិបតីភាពរបស់ព្រះ **សព្វកាមិត្ថេរ** ព្រះ **រេវតត្ថេរសហជាតិ** ជាអ្នកសួររីឯព្រះ **សព្វកាមិត្ថេរ** ជាអ្នកឆ្លើយ ព្រះ **សង្គតិកាចារ្យ** ជាព្រះអរហន្ត ៧០០ អង្គ ធ្វើនៅវត្តវាលុការាម ក្រុងវេសាលីដែនវជ្ជី ក្រោមព្រះរាជជួយឧបត្ថម្ភរបស់ព្រះបាទ ***កាលាសោក*** ជាព្រះរាជាក្រុងបាដលិបុត្តប្រទេសឥណ្ឌា។ ព.សបានកន្លងទៅបាន ១០០ ឆ្នាំ គឺមុនគ.ស ៣៧៧ ឆ្នាំ សង្គាយនានេះមានឈ្មោះថា ទុតិយសង្គាយនា បានធ្វើឡើងអស់ថេរវេលា ៨ ខែ ទើបចប់។

*ទី ៣ :* ក្រោយពេលព្រះពុទ្ធបរិនិព្វាន្តបាន ២១៨ ឆ្នាំ មានការច្របូកច្របល់ ក្នុងពុទ្ធសាសនា ពីព្រោះនៅពេលនោះ មានអ្នកកាន់សាសនាព្រាហ្មណ៍មកបួសបន្លំខ្លួន ក្នុងរជ្ជកាលព្រះបាទ **អសោកមហារាជ**។ សង្គាយនានេះ ចាត់ទុកជាមហាសង្គាយនាដ៏ល្អប្រពៃមួយ ដើម្បីរក្សាទុកភាពបរិសុទ្ធធម្មវិន័យ ឱ្យនៅគង់វង្សដូចដើម។ សង្គាយនានេះប្រព្រឹត្តទៅអស់រយៈពេល ៨ ខែ។

*ទី ៤ :* សង្គាយនានេះ ប្រព្រឹត្តទៅនៅប្រទេសឥណ្ឌា ធ្វើនៅដែនកស្មីរ ក្រោមព្រះរាជជួយឧបត្ថម្ភរបស់ព្រះបាទ **កសិស្កៈ**។ សង្គាយនានេះ មានការចូលរួមពីព្រះ **មហិន្ទត្ថេរ** ជាព្រះរាជបុត្ររបស់ព្រះបាទ **អសោកមហារាជ** ជាសមណទូត ឱ្យទៅផ្សព្វផ្សាយពុទ្ធសាសនានៅលង្កាទ្វីប និងព្រះនាង **សង្ឃមិត្តាថេរ** ជាព្រះរាជបុត្រី នាង **អនុឡាទេវី** ជាព្រះអនុជថ្លៃ ក្រោមការប្រោសប្រណីរបស់ព្រះមហាក្សត្រកោះលង្កា និងប្រជារាស្ត្រ។

ដើម្បីប្រតិស្ឋានពុទ្ធសាសនា ព្រះបាទ **ទេវានម្បិយតិស្ស** " មហាក្សត្រកោះលង្កា " ក្រាបបង្គំទូលថ្វាយព្រះ **មហិន្ទត្ថេរ** សូមធ្វើសង្គាយនាធម៌វិន័យ។ មុននឹងធ្វើសង្គាយនា ព្រះបាទ **ទេវានម្បិយតស្ស** បានបញ្ជូនទូតឱ្យចូលទៅបង្គំគាល់ដល់ព្រះបាទ **ធម្មាសោកមហារាជ** នៅជម្ពូទ្វីប ប្រទេសឥណ្ឌា។

កាលនោះ ព្រះសង្ឃបានសិក្សាព្រះពុទ្ធវចនៈចេះចាំស្ទាត់ច្រើនអង្គ ហើយបានចូលរួមធ្វើសង្គីតិភាចារ្យនៅវត្តថូបារាម ក្នុងក្រុងអនុរាធបុរៈ ធ្វើអស់រយៈពេល ១០ ខែ "ព.ស ២៣៦ មុនគ.ស ២៤១ ឆ្នាំ "។

*ទី ៥ :* ព្រះមហាក្សត្រកោះលង្កា បានប្រោសប្រណី ឱ្យកសាងវត្តមួយនៅក្រុងអនុរាធបុរៈ "អភយវិហារ " ប្រគេនដល់មហាថេរ ដែលមាននាមថា **តិស្ស** ជាអ្នកតែងគម្ពីរមួយឈ្មោះថា វិមុត្តិមគ្គគម្ពីរ វិសុទ្ធិមគ្គ ជាស្នាដៃពុទ្ធ-ឃោសាចារ្យ។

ព្រះមហាថេរអង្គនេះ កាន់តាមសិទ្ធិវជ្ជីបុត្តិភិក្ខុ ដែលផ្ទុយនឹងធម្មវិន័យក្នុងពុទ្ធសាសនា។ សង្គាយនាទី ៥ នេះ ព្រះ **ពុទ្ធត្ថេរ** ជាប្រធាន ជាអ្នកសួរ ព្រះ **តិស្សត្ថេរ** ជាអ្នកឆ្លើយ ហើយដែលប្រព្រឹត្តទៅអស់រយៈពេលមួយឆ្នាំទើបចប់ " ព.ស ៥២០ មុនគ.ស ២៤ ឆ្នាំ "។

ពេលនោះហើយ ដែលនាំឱ្យកើតមានជាការចារឹកជាលាយល័ក្ខណ៍អក្សរ មុនដំបូងបង្អស់នៅក្នុងប្រវត្តិរបស់ពុទ្ធសាសនា។

*តើព្រះពុទ្ធសាសនាមហាយាន និងហិនយានមានសភាពលក្ខណៈខុសប្លែកគ្នាយ៉ាងណាខ្លះ ?*

សភាពខុសគ្នា

| ❖ ***មហាយាន ( ជើង )*** | ❖ ***ហីនយាន ( ត្បូង )*** |
|---|---|
| • មហាយានជាយានធំនាំសត្វលោកទៅកាន់ត្រឹមតែព្រះពោធិសាត់បានច្រើន។ | • ហីនយានជាយានតូច នាំសត្វលោកទៅកាន់ត្រើយនិព្វានបានតិច។ |
| • ស្លៀកសម្លៀកបំពាក់ពណ៌លឿង | • គ្រងស្បង់ចីវរពណ៌លឿង |
| • គោរពអាចារ្យមួយៗ ( អាចរិយវាទ) | • គោរពតាមពុទ្ធឱវាទ នៃព្រះសម្មាសម្ពុទ្ធ |
| • វិន័យធូរស្រាល | • វិន័យតឹងតែង |
| • គោរពធម៌ថ្មី គម្ពីរថ្មី | • គោរពគម្ពីរត្រៃបិដក |

លក្ខណៈខុសគ្នា

| | |
|---|---|
| • បំណងទៅកាន់តួនាទីជាពោធិសាត់ | • បំណងទៅកាន់និព្វាន និងព្រះអរហន្ត |
| • តួនាទីជាពោធិសាត់ តែមានសទ្ធា និងជំនឿស្មោះត្រង់លើព្រះ។ | • ភិក្ខុទើបអាចទៅកាន់និព្វានបាន |
| • កុសលរបស់ខ្លួនអាចផ្សព្វផ្សាយដល់អ្នកដទៃ | • ជឿលើកម្លាំងខ្លួន " អត្តាហិ អត្តនោនាថោ " |
| • ជឿលើព្រះពោធិសាត់ លោកេស្វរៈ ឬអវលោ- | • ជឿលើព្រះសម្មាសម្ពុទ្ធ |

*តើការប្រាសចាកសីលធម៌របស់មនុស្សខ្មែរ បានផ្តល់ផលវិបាកអ្វីខ្លះដល់ខ្លួនឯង គ្រួសារ និងសង្គម ?*

✡ *ចំពោះខ្លួនឯង :*

សង្គមស្អប់ខ្ពើម មិនទទួលស្គាល់ បាត់បង់តម្លៃជាមនុស្ស គ្មានញាតិមិត្តគ្រួសាររាប់អាន ត្រូវច្បាប់ផ្តន្ទាទោស ( ច្បាប់រដ្ឋ ច្បាប់សង្គម សាសនា ) ប៉ះពាល់សុខភាព បាត់បង់ជីវិត ខាតបង់ប្រាក់កាស ទ្រព្យសម្បត្តិ បាត់បង់អនាគត ក្នុងឆាកជីវិត ។

*ឧទាហរណ៍ :* ការលួចឆក់ប្លន់គេ សេពគប់គ្រឿងញៀន លេងល្បែងស៊ីសង បៀរបៀ៉ កន្ទុយលេខ ចាក់បាល់ ( អំពើអបាយមុខទាំង ៣ ) ។

✡ *ចំពោះគ្រួសារ :*

បាត់បង់កិត្តិយស កម្លាំងពលកម្ម ថវិកា ឬសេដ្ឋកិច្ច កើតមានអំពើហិង្សាក្នុងគ្រួសារ ខ្វះភាពកក់ក្តៅក្នុងគ្រួសារ ខ្វះការទទួលខុសត្រូវក្នុងគ្រួសារ ខ្វះការគោរព និងជំនឿទុកចិត្ត ។

✡ *ចំពោះសង្គម :*

បាត់បង់ធនធានមនុស្ស ប្រទេសជាតិអាប់ឱនកិត្តិយស គ្មានការរីកចម្រើន បាត់បង់ថវិកាជាតិ បាត់បង់ការគោរពច្បាប់ បាត់បង់តម្លាភាព បាត់បង់ការអភិវឌ្ឍ បាត់បង់សន្តិសុខ សង្គមអនាធិបតេយ្យ និងលទ្ធផលមិនអាចយកជាការបាន ។

សរុបមក សីលធម៌មានសារៈសំខាន់ណាស់ សម្រាប់ធ្វើឱ្យបុគ្គលមានមនសិការ ក្នុងជីវិតរស់នៅ ។

*គេនិយាយថា " បើចង់កែលម្អ ឬកសាងមនុស្ស ត្រូវពិចារណា និងកសាងមជ្ឈដ្ឋាន ដែលមនុស្ស " ។ ពាក្យ នេះ មានន័យយ៉ាងណា ?*

ការកែលម្អ ឬកសាងមនុស្ស ដែលទាក់ទងនឹងការអប់រំ ទាំងក្នុងសាលារៀន ទាំងក្នុងមជ្ឈដ្ឋាន ដែលមនុស្សរស់នៅមានមានសេចក្តីដូចតទៅ ÷

- កែលម្អ មានន័យថា កែឱ្យបានល្អ ធ្វើឱ្យល្អ កែពីអំពើអាក្រក់ឱ្យមកជាអំពើល្អ
- កសាង មានន័យថា ធ្វើឱ្យកើតមានឡើង បណ្តុះបណ្តាល.........
- មជ្ឈដ្ឋាន មានន័យថា ទីកន្លែង សង្គមមនុស្ស សហគមន៍

✡ *ស្ថានភាពសង្គមបច្ចុប្បន្នមាន ÷*

• ភាពក្រីក្រតោកយាក

• សីលធម៌មិនទាន់ល្អ ពិសេសការគោរពច្បាប់

• ទទួលឥទ្ធិពលមិនល្អ នៃវប្បធម៌បរទេមកលើវប្បធម៌ជាតិ " តន្រ្តី ភាពយន្ត វីដេអូ អាកប្បកិរិយា ដេក ដើរ ឈរ អង្គុយ និយាយស្តី សំភារៈ......." ។ ចំណុចទាំងអស់នេះ ជាសេរីភាពគ្មានព្រំដែន ដែលនាំឱ្យប៉ះពាល់ដល់ ទំនៀមទំលាប់ ប្រពៃណីជាតិ ជាពិសេសយុវជនយើង

• ការអភិវឌ្ឍធនធានមនុស្ស នៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់សង្គមជាតិ " បំណិនវិជ្ជាជីវៈ និង ទីផ្សារពលកម្ម "

• ការយល់ដឹង នៅមានកម្រិតទាប ស្តីពីការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ បរិស្ថាន វប្បធម៌ជាតិ សុខភាព ......។

• នៅមានអំពើពុករលួយ សីលធម៌ គុណធម៌នៅមានកម្រិត..........។

*✡ មធ្យោបាយ និងវិធានការ ÷*

• បណ្តុះបណ្តាលធនធានមនុស្សឱ្យមានស្មារតីស្នេហាជាតិ " ព្រលឹងជាតិ អត្តសញ្ញាណជាតិ......"

• ផ្សព្វផ្សាយវប្បធម៌ជាតិឱ្យបានច្រើនជាងវប្បធម៌បរទេស

• បង្កើតស្នាដៃវប្បធម៌ជាតិ ឱ្យបានច្រើនជាងបរទេស

• ទប់ស្កាត់ ឱ្យខានតែបាននូវឥទ្ធិពលទាំងឡាយណា ដែលមិនល្អ ដែលជាវប្បធម៌បរទេស

• លើកកម្ពស់ការយល់ដឹងពីដួងព្រលឹងជាតិ អត្តសញ្ញាណជាតិ វប្បធម៌ជាតិ

• កាត់បន្ថយភាពក្រីក្ររបស់ប្រជាជាតិ ដោយបំបាត់អំពើពុករលួយ អំពើហឹង្សា ការជួញដូរគ្រឿងញៀន ការ ជួញដូរមនុស្ស ការប្រើអាវុធខុសច្បាប់ ល្បែងស៊ីសងខុសច្បាប់ ពិសេសអនក្ខរភាពនៅក្នុងសង្គម និងរាល់បាតុភាពជា អវិជ្ជមាន។

• អភិវឌ្ឍសហគមន៍ ដោយបង្កើនបំណិនវិជ្ជាជីវៈ ស្របតាមទីផ្សារពលកម្មសេរី ដោយជួយឧបត្ថម្ភទាំងស្មារតី និង សំភារៈ។

*✡ កសាងមនុស្សល្អ យុវជនល្អ និងពលរដ្ឋល្អ ÷*

• កាយសម្បទាមាំមួន សុខភាពល្អ មានភាពរាងវៃ រហ័សរហួន

• បញ្ញាសម្បទា ផ្នែកចំណេះដឹងទូលំទូលាយ មានបច្ចេកវិទ្យា វិទ្យាសាស្រ្តទំនើប ចេះប្រើគ្រឿងអេឡិចត្រូនិច

• ចំណេះធ្វើ មានបទពិសោធន៍ និងសិក្សាស្រាវជ្រាវ

• សីលសម្បទា មានសីលធម៌ គុណធម៌ជឿនលឿន គ្មានការរំលោភសិទ្ធិ គោរពសិទ្ធិមនុស្ស និងច្បាប់ តាម គោលនយោបាយលទ្ធិប្រជាធិបតេយ្យ មានមនសិការជាតិ មានសាមគ្គីឯកភាពជាតិ មានគតិយុត្តិធម៌ក្នុងសង្គម។

*ហេតុអ្វីបានជាគេនិយាយថា កិត្តិយស ‑ កិត្តិនាមរបស់មនុស្សម្នាក់ ត្រូវផ្តើមចេញពីសកម្មភាព និងសីលធម៌ អាកប្បកិរិយាផ្ទាល់ខ្លួនរបស់អ្នកនោះ ?*

*កិត្តិយស* មានន័យថា កេរ្តិ៍ឈ្មោះដ៏រុងរឿង យសស័ក្តិដ៏ល្បីល្បាញ និងថ្កុំថ្កើង។

*កិត្តិនាម* មានន័យថា នាមឈ្មោះ កេរ្តិ៍ឈ្មោះដ៏ល្បីល្បាញរន្ទឺសុះសាយ។

ត្រូវផ្តើមចេញពីសកម្មភាព សីលធម៌ អាកប្បកិរិយាផ្ទាល់ខ្លួន តាមរយៈកាយវិការ វាចាចិត្ត ដូចតទៅ ÷

• ដឹងខុស ដឹងត្រូវ ល្អអាក្រក់ ក្លាហាន ហ៊ានទទួលខុសត្រូវលើអំពើរបស់ខ្លួន តាំងខ្លួនជាម្ចាស់លើចិត្តរបស់ខ្លួន

• ស្គាល់ភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួន

• ស្រឡាញ់ខ្លួន គ្រួសាររបស់ខ្លួន ស្រឡាញ់អ្នកដទៃ ដោយគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ធ្វើឱ្យមានសមភាព សុខដុមរមនា។

• មានមនសិការក្នុងការងារ រកស៊ីតាមសមត្ថភាព និងតាមសម្មាអាជីវោ មិនរំលោភលើអ្នកតូចតាចជាងខ្លួន ឬអ្នកខ្សត់ខ្សោយជាងខ្លួន។

• មានសាមគ្គីភាពល្អ មិនបង្កទំនាស់ ស្រឡាញ់យុត្តិធម៌ ស្រឡាញ់មនុស្សជាតិទូទៅ ទទួលស្គាល់ទុក្ខវេទនារបស់អ្នកដទៃ ឱ្យដូចទុក្ខវេទនារបស់ខ្លួន។

• មានទំនាក់ទំនងល្អ មិនប្រកាន់ពណ៌សម្បុរ ប្រកាន់ពូជសាសន៍ មិនប្រកាន់វណ្ណៈ ឋានៈ ជំនឿសាសនា......។

• ប្រកាន់នូវព្រហ្មវិហារធម៌ទាំង ៤ ( មេត្តា ករុណា មុទិតា ឧបេក្ខា ) និងសីល ៥។

• បើជាអ្នកដឹកនាំ ត្រូវមានទសពិធរាជធម៌ ១០ ប្រការ គឺ ទាន ( អំណោយ ) សីល ( មិនប្រព្រឹត្តអាក្រក់ ) បរិច្ចាគ ( ចំណាយធនធាន ) អាជ្ជវៈ ( ស្មោះត្រង់ ) មទ្ទវៈ ( ទន់ភ្លន់ ) តបៈ ( គង់ឧបោសថសីល) អក្កោធនៈ ( មិនក្តៅក្រហាយ) អវិហឹង្សា ( មិនប្រើអំពើហឹង្សា ) ខន្តិ ( អត់ធ្មត់ ទន់ភ្លន់ ) អវិរោធនៈ ( មិនរំលោភបំពាន )

# បញ្ញាពុទ្ធិ ភាវៈ សុខៈ
# ក្នុងពុទ្ធសាសនា និងព្រហ្មញ្ញសាសនា

*ពុទ្ធិជាអ្វី ?* ពុទ្ធិ ( *La Connaissance* ) គឺជាចំណេះដឹង ការយល់ដឹងទូទៅរបស់មនុស្ស ភាសាក្តី ក្នុងចិត្តក្តី និងក្នុងការងារក្តី ។

*បញ្ញាពុទ្ធិ :* មានមូលហេតុ ៣ យ៉ាងគឺ ÷

❖ **ពុទ្ធិប្រធាន *Objet de la Connaissance***

| | | | |
|---|---|---|---|
| ជានាម | ជារូប | ជាអស្ថិរូប | - អ្នកបង្កើត<br>- អ្នកផ្សាយ<br>- អ្នកទទួល |
| Mental | Matiere | Metaphysique | |

❖ **ពុទ្ធិវត្ថុ *Objet de la Connaissance***

| | | | |
|---|---|---|---|
| ពុទ្ធសិល្ប៍ | ពុទ្ធសាសន | ពុទ្ធិវិជ្ជា | - វត្ថុ<br>- មនុស្ស<br>- សង្គមមនុស្ស<br>- ទេវៈ |
| Certhetuque | Religieuse | Savoir | |

❖ **ពុទ្ធិបំណង *But de la Connaissance***

តម្លៃនៃទំនាក់ទំនងរវាងពុទ្ធិប្រធាន និងពុទ្ធិវត្ថុ
- ល្អ អាក្រក់
- ពិរោះ មិនពិរោះ
- សុខ ទុក្ខ
- តថៈ សច្ចៈ អច្ឆរិយៈ

*ភាវៈជាអ្វី ?* សម្គាល់នូវការកកើតគ្រប់បែបយ៉ាងក្នុងធម្មជាតិតាំងពីកំណើតអរូបី រូបី និងអស្ថិរូប ។

*ឧទាហរណ៍ :* ដង្កូវ មេអំបៅ..... ។

*បញ្ហាភាវៈ* : មានមូលធាតុ ៣ យ៉ាង គឺ ÷

❖ **ភាវភាព** " ភាវៈមានរូបរាងរួចមកហើយ ដូចជាទឹក ខ្យល់ ភ្លើង ដី
- សភាពលក្ខណៈ (ដីខុសពីទឹកបែបណា?)
- ដំណើរ (សម្គាល់នូវការប្រព្រឹត្តទៅនៃភាវៈ)

❖ **ភាវវិធី** : វិធីបង្កើត $O_2 + H_2 \rightarrow H_2O$
- សាមញ្ញវិធី " វិធីបង្កើតភាវៈតាមមធ្យោបាយធម្មជាតិ " ។ *ឧទាហរណ៍ :* ដុសថ្មឱ្យក្ដៅ - ភ្លើង ។
- វិទ្យាវិធី " វិធីបង្កើតភាវៈតាមវិជ្ជាស្បង់ " *ឧទាហរណ៍ :* ការពិសោធន៍រកការពិត ។
- ទស្សនៈវិធី " វិធីបង្កើតភាវៈតាមទស្សនៈអ្នកប្រាជ្ញនីមួយៗ " ។

❖ **ភាវវាទទ្រឹស្ដី** ដែលពន្យល់ពីភាវៈ គឺយក ភាវភាព-ភាវៈ-វិធី-ភាវវាទទ្រឹស្ដី
- រូបនិយមវាទ "សំភារៈ" ទ្រឹស្ដី ដែលនិយមយកវិធីមកប្រើ " កម្មវត្ថុ សិក្សាលោក " ។
- មនោនិយមវាទ " ទ្រឹស្ដីដែលយកមនោជាធំ "
- សំយោគនិយមវាទ "ទ្រឹស្ដីដែលផ្សំរវាងមនោនិយម និងរូបនិយម

*បញ្ហាសុខ:* Bonheur

***សុខៈជាអ្វី ?*** ជាបំណងរបស់មនុស្ស ហើយនិងជាលទ្ធផលរួម ដែលកើតពីទំនាក់ទំនងរវាងពុទ្ធិ និងភាវៈ ។ សុខៈសម្គាល់នូវសេចក្ដីសុខ ។

*បញ្ហាសុខៈ* : មានមូលធាតុ ៣ យ៉ាង គឺ ÷

❖ **សុខភាព** ដំណើរនៃសុខៈ ពុទ្ធសាសនានិព្វាន្ត
- សភាពលក្ខណៈ " សុខៈ រូបរាង "
- ដំណើរ " ការប្រព្រឹត្តនៃសេចក្ដីសុខ " *ឧទាហរណ៍ :* អនុវត្ត វិវត្ត បដិវត្តន៍ ។

❖ **សុខវិធី** " វិធី សំរាប់បង្កើតសុខ
- សាមញ្ញវិធី " វិធីបង្កើតសុខបានជាធម្មតា " ឧទាហរណ៍ : ការស្វែងរកមាស ប្រាក់ ដើម្បីសុខក្នុងជីវភាព ។
- វិទ្យាវិធី "វិធីបង្កើតសុខតាមវិជ្ជាស្បង់" ឧទាហរណ៍ : ការគោរពអនាម័យ ។
- ទស្សនៈវិធី " វិធីបង្កើតសុខតាមទស្សនៈវិទូ និងការពិសោធន៍ផ្ទាល់ខ្លួន ។

- រូបធាតុនិយមវាទ " ទ្រឹស្ដីសម្គាល់សុខៈ យករូបធ្វើជាគោល ជាមូលដ្ឋាន នៃ

ទ្រឹស្តីដែលស្តែងឡើងតាមចិត្ត។

❖ សុខវាទ ទ្រឹស្តីដែលចងក្រង សំរាប់សុខៈ
- មនោនិយមវាទ " ទ្រឹស្តីពីសុខៈជាគោលមូលដ្ឋាន នៃទ្រឹស្តីតាមរូបវាទ ចិត្ត និងសំភារៈ "។
- បដិសំយោគនិយមវាទ " រូបនិយម និងមនោនិយម "

❖ **វណ្ណៈទាំង ៤** ក្នុងសាសនាព្រាហ្មណ៍
- ព្រាហ្មណ៍ : ពណ៌ស
- ស្តេច : ពណ៌ក្រហម
- វៃស្សៈ : ពណ៌លឿង
- សូទ្រ : ពណ៌ខ្មៅ

**ក. ព្រហ្មញ្ញសាសនា : ពុទ្ធិ ភាវៈ សុខៈ**

❖ *ពុទ្ធិ :* គឺជាចំណេះដឹង ការយល់ឃើញទូលំទូលាយយ៉ាងល្អប្រសើររបស់មនុស្ស នៅក្នុងភាសាក្តី ចិត្តក្តី ក្នុងការងារផ្សេងៗក្តី សុទ្ធតែជាពុទ្ធិ ដែលបានមកដោយសារអំណោយរបស់អាទិទេព។ ពុទ្ធិនេះ មាននៅក្នុងគម្ពីរវេទ ហើយអ្នក ដែលមានសិទ្ធិទទួល គឺពួកព្រាហ្មណ៍ ឬព្រះមហាក្សត្រ។

❖ *ភាវៈ* : សម្គាល់នូវអ្វីៗទាំងអស់ ដែលកើតមាននៅក្នុងលោក ដូចជាមនុស្ស ទឹក ដី ភ្លើង ខ្យល់ ជាដើម។ ភាវៈទាំងអស់នេះ សុទ្ធតែកើតឡើងដោយសារអាទិទេពជាអ្នកបង្កើត។

❖ *សុខៈ* : មនុស្សគ្រប់ៗរូបនៅក្នុងលោកយើងនេះ ដើម្បីបានសេចក្តីសុខកាយសប្បាយចិត្ត មានសុភមង្គល មនុស្សត្រូវតែមានភក្តីភាពចំពោះអាទិទេព ដោយអនុវត្តវិធីប្រតិបត្តិផ្សេងៗ នៅក្នុងសាសនាព្រាហ្មណ៍។

**ខ. ពុទ្ធសាសនា**

❖ *ពុទ្ធិ* : ជាចំណេះដឹង ការយល់ឃើញទូទៅរបស់មនុស្ស ទោះបីជាមានកម្រិតណាក្តី ពិតជាកើតចេញមកពីការសន្សំ ឧស្សាហ៍ព្យាយាមបន្តិចម្តងៗ របស់មនុស្ស មិនមែនជាអំណោយរបស់អាទិទេពឡើយ មានន័យថា មនុស្សគ្រប់វណ្ណៈ អាចរកពុទ្ធិឃើញទាំងអស់ តែដោយសារការតស៊ូព្យាយាម។

❖ *ភាវៈ* : គឺជាអ្វីៗ ដែលកើតមានឡើងនៅក្នុងលោកយើងនេះ មានកំណើតដោយសំខតធាតុ គឺធាតុផ្សំ។ *ឧទាហរណ៍ :* មនុស្សកើតឡើង ដោយសារធាតុផ្សំខ័ន្ធទាំង ៥ និងធាតុផ្សេងៗទៀត។ ក្នុងពុទ្ធសាសនាចែងថា មនុស្សបង្កើតភាវៈបាន ដោយភាវៈផ្សេងៗទៀតស្របតាមធម្មជាតិ ដែលទ្រទ្រង់ភាវៈ ពោលគឺ ពិសោធន៍អាចខុស អាចត្រូវ។ កំណើតភាវៈនោះ ទាក់ទងនឹងធម្មភាពភ្ជាប់ហេតុ និងផល ដែលមានការទាក់ទងគ្នា។

❖ *សុខៈ* : មនុស្សគ្រប់ៗរូប គ្រប់ជាតិសាសន៍ តែងតែចង់បានសេចក្តីសុខកាយ សប្បាយចិត្ត ព្រមទាំងសុភមង្គល ។ គ្រប់សាសនាទាំងអស់ តែងតែមានបំណងស្វែងរកសុខៈ គ្រាន់តែមធ្យោបាយ ដើម្បីសម្រេចផ្សេងៗគ្នាតែប៉ុណ្ណោះ។ ទ្រឹស្តីព្រះពុទ្ធចែងថា ដើម្បីសម្រេចសុខៈ គេត្រូវកសាងអំពើល្អ តាមផ្លូវកាយ វាចារចិត្ត និងផ្លូវសំភារៈ។

*តើការស្រឡាញ់រាប់អាន ការគោរព ការជួយទុក្ខធុរៈអ្នកដទៃមានសារៈប្រយោជន៍អ្វីខ្លះ ?*

• ទទួលការរាប់អាន ការគោរព ការយកអសារពីអ្នកដទៃ តបមកវិញនូវការជួយសង្គ្រោះ ឬលើកទឹកចិត្តពីអ្នកដទៃ នៅពេលដែលយើងមានអាសន្នអន់ក្រ ។

• មានភាពស្ងប់ សុខស្រួលក្នុងចិត្ត ( មានអរិយទ្រព្យ ក្នុងលោកខាងមុខ )

• មានមិត្តភាពនៅជុំវិញខ្លួន មានសាមគ្គីភាពជាកម្លាំងដ៏ខ្លាំងក្លា មានកិច្ចសហប្រតិបត្តិការល្អ

• ទទួលការគាំទ្រពីមិត្តភ័ក្ត្រ ញាតិមិត្តជិតឆ្ងាយ

• ទទួលបានកិត្តិយស និងសេចក្តីថ្លៃថ្នូរ ក្នុងជីវិត

• កសាងបានសង្គមមួយល្អ អាចធ្វើឱ្យមានសុខសុវត្ថិភាពទាំងអស់គ្នា

*ហេតុអ្វីបានជាគេនិយាយថា សេចក្តីថ្លៃថ្នូររបស់មនុស្សជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស ?*

• មនុស្សម្នាក់ៗ កើតមកហើយ តែងតែទាមទារ នូវសិទ្ធិរស់រានមានជីវិត សេរីភាព សុភមង្គល និងសេចក្តីថ្លៃថ្នូរ ដើម្បីរស់ជាមនុស្សឱ្យបានសមរម្យនៅក្នុងសង្គម ។

• បើសិនជាជីវិត សេរីភាព សុភមង្គល សេចក្តីថ្លៃថ្នូរ ត្រូវបានគេបំបិទ ឬដកហូតនោះ យើងឃើញថា វាផ្ទុយពីសំណូមពររបស់មនុស្ស ។ លក្ខខ័ណ្ឌទាំងអស់ខាងលើនេះហើយ ពិតជានាំមកនូវសេចក្តីថ្លៃថ្នូរ និងជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស ក្នុងសង្គមប្រជាធិបតេយ្យពិតប្រាកដ ។

*តើធម៌ព្រះពុទ្ធដែលថែងថា សេចក្តីសុខ និងទុក្ខកើតមានដល់បុគ្គលដែលជាអ្នកប្រព្រឹត្ត ព្រមទាំងហាមប្រព្រឹត្តអំពើអាក្រក់ ១០ យ៉ាង ដែលកើតចេញពីកាយ វាចា និងចិត្ត មានអត្ថន័យយ៉ាងណាខ្លះ ? ចូរពន្យល់ដោយលើកយកឧទាហរណ៍តាមផ្លូវលោក និងផ្លូវធម៌មកបញ្ជាក់។*

១. *សេចក្តីសុខ* : គឺជាសេចក្តីសប្បាយផ្នែកកាយចិត្ត ស្រណុកស្រួល ។

*ក- សេចក្តីសុខតាមផ្លូវលោកមាន ៖*

• សុខកើតពីការមានទ្រព្យ

• សុខកើតពីការបរិភោគ និងប្រើប្រាស់ទ្រព្យយ៉ាងសម្បូណ៌បែប

• សុខកើតពីការមិនជំពាក់បំណុលគេ

• សុខកើតពីការធ្វើការងារប្រាសចាកទោស

• សុខព្រោះគ្មានទំនាស់ គ្មានអសន្តិសុខសង្គម ។

*ខ. សេចក្តីសុខតាមផ្លូវធម៌មាន ៖*

• បាណាតិបាតា ( ហាមបំផ្លាញជីវិតសត្វលោក ) នាំឱ្យមានសិទ្ធិរស់រានមានជីវិត

• អទិន្នាទានា ( ហាមលួច ) នាំឱ្យមានស្វ័យសម្រេច និងសេចក្តីថ្លៃថ្នូរ មានតម្លៃជាមនុស្ស

• កាមេសុមិច្ឆាចារា ( ហាមសេពកាម ប្រពន្ធ កូនអ្នកដទៃ )

• មុសាវាទា ( ហាមពោលពាក្យមិនពិត ) នាំឱ្យសេចក្តីថ្លៃថ្នូរ មានតម្លៃជាមនុស្ស

• សុរាមេរយៈ ( ហាមផឹកគ្រឿងស្រវឹង ) នាំឱ្យមានសេចក្តីថ្លៃថ្នូរប្រចាំកាយ ។

២.សេចក្តីទុក្ខ ជាការព្រួយបារម្ភ ជាការលំបាក ។

*ក. សេចក្តីទុក្ខតាមផ្លូវលោកមាន ÷*

• ទុក្ខព្រោះស្រេកឃ្លាន




• ទុក្ខព្រោះរកស៊ីពុំបាន ខ្វះការងារធ្វើ

• ទុក្ខព្រោះជីវភាពដុនដាប ជំពាក់បំណុលគេ

• ទុក្ខព្រោះអសន្តិសុខ គ្មានសុវត្ថិភាព

• ទុក្ខព្រោះមានសង្គ្រាម ឥតឈប់ឈរ

*ខ. សេចក្តីទុក្ខតាមផ្លូវធម៌*

សេចក្តីទុក្ខតាមផ្លូវធម៌គ្មានទេ ពីព្រោះធម៌នាំមកនូវសីល ដែលវៀរ-ចាកអំពើអាក្រក់គ្រប់បែបគ្រប់យ៉ាង ប្រកាន់យកតែអំពើល្អតាមផ្លូវកាយ វាចា និងចិត្ត ។

៣. មនុស្សម្នាក់ៗ មិនត្រូវប្រព្រឹត្តអំពើអាក្រក់ ១០ យ៉ាង ដែលទាក់ទងនឹងសិទ្ធិមនុស្ស ។

*ក. កាយកម្ម ៣ ( ដោយអំពើរ )*

• មិនត្រូវសម្លាប់ ( សិទ្ធិរស់រានមានជីវិត )

• មិនត្រូវលួច ( សិទ្ធិស្វ័យសម្រេច )

• មិនត្រូវប្រព្រឹត្ត រំលោភលើភេទនានា ( សិទ្ធិស្វ័យសម្រេច )

*ខ. វិចីកម្ម ៤ ( ដោយវាចា )*

• មិនត្រូវភូតកុហក ( សិទ្ធិស្វ័យសម្រេច )

• មិនត្រូវនិយាយញ្ញោះញ្ញង់ ( សិទ្ធិស្វ័យសម្រេច ) និងសេចក្តីថ្លៃថ្នូរ

• មិនត្រូវនិយាយត្រគោះបោះបោក ( សិទ្ធិស្វ័យសម្រេច ) និងសេចក្តីថ្លៃថ្នូរ

• មិនត្រូវនិយាយពាក្យមិនបានការ ( សិទ្ធិស្វ័យសម្រេច ) និងសេចក្តីថ្លៃថ្នូរ ។

*គ. មនោកម្ម ៣ ( ដោយចិត្ត )*

• មិនត្រូវចង់បានរបស់អ្នកដទៃ ( សិទ្ធិស្វ័យសម្រេច ) និងសេចក្តីថ្លៃថ្នូរ

- មិនត្រូវចងអាឃាត គុំគួន ព្យាបាទ ( សិទ្ធិស្វ័យសម្រេច ) និងសេចក្ដីថ្លៃថ្នូរ
- មិនត្រូវប្រែក្លាយការពិត ( សិទ្ធិស្វ័យសម្រេច ) និងសេចក្ដីថ្លៃថ្នូរ ។

## ពុទ្ធសាសនា និងសង្គមខ្មែរ

បន្ទាប់ពីព្រះសម្មាសម្ពុទ្ធទ្រង់ចូលព្រះបរិនិព្វានទៅ ប្រហែលជា ២១៨ ឆ្នាំមុនគ.ស ក្នុងរាជរបស់ព្រះបាទ ***ធម្មាសោកមហារាជ*** ដែលបានសោយរាជ្យនៅក្នុងរាជធានី បាតសិបុត្ត នៃមគធរដ្ឋ ព្រះអង្គបានផ្សព្វផ្សាយ នូវតេជានុភាព ទូទាំងប្រទេសឥណ្ឌា ។ ព្រះអង្គរូបនេះ ចូលកាន់ព្រះពុទ្ធសាសនានៅព.ស ២៣៤ ។

ព្រះបាទ ***អសោកមហារាជ*** ដើមឡើយជាស្ដេចចក្រពត្តិ នៅប្រទេសឥណ្ឌា ជាស្ដេចហ្វាស៊ីស ព្រៃផ្សៃបំផុត ។ ព្រះអង្គបានសម្លាប់សត្រូវអស់មួយចំនួនធំ ក្នុងពេលធ្វើសង្គ្រាមជាមួយ ***កលិង្គរាស្ត្រ*** ។ មិនតែប៉ុណ្ណោះ ព្រះអង្គថែមទាំងបានសម្លាប់បងប្អូនរួមឈាមជាមួយចំនួន ៩៩ នាក់ទៀតផង ។ ក្រោយពីបានប្រព្រឹត្តនូវអំពើដ៏ឃោរឃៅនោះមក ព្រះអង្គបានកើតមាននូវវិប្បដិសារីជាពន់ពេក បណ្ដាលឱ្យមានសមាណចិត្តមើលឃើញផ្លូវធម៌អាចិតាមពុទ្ធវចនៈ ៨៤០០០ ធម្មក្ខន្ធ ក៏បានចូលខ្លួនទៅកសាងប្រាសាទមួយចំនួន ដើម្បីឧទ្ទិសដល់ពុទ្ធសាសនា ពិសេសគឺពុទ្ធវចនៈដែលមាន ៨៤០០០ ធម្មក្ខន្ធ ។

តាមប្រភពពីកោះលង្ការបានឱ្យដឹងថា ក្រោយពីពេលធ្វើសង្គាយនាអស់ចំនួន ៤ ដងមក ព្រះមោគ្គលីបុត្តតិស្សត្ថេរ បានចាត់ឱ្យ សោណត្ថេរ និងឧត្តរត្ថេ ចុះមកកាន់ដែនដី " សុវណ្ណភូមិ " របស់យើង ក្រោមការជួយឧបត្ថម្ភរបស់ព្រះបាទ ធម្មាសោកមហារាជ ។

*ប្រទេសកម្ពុជាសម្បូណ៌សម្បត្តិធម្មជាតិ ចុះហេតុអ្វីប្រជាជននៅតែក្រ ?*

✲ *ប្រជាពលរដ្ឋនៅមានជួបប្រទះកង្វះខាតការអប់រំ ÷ ( ពិសេសបច្ចេកវិទ្យាទំនើប )*

- គ្មានចំណេះដឹង ↔ ល្ងង់ ↔ ក្រ ↔ មានជម្ងឺ ↔ គ្មានការអភិវឌ្ឍ
- មានយុវជនពាលាអាវ៉ាសែ ↔ មានស្វាមីភរិយាអពមង្គល ↔ មានអំពើហឹង្សាក្នុងគ្រួសារ និងសង្គម
- ងាយស្រួលក្នុងការចាញ់បោកគេ ឬត្រូវគេបោក
- គ្មានយោបល់ ↔ គ្មានដំណោះស្រាយបញ្ហាក្នុងគ្រួសារ និងសង្គម
- គ្មានបំណិនជីវិត ↔ គ្មានសមត្ថភាពបម្រើការងារផ្សេងៗ

✲ *ប្រជាជនខ្វះមូលដ្ឋានសំភារៈថវិកា ÷*

- ខ្វះដីធ្លី ខ្វះមធ្យោបាយផលិតកម្ម ខ្វះកម្លាំងផលិត ខ្វះទីផ្សារសម្រាប់លក់កសិផល ( កែច្នៃកសិផល )

✡ *ជម្លោះប្រដាប់អាវុធ ÷*

- ប្រទេសខ្មែរ ជាប្រទេសមួយដែលទើបតែងើបចេញពីសង្គ្រាមជាយូរឆ្នាំ

✡ *ប្រព័ន្ធគ្រប់គ្រងអំណាច ÷*

- មិនទាន់គោរពច្បាប់ឱ្យបានត្រឹមត្រូវ ច្រើនប្រើអំណាចផ្ដាច់ការ

✡ *អំពើកេងប្រវ័ញ្ចមនុស្ស ÷*

- ផ្អែកលើទឹកប្រាក់ និងអំណាច.......

✡ *កំណើនប្រជាជន ÷*

- ទាមទារការកើនឡើង នៃការប្រើប្រាស់ និងមូលដ្ឋានសំភារៈបរិក្ខារ

✡ *វចនាសម្ព័ន្ធសង្គម ÷*

- ប្រទេសតូច មានប្រជាជនតិច ក្បាលម៉ាស៊ីនដឹកនាំ និងគ្រប់គ្រងសំពីងសំពោង..........

## I. សម័យនគរភ្នំ

*ព.ស.វទី ៦ - ១១ " ព.ស ៥៤៣ - ១០៩៣ "*

*គ.ស ស.វទី ១ - ៦ " គ.ស ១៥៥០ "*

នៅពេលនោះ ប្រទេសកម្ពុជាយើងមានការគោរពសាសនាចំនួនពីរគឺ ព្រាហ្មណ៍សាសនា និងពុទ្ធសាសនា។ នៅក្នុងព្រាហ្មណ៍សាសនា គេគោរពព្រះឥសូរជាធំ និងព្រះវិស្ណុ ព្រះហរិហរៈ " ព្រះឥសូរ និងព្រះនារាយណ៍រួមគ្នា "។

ចំណែករីឯខាងពុទ្ធសាសនាវិញ គេបានគោរពពុទ្ធសាសនាថេរវាទ " និកាយ " រហូតមកដល់សតវត្សទី ២ ពុទ្ធសាសនា បានរីកចំរើនខ្លាំងជាព្រាហ្មណ៍សាសនា។ នៅសតវត្សទី ១ - ៦ ប្រទេសកម្ពុជាមានឈ្មោះថា " នគរភ្នំ " ចិនហៅថា ហ្វូណន ក្នុងរាជធានី " ទូមូ " ( ពាក្យបុរាណហៅ " ទមាក់ " ទ្រមាក់ អ្នកបរបាញ់ )។

សិលាចារឹកខ្មែរបានសរសេរថា " កុរុងព្នំ " ម្រ៉ះវ្នំ សំស្ក្រឹតហៅថា "បពិត ភូបាល " ស្ដេចភ្នំ ក្នុងរាជធានីវ្យាធបុរៈ ប្រែថា " អ្នកបរបាញ់ " តាំងនៅតំបន់បាភ្នំ ខេត្តព្រៃវែងសព្វថ្ងៃនេះ។

## II. សម័យចេនឡា

*ព.ស.វទី ១១ - ១៤ " ព.ស ១០៩៣- ១៣៤៥ "*

*គ.ស.ស.វទី ៦ - ចុងស.វទី ៨ " គ.ស ៥៥០- ៨០២ "*

នៅសម័យនេះ សាសនាព្រាហ្មណ៍បានរីកចំរើនលូតលាស់ជាងពុទ្ធសាសនា រហូតដល់សតវត្សទី ១២។ ពេលនោះ ពុទ្ធសាសនាហីនយានបានថយចុះឥទ្ធិពលបន្តិច។ នៅចុងសតវត្សទី ៧ ពុទ្ធសាសនាមហាយានបានចូលមកផ្សព្វផ្សាយឥទ្ធិពលក្នុងស្រុកខ្មែរ ហើយបានរីកចំរើនលូតលាស់ដល់សតវត្សទី ១៣។ នៅពេលនោះ គេពុំសូវឃើញមានរូបបដិមាករ ដែលជាពោធិសាត្វលោកេស្វរៈ ( អវលោកេស្វរៈ គេឃើញមាននៅតែក្នុងប្រាសាទខ្លះៗ ដូចជាប្រាសាទ "

ក្រមួនស " នៅកម្ពុជាក្រោម ប្រាសាទ " តាគាម " នៅខេត្តសៀមរាមជាដើម ) ទៀតទេ។ លុះមកដល់សតវត្សទី ៨ សាសនាព្រាហ្មណ៍នៅតែរីកចំរើនតទៅទៀត។

## III. សម័យមហានគរ

*ព.ស.វទី ១៤_ ២០ " ព.ស ១៣៤៥_ ១៩៧៦ "*




*គ.ស.វទី ៩_ ១៥ " គ.ស ៨០២_ ១៤៣២ "*

ព្រះបាទ **ជ័យវរ្ម័នទី ២** ទ្រង់បានឡើងសោយរាជ្យនៅគ.ស ៨០២ នៅមហេន្ទ្រពតិ គឺភ្នំគូលែន។ កាលនោះ ទ្រង់បាននិមន្តព្រាហ្មណ៍ម្នាក់ ដែលមានឈ្មោះ **ហិរណ្យទាមៈ** ឱ្យមកជួយរៀបចំហោមពិធីប្រកាសឯករាជ្យ ជាចក្រពត្តិធិរាជ ហើយកិត្តិយសរបស់ព្រះអង្គ ជាតួអង្គទេវរាជ គឺព្រះ **ហរិហរៈ** ដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាយើង។

ព្រះបាទ **ជ័យវរ្ម័នទី ២** ជាស្តេចមួយអង្គដ៏ប្រសើរក្រៃលែង ពីព្រោះអង្គទ្រង់បានបង្រួបបង្រួមប្រទេសដែល



បែកបាក់គ្នា ឱ្យមករួមជាមួយគ្នាឡើងវិញ។ ស្តេចអង្គនេះ កាន់សាសនាព្រាហ្មណ៍ មិនកាន់ពុទ្ធសាសនានោះទេ ក៏ប៉ុន្តែពុទ្ធសាសនា ក៏នៅជាមួយគ្នាដូចដើម វិញដែរ។ ព្រះអង្គទ្រង់ឱ្យគេកសាងលិង្គព្រះឥសូរតម្កល់ទុកក្នុងប្រាសាទភ្នំ សម្រាប់គោរពបូជា។

នៅចុងសតវត្សទី ៩ គ.ស ៨៨៩ ព្រះបាទ **យសោវរ្ម័នទី ១** ទ្រង់បានឡើងសោយរាជ្យសម្បត្តិបន្ត ទ្រង់បានកាន់ព្រាហ្មណ៍សាសនា ដែលនិយមព្រះឥសូរជាធំ ក៏ប៉ុន្តែទ្រង់បានអនុញ្ញាតឱ្យកាន់ពុទ្ធសាសនាដែរ គឺពុទ្ធសាសនានិកាយហីនយាន មហាយាន ព្រមទាំងព្រហ្មញ្ញសាសនា (គោរពសាសនាទាំងបី)។

នៅសតវត្សទី ១២ ក្នុងរាជរបស់ព្រះបាទ **សូរិយាវរ្ម័នទី ២** គ.ស ១១១៣ មានការប្រែប្រួល ក្នុងសាសនាព្រាហ្មណ៍ គឺព្រះអង្គទ្រង់បានគោរពព្រះវិស្ណុជាធំ ដូចជាគេប្រទះឃើញមាននៅក្នុងក្បាច់ចម្លាក់នៅតាមជញ្ជាំងប្រាសាទអង្គវត្ត ដែលទាក់ទងនឹងព្រះអវតារបស់ព្រះវិស្ណុ (រឿងរាមាយណៈ រឿងមហាភារតៈជាដើម) រហូតដល់សតវត្សទី ១២ ទើបព្រះអង្គរេមកគោរពពុទ្ធសាសនាវិញ។

នៅសតវត្សទី ១៣ ព្រះបាទ **ជ័យវរ្ម័នទី ៧** ជាពុទ្ធសាសនិកដ៏ឆ្នើម ព្រះអង្គទ្រង់បានកាន់ពុទ្ធសាសនានិកាយមហាយាន គោរពព្រះពោធិសាត្វលោកេស្វរៈ ។ ព្រះអង្គទ្រង់បានផ្លាស់ប្តូរប្រពៃណី ដែលធ្លាប់តែបានគោរពទេវរាជ តាំងតែពីរាជរបស់ព្រះបាទ ***ជ័យវរ្ម័នទី ២*** មកគោរពពុទ្ធសាសនាវិញ ។ ប៉ុន្តែព្រហ្មញ្ញសាសនា ក៏ពុំទាន់រលាយសាបសូន្យនៅឡើយដែរ ។



***ព្រះបាទជ័យវរ្ម័នទី ៧***

ព្រះអង្គទ្រង់បានកសាងប្រាសាទជាច្រើន សម្រាប់ឧទ្ទិសដល់ពុទ្ធសាសនា ដូចជាប្រាសាទបាយ័ន តំណាងឱ្យព្រះអង្គចូទីវង្គត ។ ចំណែករីឯព្រះពោធិសាត្វលោកេស្វរៈ គឺស្ថិតនៅសមន្តមុខ ( មុខបួន ) ដែលនៅគ្រប់កំពូល ភ័ក្រ្តញញឹមទៅគ្រប់ទិសទីទាំង ៤ ហៅថាញញឹម " បាយ័ន " ។

បន្ទាប់ពីរាជព្រះបាទ ***ជ័យវរ្ម័នទី ៧*** មក ទើបគេវិលត្រឡប់មកកាន់ព្រហ្មញ្ញសាសនាឡើងវិញ ដែលគោរពព្រះឥសូរជាធំ ដោយមានការបំផ្លាញព្រះពុទ្ធរូប រហូតមកដល់ចុងសតវត្សទី ១៤ ពុទ្ធសាសនាផ្នែកភាសាបាលី ដែលបាននាំចូលតាំងពីសតវត្សទី ១២ ក៏បានរីកដុះដាលឡើងរហូតដល់ពេលបច្ចុប្បន្ននេះ ។

**IV. សម័យក្រោយមហានគរ**

ចាប់ពីគ.ស ១៥២០ ក្រោយសម័យមហានគរមក ព្រះពុទ្ធសាសនាថេរវាទបានប្រតិស្ថាននៅលើទឹកដីកម្ពុជា ដោយបានចាក់ឫសយ៉ាងជ្រៅជារៀងរហូតមក ចំណែកឯព្រហ្មញ្ញសាសនា និងពុទ្ធសាសនានិកាយមហាយានវិញ មិនសូវមានសាវ៏កចូលរួម ហើយក៏សាបសូន្យបន្តិចម្តងៗ ។

ព្រះពុទ្ធសាសនាថេរវាទ បានរីកចំរើន ហើយបានយកវត្តព្រហ្មញ្ញសាសនាមកធ្វើជាវត្តបែប



***ព្រះពោធិសត្វលោកេស្វរៈ***

ពុទ្ធសាសនាវិញ គឺបាត់សីរៈ លិង្គ ហើយបានលេច ឆ្លោឡើងនូវពុទ្ធរូបជំនួសវិញ។ វត្ត ដែលផ្លាស់ពីវត្ត ព្រហ្មញ្ញសាសនាមកជាវត្តពុទ្ធសាសនា មានដូចជាវត្ត អង្គតាំងក្រាំង វត្តរលាំង វត្តបាអង្គ វត្តព្រះលិង្គ វត្តតាំងនៅគោក វត្តក្រាំងស្វាយ វត្តរលាំងកែន វត្តបាឆាយជាដើម។ ការដែលផ្លាស់ប្តូរ មាននៅជិត ដាមទំនៀមទំលាប់ដូចពីដើម គេបានឱ្យកូនចៅទៅ រៀនសូត្រនៅតាមវត្តអារាម បង្រៀនអក្សរ លេខ នព្វន្ត រចនា ការស្ថាបនា ច្បាប់សីលធម៌ និងធម៌- អាថ៌ពុទ្ធសាសនា។ លុះរៀនចេះដឹងល្មមហើយ ត្រូវ បំបួសជាសាមណេរ ជាភិក្ខុ កើតជាទម្លាប់ថា កូន ប្រុសអាយុ ១២ ឆ្នាំ ត្រូវបួសជាសាមណេរ ដើម្បី សងគុណមាតា។

អាយុបាន ២១ ឆ្នាំ ត្រូវបួសរៀនជា ភិក្ខុ ដើម្បីសងគុណបិតា។ លុះបួសជាសាមណេរ ភិក្ខុហើយ ទើបគេរាប់ជាមនុស្សពេញលេញ។ នៅ ពេលសឹកមកវិញ គេហៅថា អន្ទិត បណ្ឌិត ដែល ប្រែថាជាអ្នកប្រាជ្ញ គេលែងហៅថា អា មឹង ទៀតហើយ។




ប្រាជ្ញាបារមីតា ជាព្រះពោធិសត្វ

*តើទំនៀមទំលាប់គ្រួសារបុរាណខ្មែរនិយមឱ្យកូនប្រុសសាងផ្នួស កូនស្រីចូលម្លប់ តើមានអត្ថន័យយ៉ាងណាខ្លះ ?*

✡ *អត្ថន័យនៃការសាងផ្នួស ÷*

• បួសរៀន ដើម្បីសងគុណម្តាយឪពុក ដែលមនុស្សខ្មែរមាន ជំនឿស៊ប់ទៅលើព្រះពុទ្ធសាសនា ( គុណម្តាយមាន ១២ គុណឪពុក មាន ២១ )

• ដំណាក់កាលទី ១ បួសជាសាមណេរ ដើម្បីសងគុណម្តាយ

• ដំណាក់កាលទី ២ បួសជាភិក្ខុ ដើម្បីសងគុណឪពុក

• បួស ដើម្បីទទួលការអប់រំ ពីចៅអធិការវត្ត ជាគ្រូបាអាចារ្យ ( ខាងផ្លូវលោក និងខាងផ្លូវធម៌ )

• មានចំណេះដឹងទូទៅ បំណិន ឥរិយាបថ ពិសោធន៍ ចំណេះ ចេះរស់នៅក្នុងសង្គម ពិសេសចំណេះវិជ្ជាជីវៈ ចំណេះបច្ចេកទេស និងពិសោធន៍ ក្នុងជីវភាពប្រចាំថ្ងៃ

• មានចំណេះដឹងផ្នែកសីលធម៌ គុណធម៌ ច្បាប់នានា ទំនៀម ទំលាប់ប្រពៃណីរបស់ជាតិខ្មែរ ដែលមានតាំងពីបុរាណកាលមក

• ការបួសរៀនសម័យបូរាណ គឺជាកាតព្វកិច្ច បើមិនបានបួស រៀន គេហៅអាមឹង ឬហៅកូនភ្នងចុងស្រុក ដែលសង្គម គេមិនរាប់ រក អ្នកនោះគ្មានសិទ្ធិកសាងគ្រួសារ តែបើបានបួសរៀនវិញ ចង់ កសាងគ្រួសារ ពេលសិកមក គេហៅថាអន្ទិត : មកពីពាក្យបណ្ឌិត

គឺជាអ្នកចេះដឹងខ្ពស់ មានសិទ្ធិស្ដីដណ្ដឹងកូនគេ ដែលទំនៀមទំលាប់ បូរាណ ពេលភ្ជាប់ពាក្យរួចហើយ មេ-បាខាងស្រី តម្រូវឱ្យកូនប្រុស ទៅនៅបម្រើគ្រួសារកូនស្រី ចាប់ពីរយៈពេល ៦ ខែ ទៅជាង ១ ឆ្នាំ តាមតែការកំណត់របស់មេបា។ ចំណុចទាំងអស់នេះហើយ គឺជាការធ្វើតេស្តចង់ដឹងពីចំណេះដឹង ដែលបានបួសរៀននៅ ឯវត្ត។

✡ *អត្ថន័យនៃការចូលម្លប់របស់កូនស្រី ÷*

- ទទួលដឹងឮ ឬទទួលស្គាល់ថា កូនខ្លួនពេញវ័យហើយ និងផ្សព្វផ្សាយឱ្យញាតិមិត្តដឹងឮ
- ដើម្បីបន្ទំរូបសម្ផស្សឱ្យស្រស់ថ្លា
- ដើម្បីទទួលការណែនាំពីម្ដាយ ឬបងប្អូនឱ្យយល់ដឹងពី
    - គេហកិច្ច ទំនៀមទំលាប់ប្រពៃណី សីលធម៌រស់នៅ......
    - អប់រំអត្តចារិត និងគុណធម៌
- ដើម្បីឱ្យពេញលក្ខណៈជាស្ត្រីខ្មែរ ជានារីគ្រប់លក្ខណ៍ ជាភរិយាដ៏ល្អ ក្នុងពេលអនាគតដ៏ខ្លី។

បច្ចុប្បន្ននេះ ការបួសរៀន មិនត្រូវបានគេអនុវត្តជាទូទៅនោះទេ ពីព្រោះសព្វថ្ងៃមានសាលារៀនគ្រប់ទីកន្លែង សម្រាប់អប់រំសីលធម៌ គុណធម៌ សាមគ្គីធម៌ ចំណេះដឹងខាងភាសា វិជ្ជាជីវៈ បច្ចេកវិទ្យាទំនើប ចំណេះដឹងទូទៅ.....។

ចំណែកឯប្រពៃណីចូលម្លប់ ក៏គេមិននិយមដែរ ពីព្រោះកូនស្រីមានសិទ្ធិស្មើនឹងបុរស ត្រូវទៅសាលារៀន ដើម្បីទទួលនូវចំណេះដឹងគ្រប់ផ្នែក ថែមទាំងមានឱកាសចូលរួម ក្នុងសកម្មភាពផ្សេងៗរបស់សង្គមទៀតផង។

- ការចូលម្លប់នាំឱ្យខាតកម្លាំងពលកម្ម ក្នុងគ្រួសារខ្មែរ
- ការចូលម្លប់នាំឱ្យខាតបង់ពេលវេលា ខាតទាំងកម្លាំងមនុស្ស សម្រាប់ថែទាំរាល់ថ្ងៃ
- ការចូលម្លប់នាំឱ្យខាតបង់ថវិកាគ្រួសារ និងសង្គមជាតិ។

ជនជាតិខ្មែរពេញចិត្តនឹងធ្វើបុណ្យទានផ្សេងៗជាច្រើន ក្នុងពុទ្ធសាសនា ដោយគេយល់ថា " ក្រក៏ក្រចុះឱ្យតែមាន គឺមានអរិយទ្រព្យ "។

**<u>បញ្ជាក់</u> :** នៅក្នុងនិកាយហីនយាន មានបែកចេញជាពីរវត្តផ្សេងៗគ្នា ÷

❖ **ធម្មយុត្តិ :** មានវិន័យមិនកាន់លុយកាក់ មិនពាក់ស្បែកជើង មិនស្ពាយបាត្រ គឺប្រតិបត្តិធម៌ដូចគ្នា តែអានខុសគ្នា។ ធម្មយុត្តិសូត្រធម៌អានតាម " សំស្ក្រឹត "។ *ឧទាហរណ៍ :* ពុទ្ធំ ធម្មំ.....(អានពុទ្ធាំង ធម្មាំង....)។

❖ **មហានិកាយ :** មានវិន័យធូរស្រាល គឺកាន់លុយកាក់ ពាក់ស្បែកជើង ស្ពាយបាត្រ នៅពេលទ្រង់បាត្រ។ សូត្រធម៌អានតាមភាសាបាលី។ *ឧទាហរណ៍ :* ពុទ្ធំ ធម្មំ.....។

ពុទ្ធសាសនាមានចែកចេញជាពីរនិកាយគឺ និកាយហីនយានថេរវាទ ទក្ខិណនិកាយ និងនិកាយមហាយាន "អាចរិយវាទ ឧត្តរនិកាយ "។

❖ **ហីនយាន :** ជាយានតូចចង្អៀត អាចផ្ទុកសត្វលោកទៅកាន់ត្រើយនិព្វានបានតិច ពីព្រោះវិន័យតឹងតែងហ្មត់ចត់។ និកាយនេះ និយមធម៌ចាស់ គឺគោរពប្រតិបត្តិតាមពុទ្ធោវាទ ដែលមាននៅក្នុងគម្ពីរ " ត្រៃបិដក " ជាឃ្លាំងផ្ទុកនូវពុទ្ធវចនៈរបស់ព្រះពុទ្ធ។ ប្រទេស ដែលនិយមកាន់និកាយហីនយានមាន ខ្មែរ ឡាវ ភូមា ថៃ ឥណ្ឌា ស៊ីរីលង្កា.....។




❖ **មហាយាន :** ជាយានមួយដ៏ធំ អាចផ្ទុកសត្វលោកបានច្រើន ទៅកាន់គោលដៅត្រឹមតែព្រះពោធិសត្វ ដែលអាចជួយណែនាំ អប់រំសត្វលោកបាន។ និកាយមហាយាន និយមធម៌ថ្មី មានវិន័យធូរស្រាល គោរពប្រតិបត្តិតាមលទ្ធិអាចរិយវាទ ពោលគឺគោរពគ្រូអាចារ្យតៗគ្នា ពុំមែនគោរពតាមពុទ្ធោវាទដូចនិកាយហីនយានឡើយ។ ពោធិសត្វ ដែលត្រូវគោរពមានព្រះពោធិសត្វ អវលោកេស្វរៈ ឬលោកេស្វរៈ បញ្ចុស្រ៊ីជាដើម...។

*ហេតុអ្វីបានជាមនុស្សគ្រប់រូប គ្រប់វ័យ មានសិទ្ធិទទួលការអប់រំ ?*

មនុស្សគ្រប់វ័យ ត្រូវមានសិទ្ធិទទួលការអប់រំគ្រប់ៗគ្នា

- មនុស្សគ្រប់ប្រភេទ គ្រប់វណ្ណៈ គ្រប់ឋានៈ គ្រប់សេវាសង្គម ត្រូវចូលរួមចំណែកក្នុងការអប់រំលើផ្នែកចំណេះដឹង



បំណិន ឥរិយាបទ ពោលគឺ ៖

▪ ទ្រឹស្តីផ្សារភ្ជាប់សង្គម

▪ ទ្រឹស្តីផ្សារភ្ជាប់ការប្រតិបត្តិ

▪ ការបណ្តុះបណ្តាលធនធានមនុស្ស ត្រូវផ្សារភ្ជាប់នឹងទីផ្សារពលកម្ម

ដើម្បីកាត់បន្ថយភាពក្រីក្រ ពង្រីក និងពង្រឹងយុទ្ធសាស្ត្រកាត់បន្ថយការចំណាយ សម្រាប់ការទទួលសេវាអប់រំ ៖

▪ បណ្តុះប្រាជ្ញាស្មារតី ឱ្យចេះត្រិះរិះពិចារណា សន្សំសំចៃខ្ពស់

▪ ចំពោះធនធានមនុស្សនៅគ្រប់សេវាសង្គម ត្រូវតែបានចូលទៅក្នុងសេវាអប់រំ បើធនធានមនុស្សក្នុងសេវាសង្គមណាមួយ ពុំបានចូលក្នុងសេវាអប់រំទេនោះ នឹងត្រូវធ្លាក់ចូលទៅក្នុងភាពក្រីក្រ ។

▪ ការអប់រំពិតជាសម្រេចបាននូវចតុស្តម្ភ ( ចំណេះដឹង ចំណេះធ្វើ ឥរិយាបថ និងចំណេះចេះរស់នៅក្នុងសង្គម )

កុមារា កុមារី យុវជនប្រុសស្រី និងមនុស្សពេញវ័យ មានសិទ្ធិទទួលផលប្រយោជន៍ពីការអប់រំ ដែលពួកគេនឹងត្រូវសម្រេចបានសំណូមពររៀនសូត្រជាមូលដ្ឋាន ដោយប្រសើរ និងពេញលេញបំផុត ពោលគឺមានការអប់រំមួយដែលមាន : រៀនដើម្បីចេះដឹង រៀនដើម្បីចេះធ្វើ រៀនដើម្បីសីលធម៌ល្អ និងរៀនដើម្បីចេះរួមរស់ជាមួយគ្នា ។

បច្ចុប្បន្នការវិវត្ត នៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើបមានសន្ទុះយ៉ាងខ្លាំងក្លាហួសពីការស្មាន ។ ចំណែងគំនិត និងទស្សនៈថ្មីៗ លេចឡើងជាបន្តបន្ទាប់ ធ្វើឱ្យជីវិតរស់នៅរបស់មនុស្សមានការប្រែប្រួលឥតឈប់ឈរ ទាំងរូបភាព និងខ្លឹមសារ ធ្វើឱ្យមុខរបរចិញ្ចឹមជីវិត ក៏មានការប្រែប្រួលទាំងពលកម្មខួរក្បាល និងរូបរាងកាយ ពីព្រោះត្រូវបានជំនួសដោយគ្រឿងម៉ាស៊ីន និងឧបករណ៍អេឡិចត្រូនិច ដែលជាហេតុធ្វើឱ្យមធ្យោបាយគមនាគមន៍ ក៏ត្រូវបានបំពេញ ពោលគឺសុទ្ធតែអភិវឌ្ឍន៍ ឈានឡើងឆ្ពោះទៅរកទំនើបកម្ម និងភាពសុក្រឹត ។

ប្រការទាំងអស់ដូចបានពោលខាងលើ ទើបទាមទារឱ្យមនុស្សត្រូវរៀនបន្តពេញមួយជីវិត ។

*ហេតុអ្វីបានជាគេនិយាយថា គោលដៅនៃជីវិតរបស់មនុស្ស មិនគ្រាន់តែជាការរស់រានមានជីវិតប៉ុណ្ណោះទេ តែត្រូវរស់ដោយមានសេចក្តីថ្លៃថ្នូរផងដែរ ?*

• មិនរស់ដើម្បីរស់ មិនរស់ដើម្បីហូប

• ត្រូវចេះរស់

• រស់ចុះសម្រុងជាមួយអ្នកដទៃ

• រស់ប្រកបដោយកិត្តិយស រស់មានប្រយោជន៍ដល់សង្គមជាតិ សង្គមគ្រួសារ និងខ្លួនឯងផ្ទាល់

✡ *រស់ឱ្យបានថ្លៃថ្នូរត្រូវ ៖*

• មានសីលធម៌ គុណធម៌ រស់នៅល្អ

• គោរពសិទ្ធិ ច្បាប់ និងសេរីភាពអ្នកដទៃ

• ស្វះស្វែងរកមុខជំនាញ ចំណេះដឹង បច្ចេកទេស វិទ្យាសាស្ត្រ តាមការវិវត្តរបស់សង្គម ដើម្បីកសាងសមត្ថភាពខ្លួន

• ចូលរួមថែរក្សាបរិស្ថាន អនាម័យ

• ចូលរួមកសាង ការពារសម្បត្តិវប្បធម៌ សម្បត្តិធម្មជាតិ និងទឹកដី

• ចូលរួមបំបាត់បាតុភាពអវិជ្ជមាន

• អភិវឌ្ឍខ្លួនឯងជានិច្ច

បើមនុស្សម្នាក់ៗ ធ្វើដូច្នេះបានហើយ ទើបមានន័យថា រស់នៅថ្លៃថ្នូរ។

*ប្រទេសជាតិរីកចម្រើន មានការអភិវឌ្ឍ ប្រកបដោយសុខសុវត្ថិភាព មិនអាចផ្តាច់ចេញពីការបណ្តុះបណ្តាលធនធានមនុស្សបានឡើយ។ តើកម្ពុជាសព្វថ្ងៃ ត្រូវបណ្តុះបណ្តាលធនធានមនុស្សមានលក្ខណៈសម្បត្តិយ៉ាងដូចម្តេច ?*

*ការអភិវឌ្ឍ* មានន័យថា ការរីកចម្រើនខ្លាំង ការលូតលាស់ក្រៃលែង។

*សុវត្ថិភាព* មានន័យថា ការប្រកបដោយសេចក្តីសុខសប្បាយ។

*ធនធានមនុស្ស* មានន័យថា មនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ពេញលេញ។

លក្ខណៈសម្បត្តិ ដែលត្រូវបណ្តុះបណ្តាល ÷

• កាយសម្បទារឹងមាំ គឺអប់រំ ផ្នែកសុខភាព អនាម័យ និងបរិស្ថានដល់ជនគ្រប់រូប ឱ្យស្គាល់អំពីសារៈសំខាន់ និងផលប្រយោជន៍លើផ្នែកនីមួយៗ។ " ផឹកស្អាត ហូបស្អាត រស់នៅស្អាត " នាំឱ្យសុខភាពរឹងមាំ ជាកម្លាំងអភិវឌ្ឍប្រទេសជឿនលឿន។

• បណ្តុះបណ្តាលនូវបញ្ញាស្មារតី ដោយឆ្លងកាត់ការត្រិះរិះពិចារណា បណ្តាចំណេះដឹងនានា ប្រកបដោយសីលធម៌ គុណធម៌ខ្ពស់ ពោលគឺ ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រព័ន្ធខួរក្បាល។

• បណ្តុះបណ្តាលចិត្តគំនិត ឆន្ទះមោះមុត ប្រយុទ្ធយ៉ាងអង់អាចក្នុងកិច្ចការអភិវឌ្ឍប្រសទេសជាតិ ទប់ទល់រាល់សកម្មភាពអសកម្មរបស់សង្គម បង្កើតឡើងជាស្មារតីសាមគ្គីភាព ភាតរភាព មនុស្សធម៌ អហិង្សា លទ្ធិប្រជាធិបតេយ្យ និងបង្កើតបានជាការស្រឡាញ់ ថែរក្សាការពារ នូវអត្តសញ្ញាណជាតិ ដែលជាដួងព្រលឹងរបស់ជាតិខ្លួន។

• បង្កើតស្នាដៃ ដែលជាទេពកោសល្យរបស់មនុស្សគ្រប់រូប ឱ្យក្លាយទៅជាកោសិការរបស់សង្គម។ ម្នាក់ៗ ត្រូវធ្វើអ្វីៗ ដែលជាគុណប្រយោជន៍ដល់សង្គមជាតិខ្លួន។ ការរស់នៅមិនប្រកាន់ឋានៈ ពណ៌សម្បុរ ជំនឿសាសនា គឺជាគំនិតចេះរួមរស់ ក្នុងសន្តិភាព និងចុះសម្រុងគ្នា។ ទង្វើទាំងអស់នេះ ដើម្បីកសាងខ្លួនឱ្យក្លាយជាស្ថាបនិកដ៏សកម្ម ក្នុងការកសាងប្រវត្តិសាស្ត្រ របស់សង្គមជាតិ។

<u>**ឯកសារពិគ្រោះ**</u>

- វប្បធម៌ អរិយធម៌ របស់លោក **សរ សារុន**
- វប្បធម៌ អរិយធម៌ខ្មែរ-ឥណ្ឌា របស់លោក **ឆាយ ឆៃសុខ**
- អរិយធម៌ របស់អ្នកស្រី **ត្រឹង ងា**
- សៀវភៅព្រះរាជពិធីទ្វារទសមាស របស់ឧកញ៉ា **ពិន្ទុ ឈឹម ក្រសេម**
- ឯកសារ " នគរគោកធ្លករបស់លោក **ឆត្រាប្រេម ថូឌី** ១៩៧៣
- វប្បធម៌ អរិយធម៌ ខ្មែរ-ឥណ្ឌា របស់លោក **សែម សូរ** ១៩៧១
- អរិយធម៌ខ្មែរ " អាទិទេពក្រុងអង្គរ " របស់លោក **ថាច់ ទ៉ាន់ថាត** និង **កែម សូភុន** ឆ្នាំ ១៩៨៩
- អរិយធម៌ខ្មែរ-មន របស់លោក **កែប ទ៉ានឌី**
- ប្រពៃណីអ្នកស្រុក ចេនឡា របស់លោក **លី ធាមតេង** ១៩៧៣
- សាសនា និងទំនៀមទម្លាប់របស់ពុទ្ធសាសនបណ្ឌិត ១៩៧០
- វប្បធម៌ អរិយធម៌របស់លោក **ឆ សោ**
- ប្រវត្តិសាស្ត្រកម្ពុជារបស់លោក **ស៊ន សំណាង**